ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការមេស្ថិតិ

# របាយការណ៍ពាក់កណ្តាលអាណត្តិ

**រៀបចំដោយ**

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

**ខែ វិច្ឆិកា ឆ្នាំ ២០១២**

# បុព្វកថា

ខ្ញុំមានសេចក្ដីរីករាយ សូមណែនាំនូវរបាយការណ៍ពាក់កណ្ដាលអាណត្តិផែនការមេស្ថិតិសម្រាប់កម្ពុជា។ ផែនការមេស្ថិតិបានកំណត់នូវផែនការអាទិភាពរយៈពេលវែង សម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិកម្ពុជា។ ផែនការនេះផ្ដល់នូវក្របខ័ណ្ឌការងារយ៉ាងទូលំទូលាយក្នុងការអភិវឌ្ឍន៍ស្ថិតិផ្លូវការទូទាំងព្រះរាជាណាចក្រកម្ពុជា។ ផែនការមេស្ថិតិគ្របដណ្ដប់សកម្មភាពស្ថិតិ និងទិសដៅអភិវឌ្ឍន៍របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក៏ដូចជាអង្គភាពស្ថិតិដែលបានចាត់តាំង នៃបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងធនាគារជាតិនៃកម្ពុជា។

ផែនការមេស្ថិតិបច្ចុប្បន្ន គ្របដណ្ដប់រយៈពេលពីឆ្នាំ ២០០៨ រហូតដល់ឆ្នាំ ២០១៥។ នៅឆ្នាំ ២០១២ ជារយៈពេលនៃការពិនិត្យឡើងវិញដើម្បីធ្វើការវាយតម្លៃនូវផែនការនេះ និងធ្វើការកែតម្រូវប្រសិនមានការចាំបាច់ ជាពិសេស ទាក់ទងទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកម្ពុជា និងការកើនឡើងនូវតម្រូវការនានា និងគម្លាតហិរញ្ញប្បទានជាក់ស្ដែង និងការពិចារណាដែលថាក្របខ័ណ្ឌការងារអាស៊ាននឹងមានឥទ្ធិពលកាន់តែទូលំទូលាយទៅលើប្រព័ន្ធស្ថិតិជាតិ នាពេលអនាគត។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមយកឱកាសនេះសម្ដែងនូវការដឹងគុណចំពោះអង្គការ Sida ដែលបានជួយឧបត្ថម្ភគាំទ្រហិរញ្ញវត្ថុ និងស្ថិតិស៊ុយអែត ដែលបានគាំទ្រផ្នែកបច្ចេកទេស ក្នុងការរៀបចំនូវរបាយការណ៍ត្រួតពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិផែនការមេស្ថិតិនេះ។ ខ្ញុំក៏សូមសម្ដែងនូវការដឹងគុណផងដែរ ចំពោះក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ ដែលបានជួយគាំទ្រដល់ការរៀបចំរបាយការណ៍ត្រួតពិនិត្យពាក់កណ្ដាលអាណត្តិនេះឱ្យចេញជារូបរាងឡើង។

របាយការណ៍ត្រួតពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិផែនការមេស្ថិតិ ត្រូវបានអនុម័តជាឯកច្ឆន្ទដោយក្រុមប្រឹក្សាស្ថិតិ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២។ ក្នុងនាមក្រុមប្រឹក្សាស្ថិតិ និងអ្នកប្រើប្រាស់ស្ថិតិផ្លូវការកម្ពុជាទាំងអស់ ខ្ញុំសូមប្រគល់ជូននូវផែនការមេស្ថិតិថ្មីនេះ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
**ប្រធានក្រុមប្រឹក្សាស្ថិតិ**

**ឆាយ ថន**

ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ ២០១២

# អារម្ភកថា

ផែនការមេស្ថិតិគ្របដណ្តប់សកម្មភាពស្ថិតិ និងគម្រោងអភិវឌ្ឍន៍ នៃគ្រប់បណ្តាក្រសួងស្ថាប័នទាំងអស់នៅក្នុងប្រព័ន្ធស្ថិតិជាតិនៃព្រះរាជាណាចក្រកម្ពុជា។ផែនការមេស្ថិតិ ឆ្លុះបញ្ចាំងពីមហិច្ឆតាខ្ពស់ ដើម្បីឆ្លើយតបនូវតម្រូវការស្ថិតិរបស់អ្នកប្រើប្រាស់នៅក្នុងសង្គមកម្ពុជាទាំងមូល។ ផែនការនេះត្រូវបានរៀបចំឡើងដោយមានរចនាសម្ព័ន្ធផែនការ និងមានកម្មវិធីហេដ្ឋារចនាសម្ព័ន្ធស្ថិតិយ៉ាងត្រឹមត្រូវ ដោយក្នុងនោះរួមមានកម្មវិធីការងារស្ថិតិ ផែនការហិរញ្ញវត្ថុ និងសំណើថវិកា ព្រមទាំងការអនុវត្តផែនការសម្រាប់ប្រព័ន្ធស្ថិតិជាតិទាំងមូល។ នៅក្នុងផែនការមេស្ថិតិមានព័ត៌មានអំពីការសន្យាផ្តល់ និងមានរៀបរាប់ពីសូចនាករសំខាន់ៗមួយចំនួន។ ផែនការមេស្ថិតិបច្ចុប្បន្ន បង្ហាញពីបញ្ញត្តិការងារអនុវត្តន៍ចាប់តាំងពីឆ្នាំ ២០០៧ និងគ្របដណ្តប់ពេលវេលាពីឆ្នាំ ២០០៨ រហូតដល់ឆ្នាំ ២០១៥។

គោលបំណងទូទៅនៃការត្រួតពិនិត្យឡើងវិញនូវផែនការមេស្ថិតិ ដែលបានអនុវត្តន៍នៅឆ្នាំ ២០១២ នេះ គឺដើម្បីវាយតម្លៃទៅលើសកម្មភាពនានា ដែលមាននៅក្នុងផែនការនេះ ជាមួយនឹងការវាយតម្លៃនូវរាល់ការរៀបចំការអនុវត្ត និងអំពីថាតើសកម្មភាពទាំងនេះ បានរួមចំណែកក្នុងការអនុវត្តផែនការមេស្ថិតិយ៉ាងដូចម្តេចខ្លះ។ ការងារនេះ មានការចូលរួមដោយអ្នកផលិត អ្នកប្រើប្រាស់ទិន្នន័យ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងអនុក្រុមការងារផ្នែកស្ថិតិរបស់ក្រុមការងារបច្ចេកទេសផែនការ និងកាត់បន្ថយភាពក្រីក្រ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។

ការសន្និដ្ឋានដ៏សំខាន់មួយ ដែលបានលើកឡើងនៅក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិរបស់ផែនការមេស្ថិតិនេះ គឺគម្លាតហិរញ្ញប្បទានយ៉ាងធំ ដែលនៅតែជាកត្តាចាំបាច់ក្នុងការលើកមកពិចារណា។ មានមួយផ្នែកតូចតែប៉ុណ្ណោះ នៃសកម្មភាពស្ថិតិជាអាទិភាពដែលទទួលបានការផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់។ ប្រមាណជា ១៧.៥ ភាគរយ ដែលជាហិរញ្ញប្បទានបានទទួលពីថវិកាចរន្តរបស់រាជរដ្ឋាភិបាល និងប្រហាក់ប្រហែលគ្នានេះ ដែលបានផ្តល់ដោយអង្គការ ដៃគូអភិវឌ្ឍន៍។ បើពុំមានការផ្តល់បន្ថែមនូវហិរញ្ញប្បទានពីរាជរដ្ឋាភិបាល ឬពីដៃគូអភិវឌ្ឍន៍ផ្សេងៗនោះទេ ប្រហែលពីរភាគបីនៃសកម្មភាពជាអាទិភាពសម្រាប់ស្ថិតិផ្លូវការ នឹងមិនអាចអនុវត្តបានឡើយ។ ក្នុងដំណើរការនៃការពិនិត្យឡើងវិញនេះ មានការស្នើឡើងថារាជរដ្ឋាភិបាលកម្ពុជាគួរបង្កើនថវិកាសម្រាប់សកម្មភាពស្ថិតិជាអាទិភាព និងសម្រាប់ផលិកម្មស្ថិតិផ្លូវការ ឱ្យបានកាន់តែច្រើនបន្ថែមទៀត ដូច្នេះហិរញ្ញប្បទានសម្រាប់ប្រព័ន្ធស្ថិតិជាតិទាំងមូល នឹងត្រូវបានផ្តល់គ្រប់គ្រាន់យ៉ាងហោចណាស់ត្រឹមឆ្នាំ ២០១៥។

យើងសូមអរគុណចំពោះសមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិ និងមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានគាំទ្រដល់វិទ្យាស្ថានជាតិស្ថិតិ ក្នុងការរៀបចំនូវរបាយការណ៍ត្រួតពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃផែនការមេស្ថិតិនេះ។ យើងក៏សូមសម្តែងនូវអំណរគុណផងដែរ ចំពោះមន្ត្រីវិទ្យាស្ថានជាតិស្ថិតិដែលបានខិតខំប្រឹងប្រែងក្នុងការបំពេញការងារនេះ។ លើសពីនេះទៅទៀត យើងសូមធ្វើការវាយតម្លៃខ្ពស់ចំពោះស្ថិតិស៊ុយអែត ដែលបានផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងការរៀបចំនូវរបាយការណ៍នេះឡើង។

**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**
**ប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ**



**សន ស៊ីថន**

ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ ២០១២

# មាតិកា

ទំព័រ


**ពាក្យកាត់** ............ iii

**សេចក្តីសង្ខេបប្រតិបត្តិការ** ............ Vi

**ផ្នែកទី១ ស្ថានភាព និងការវាយតម្លៃនាពេលបច្ចុប្បន្ន** ............ ១

**១ ប្រវត្តិសង្ខេប និងដំណើរការ** ............ ១

១.១ ផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ............ ១

១.២ សកម្មភាពអភិវឌ្ឍន៍ស្ថិតិ ............ ២

១.៣ ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ............ ៣

១.៤ បទពិសោធន៍ស្វែងយល់ ............ ៣

១.៥ ការរៀបចំរបាយការណ៍ត្រួតពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃផែនការមេស្ថិតិ ៤

**២ ស្ថានភាពបច្ចុប្បន្ន នៃប្រព័ន្ធស្ថិតិជាតិ** ............ ៦

២.១ សមាសធាតុនៃប្រព័ន្ធស្ថិតិជាតិ ............ ៦

២.២ ទំនាក់ទំនងរវាងសមាសធាតុនៃប្រព័ន្ធស្ថិតិជាតិ ............ ៧

**៣ ការវាយតម្លៃចំណុចខ្លាំង និងចំណុចខ្សោយ នៃប្រព័ន្ធនាពេលបច្ចុប្បន្ន** ............ ៩

៣.១ ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធស្ថិតិជាតិ ............ ៩

៣.២ លទ្ធផលស្ថិតិ និងគុណភាពទិន្នន័យ ............ ១០

៣.៣ កម្រិតជំនាញ និងការបណ្តុះបណ្តាល ............ ១២

៣.៤ កត្តាប្រឈម ............ ១៣

៣.៥ ការវាយតម្លៃតាមរយៈការសម្ភាសន៍ជាមួយអ្នកប្រើប្រាស់ អ្នកផលិតទិន្នន័យ និងដៃគូអភិវឌ្ឍន៍ ............ ១៤

**ផ្នែកទី២ ផែនការមេស្ថិតិ** ............ ១៩

**៤ ផែនការមេស្ថិតិ** ............ ១៩

៤.១ គម្រោងផែនការមេស្ថិតិ ............ ១៩

៤.២ ប្រតិបត្តិការនៃផែនការមេស្ថិតិ ............ ២០

**៥ កម្មវិធីហេដ្ឋារចនាសម្ព័ន្ធស្ថិតិ** ............ ២២

៥.១ ក្របខ័ណ្ឌច្បាប់ ............ ២២

៥.២ ការអភិវឌ្ឍធនធានមនុស្ស ............ ២២

៥.៣ ការលើកស្ទួយ/ការអភិវឌ្ឍប្រតិបត្តិការស្ថិតិ ............ ២៥

**៦ កម្មវិធីការងារស្ថិតិ ........ ២៦**

៦.១ ទស្សនវិស័យសម្រាប់ពេលអនាគត ........ ២៦
៦.២ ការរក្សាស្ថិតិសេដ្ឋកិច្ច និងសង្គម-ប្រជាសាស្ត្រសំខាន់ៗ ........ ២៧
៦.៣ ជំរឿន និងអង្កេត ........ ២៨
៦.៤ ការរក្សាបញ្ជីសហគ្រាស ........ ៣០
៦.៥ ប្រភពទិន្នន័យរដ្ឋបាល ........ ៣១
៦.៦ ការអភិវឌ្ឍប្រព័ន្ធសូចនាករ ........ ៣១
៦.៧ ការវិភាគ និងការរៀបចំរបាយការណ៍ ........ ៣២
៦.៨ ការផ្សព្វផ្សាយ ........ ៣២

**៧ គម្រោងថវិកា និងហិរញ្ញវត្ថុ ........ ៣៤**

**៨ ផែនការអនុវត្តន៍ ........ ៣៨**

៨.១ យន្តការដើម្បីអនុវត្តផែនការ និងការធ្វើបច្ចុប្បន្នភាពផែនការ ........ ៣៨
៨.២ ការត្រួតពិនិត្យ និងវាយតម្លៃ ........ ៣៨
៨.៣ ហានិភ័យ ........ ៣៩
៨.៤ និរន្តរភាព ........ ៣៩

## តារាង

១. កាលវិភាគបច្ចុប្បន្នកម្មជំរឿន និងអង្កេតគ្រួសារ ឆ្នាំ ២០០៨-២០១៥ យោងតាមការវាយតម្លៃពាក់កណ្តាលអាណត្តិផែនការមេស្ថិតិ ខែមិថុនា ឆ្នាំ២០១២ ........ ៣០
២. ប៉ាន់ស្មានចំណាយសម្រាប់ការផលិតស្ថិតិផ្លូវការនៅវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ........ ៣៦

## ឧបសម្ព័ន្ធ

១. ឧបសម្ព័ន្ធ១៖ ប្រភពព័ត៌មាន ........ ៤១
២. ឧបសម្ព័ន្ធ២៖ បញ្ជីសូចនាករសម្រាប់តាមដានត្រួតពិនិត្យ NSDP, MDGS និង ASEAN ........ ៤៤
៣. ឧបសម្ព័ន្ធ៣៖ ព័ត៌មានរបស់វិទ្យាស្ថានជាតិស្ថិតិ (សេចក្តីសង្ខេបអំពីកាប៉ាន់ប្រមាណថវិកា ........ ៥៨
៤. ឧបសម្ព័ន្ធ៤៖ ការអង្កេតនានាដែលបានធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ........ ៦០

# ពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| AusAid | ភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| BoP | ជញ្ជីញទូទាត់ |
| CAMinfo | ប្រព័ន្ធទិន្នន័យសូចនាករសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CDRI | វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា |
| CIPS | អង្កេតចន្លោះជំរឿនប្រជារាស្ត្រកម្ពុជា |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| COM | ទីស្តីការគណៈរដ្ឋមន្ត្រី |
| CPI | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ |
| CSES | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |
| DUSC | មជ្ឈមណ្ឌលសេវាកម្មអ្នកប្រើប្រាស់ទិន្នន័យ |
| EC | គណៈកម្មការអឺរ៉ុប |
| EMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ |
| GDDS | ប្រព័ន្ធផ្សព្វផ្សាយទិន្នន័យទូទៅ |
| GDP | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) |
| GRS | យុទ្ធសាស្ត្រចតុកោណរាជរដ្ឋាភិបាល |
| HMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| LFS | អង្កេតកំលាំងពលកម្ម |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MCFA | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MFA | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MONASRI | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច |

| | |
|---|---|
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOH | ក្រសួងសុខាភិបាល |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MOE | ក្រសួងបរិស្ថាន |
| MOF | ក្រសួងព័ត៌មាន |
| MOJ | ក្រសួងយុត្តិធម៌ |
| MOP | ក្រសួងផែនការ |
| MOSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MOT | ក្រសួងទេសចរណ៍ |
| MOWA | ក្រសួងកិច្ចការនារី |
| MPT | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRC | ក្រសួងធម្មការ និងសាសនា |
| MRD | ក្រសួង អភិវឌ្ឍន៍ជនបទ |
| MTR | ឯកសារពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| NBC | ធនាគារជាតិនៃកម្ពុជា |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) |
| NSS | ប្រព័ន្ធស្ថិតិជាតិ |
| NWG PM | ក្រុមការងារថ្នាក់ជាតិវាស់វែងភាពក្រីក្រ |
| PARIS21 | ភាពជាដៃគូស្ថិតិសម្រាប់សតវត្សទី២១ |
| PMG | ក្រុមបេសកកម្មកន្សោមអាទិភាព |
| POC | ចំណាយប្រតិបត្តិការអាទិភាព |
| PPI | សន្ទស្សន៍ថ្លៃផលិត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS | យុទ្ធសាស្ត្រចតុកោណ |
| SAC | ក្រុមប្រឹក្សាស្ថិតិ |
| SCA | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |
| SCC | គណៈកម្មាធិការសម្របសម្រួលស្ថិតិ |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SPF | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ |
| SDMX | ទិន្នន័យស្ថិតិ និងបំលាស់ប្តូរ មេតាដាតា (Metadata) |
| SDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ |

| | |
|---|---|
| SIda | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| SMP | ផែនការមេស្ថិតិ |
| TWG-PPR | ក្រុមការងារបច្ចេកទេសការធ្វើផែនការ និងកាត់បន្ថយភាពក្រីក្រ |
| UNDP | កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ |
| UNFPA | មូលនិធិប្រជាជនអង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |

# សេចក្តីសង្ខេបប្រតិបត្តិការ

ផែនការមេស្ថិតិឆ្នាំ ២០០៨-២០១៥ ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅឆ្នាំ ២០០៧ និងបានត្រួតពិនិត្យឡើងវិញនៅឆ្នាំ ២០១២។ ផែនការមេស្ថិតិ គឺជាផែនការរយៈពេលវែង សម្រាប់ប្រព័ន្ធស្ថិតិជាតិកម្ពុជា។ ផែនការនេះ គ្របដណ្តប់ប្រព័ន្ធស្ថិតិជាតិទាំងមូល ដោយរួមបញ្ចូលទាំងវិទ្យាស្ថានជាតិស្ថិតិ អង្គភាពស្ថិតិដែលបានចាត់តាំងនៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងធនាគារជាតិនៃកម្ពុជា។ផែនការមេស្ថិតិគឺជាគំហើញដ៏មានសារៈសំខាន់មួយដោយបង្ហាញនូវការពិពណ៌នាអំពីព័ត៌មានចាំបាច់ថាតើការអង្កេត និងជំរឿនអ្វីខ្លះ ដែលត្រូវយកធ្វើជាគោល។ ផែនការមេស្ថិតិក៏ចង្អុលបង្ហាញផងដែរ នូវភាពចាំបាច់ទាំងឡាយ ក្នុងការបំពេញស្ថិតិដោយសារតម្រូវការអ្នកប្រើប្រាស់ ពីព្រោះវាមានតម្លាតហិរញ្ញវត្ថុយ៉ាងធំ ក្នុងហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល។ ជារឿយៗ វាឆ្លុះបញ្ចាំងពីមហិច្ឆតាខ្ពស់ជាងអ្វីដែលធនធានមានកំណត់ទាំងមន្ត្រី និងហិរញ្ញវត្ថុអាចដោះស្រាយបាន។ ផែនការនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើការងារទាំងឡាយ ដែលមានពីមុនជាមូលដ្ឋាន និងរួមបញ្ចូលនូវការប៉ាន់ស្មានការចំណាយមួយចំនួនសម្រាប់ប្រព័ន្ធស្ថិតិជាតិ។

ផែនការមេស្ថិតិ គឺជាផែនការគ្រឹះសម្រាប់ប្រព័ន្ធស្ថិតិជាតិ។ មានការទទួលស្គាល់ផែនការមេស្ថិតិនេះយ៉ាងច្រើន ហើយត្រូវបានគេប្រើប្រាស់ជាឯកសារសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រផ្សេងៗ ដូចជាផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ និងនៅក្នុងចំណោមក្រសួង ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងអង្គការ ដៃគូអភិវឌ្ឍន៍មួយចំនួន។ ផែនការនេះ ក៏ដូចជាក្របខ័ណ្ឌការងារដែលពាក់ព័ន្ធ ត្រូវតែធ្វើឡើងជាបន្តបន្ទាប់ស្ថិតនៅក្នុងប្រព័ន្ធមួយ និងអ្នកពាក់ព័ន្ធទាំងឡាយ។

ផែនការមេស្ថិតិជាឯកសារទូទៅមួយ ត្រូវបានគេយកមកប្រើប្រាស់រួមគ្នា ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ដែលជាឯកសារគោលនយោបាយសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលត្រូវអនុវត្តតាម និងរៀបចំផែនការថាតើស្ថិតិអ្វីខ្លះត្រូវផលិតឡើង។ យោងទៅតាមតម្រូវការដែលមានការផ្លាស់ប្តូរចំពោះស្ថិតិទាំងក្នុង និងក្រៅប្រទេស ជាពិសេសទាក់ទងនឹង ផ.យ.អ.ជ និងការគិតពិចារណាថា ក្របខ័ណ្ឌការងារអាស៊ាននឹងមានឥទ្ធិពលខ្លាំងជាងមុនទៅលើប្រព័ន្ធស្ថិតិជាតិ នាពេលអនាគតដ៏ខ្លីនោះ ផែនការមេស្ថិតិដែលមានការត្រួតពិនិត្យឡើងវិញបច្ចុប្បន្ននេះ មានការដាក់បញ្ចូលនូវសូចនាកររបស់អាស៊ានទាំងអស់នោះ ជាផ្នែកមួយនៃផែនការនេះដែរ។ ព្រមជាមួយនេះ ក៏មានការផ្តល់អនុសាសន៍ផងដែរ សម្រាប់ផែនការមេនេះដើម្បីធ្វើការដាក់បញ្ចូលជាផ្នែកមួយនៃ ផ.យ.អ.ជ ការរៀបចំផែនការយុទ្ធសាស្ត្រ ស្ថាប័ន និងរបាយការណ៍ប្រចាំឆ្នាំ នៃប្រព័ន្ធស្ថិតិជាតិដើម្បីបញ្ចូលជាផ្នែកមួយ នៃប្រព័ន្ធសម្រាប់ធ្វើផែនការ និងការតាមដានបន្ត។

របាយការណ៍ត្រួតពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិផែនការមេស្ថិតិនេះ ត្រូវបានរៀបចំឡើងក្នុងឆ្នាំ ២០១២ ដែលជាផ្នែកមួយនៃគម្រោងបន្ត ស្ដីពីការកសាងសមត្ថភាពស្ថាប័ននៅវិទ្យាស្ថានជាតិស្ថិតិ ដែលមានការជួយឧបត្ថម្ភពីអង្គការ Sida។ គោលបំណងរួម គឺដើម្បីពិនិត្យឡើងវិញ និងធ្វើការវាយតម្លៃសកម្មភាពនានាដែលស្ថិតនៅក្រោមផែនការមេនេះ រួមជាមួយការវាយតម្លៃអំពីសកម្មភាពរៀបចំការអនុវត្ត និងថាតើសកម្មភាពទាំងអស់នេះ កំពុងរួមចំណែកដល់ការអនុវត្តផែនការមេនេះយ៉ាងដូចម្ដេច។ ការងារនេះពាក់ព័ន្ធជាមួយអ្នកផលិតទិន្នន័យ អ្នកប្រើប្រាស់ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងក្រុមការងារបច្ចេកទេសផែនការ និងកាត់បន្ថយភាពក្រីក្រ ដែលជាអនុក្រុមចំណុះឱ្យវិទ្យាស្ថានជាតិស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។ មានការធ្វើបទបង្ហាញសេចក្ដីព្រាងចុងក្រោយ នៃរបាយកាណ៍ពាក់កណ្ដាលអាណត្តិផែនការមេស្ថិតិនេះ តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាស្ថិតិកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២។

តាមរយៈការធ្វើបទបង្ហាញផែនការមេស្ថិតិនេះ មានការផ្ដល់អនុសាសន៍ឱ្យមានការពង្រឹងសមត្ថភាពរបស់ប្រព័ន្ធស្ថិតិជាតិក្នុងការផលិតស្ថិតិផ្លូវការ ជាពិសេស តួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិត្រូវតែធ្វើការពង្រឹងតាមរយៈការផ្ដល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាព។ ការផ្ដល់មូលនិធិពេញលេញពីរាជរដ្ឋាភិបាលសម្រាប់ស្ថិតិផ្លូវការ នឹងធានានូវប្រព័ន្ធស្ថិតិជាតិប្រកបដោយនិរន្តរភាព។ ដរាបណាការផ្ដល់ហិរញ្ញប្បទានភាគច្រើនរបស់ប្រព័ន្ធស្ថិតិជាតិ ធ្វើឡើងដោយម្ចាស់ជំនួយនោះ ជំរឿនមួយចំនួន ដូចជាជំរឿនកសិកម្ម និងអង្កេតទាំងឡាយ នឹងត្រូវបានគេធ្វើឡើងសម្រាប់តែក្នុងគោលបំណងពិសេសប៉ុណ្ណោះ។ ប្រព័ន្ធស្ថិតិផ្លូវការពិតជាមានសារៈសំខាន់ ដូចប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាតិដទៃទៀតដែរ។ ស្ថិតិផ្លូវការប្រកបដោយគុណភាពខ្ពស់ គឺសម្រាប់ប្រទេសជាតិមួយដែលមានសារៈសំខាន់ដូចគ្នានឹងគណនីសម្រាប់ក្រុមហ៊ុនមួយដែរ។ គម្លាតនៃការផ្ដល់មូលនិធិនាពេលបច្ចុប្បន្នមានសភាពធំធេង ហើយដើម្បីរក្សាប្រព័ន្ធស្ថិតិផ្លូវការ ប្រកបដោយនិរន្តរភាព គឺត្រូវតែមានការផ្លាស់ប្ដូរនៅក្នុងប្រព័ន្ធហិរញ្ញប្បទាន។ គម្លាតក្នុងការផ្ដល់មូលនិធិនាពេលបច្ចុប្បន្ន គឺប្រហែល ២/៣ នៃថវិកាដែលមានការប្រមាណទុកសម្រាប់ស្ថិតិ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១១។ សម្រាប់ស្ថិតិដែលមានការផលិតឡើងកំឡុងឆ្នាំ ២០០៩-២០១១ ការផ្ដល់មូលនិធិរបស់រាជរដ្ឋាភិបាលបានកើនឡើងពី ១/៥ ដល់ ១/៣ សម្រាប់វិទ្យាស្ថានជាតិស្ថិតិ។ ថវិកានៅសល់ត្រូវបានផ្ដល់ដោយដៃគូអភិវឌ្ឍន៍ផ្សេងៗ។ នៅពេលមានការផ្ដល់មូលនិធិសម្រាប់តម្រូវការទាំងស្រុងដែលប្រព័ន្ធស្ថិតិជាតិត្រូវការចំណែកថវិកាផ្ដល់ដោយរាជរដ្ឋាភិបាលមានតិចជាង។ ជំហានដ៏ល្អមួយនៅពេលខាងមុខគឺការសម្រេចចិត្តដើម្បីគាំទ្រផ្នែកហិរញ្ញវត្ថុ ដែលជាផ្នែកមួយដ៏មានសារៈសំខាន់នៃការធ្វើជំរឿនកសិកម្មឆ្នាំ ២០១៣។

ក្របខ័ណ្ឌច្បាប់ដូចជាច្បាប់ស្ដីពីស្ថិតិ និងអនុក្រឹត្យនានា ផ្ដល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ដើម្បីធ្វើឱ្យប្រព័ន្ធស្ថិតិជាតិមានដំណើរការល្អ។ ទោះបីជាយ៉ាងណាក៏ដោយមានផ្នែកខ្លះៗ នៃក្របខ័ណ្ឌ

ច្បាប់ដែលអាចធ្វើឱ្យប្រសើរឡើង។ ក្របខ័ណ្ឌការងារនេះ ត្រូវតែគាំទ្រដំណើរការការងារឱ្យបានពេញលេញ និងត្រូវបង្ហាញឱ្យច្បាស់ពីការទទួលខុសត្រូវ។ អាស្រ័យហេតុនេះ មានការផ្តល់ជាអនុសាសន៍សម្រាប់អនុក្រឹត្យទាំងឡាយ ឱ្យមានការពិនិត្យសារឡើងវិញ ដើម្បីពង្រឹងក្របខ័ណ្ឌនេះឱ្យកាន់តែប្រសើរឡើង។ ការត្រួតពិនិត្យឡើងវិញនេះត្រូវពិនិត្យមើលពីភាពច្បាស់លាស់ និងការយល់ដឹងនៅពេលមានការអនុលោមនូវច្បាប់ និងអនុក្រឹត្យ ដោយយោងទៅតាមទំនួលខុសត្រូវលក្ខខណ្ឌ និងនិយមន័យ កម្រិតព័ត៌មានលម្អិត ហើយនិងថាតើមានការបាត់បង់ផ្នែកសំខាន់ណាខ្លះឬទេ។ ក្រោយមានការអនុវត្តជាច្រើនមក ច្បាប់ស្ថិតិក៏អាចធ្វើវិសោធនកម្មផងដែរ។

របាយការណ៍ពាក់កណ្តាលអាណត្តិនេះ បង្ហាញពីសមិទ្ធផលដ៏ជោគជ័យទាំងឡាយ ប៉ុន្តែវាក៏បង្ហាញផងដែរថាមានចំណុចខ្សោយចំបងៗមួយចំនួនដែលត្រូវដោះស្រាយតាំងពីដំបូងនោះនៅតែកើតឡើងដដែល។ សកម្មភាពរៀបចំស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធមានលក្ខណៈគ្រប់គ្រាន់តាមរបៀបខ្លះ ប៉ុន្តែតាមរបៀបផ្សេងទៀតគឺនៅមិនទាន់គ្រប់គ្រាន់នៅឡើយ។ ឧទាហរណ៍ គឺកង្វះខាតឯករាជ្យភាព និងស្វយ័តភាពនៃមូលនិធិ និងថវិកាសម្រាប់វិទ្យាស្ថានជាតិស្ថិតិ និងស្ថិតិផ្លូវការ។ ប្រព័ន្ធទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ អ្នកប្រើប្រាស់ និងអ្នកផលិតស្ថិតិសម្រាប់ការធ្វើផែនការ និងការតាមដាន និងសម្រាប់ការសម្របសម្រួល និងការរៀបចំ ការពិគ្រោះយោបល់ត្រូវតែពង្រឹង ដើម្បីឱ្យប្រព័ន្ធស្ថិតិជាតិក្លាយជាប្រព័ន្ធវិមជ្ឈការដ៏មានប្រសិទ្ធភាព។ វាមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការអនុវត្តប្រព័ន្ធមួយក្នុងការគណនាការចំណាយសម្រាប់ការផលិតស្ថិតិក្នុងប្រព័ន្ធវិមជ្ឈការ ដើម្បីឱ្យមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការផ្តល់អាទិភាព និងការប្រើប្រាស់ធនធានដ៏មានប្រសិទ្ធភាព។

កត្តាយុទ្ធសាស្ត្រក្នុងការបង្កើនគុណភាពផ្នែកស្ថិតិតាមរយៈការដាក់ឱ្យប្រើប្រាស់នូវក្រមសីលធម៌ក្នុងការផលិតស្ថិតិ គឺត្រូវតែបន្ត ហើយក៏ត្រូវធ្វើដូចគ្នានេះដែរ សម្រាប់ការបណ្តុះបណ្តាល និងការណែនាំឱ្យប្រើប្រាស់អំពីបទដ្ឋានចំណាត់ថ្នាក់ និងនីតិវិធីការងារជាស្តង់ដារ។ ការងារនេះ ត្រូវតែបន្ត និងពង្រីកដើម្បីរួមបញ្ចូលនូវសូចនាករទាំងឡាយប្រកបដោយស្តង់ដារ និងដំណើរការល្អជាមួយនឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ព្រមទាំងការប្រើប្រាស់ដែលកាន់តែកើនឡើង នៃផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង។ កំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ មានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការពង្រឹងការផលិតស្ថិតិតាមរយៈការបណ្តុះបណ្តាល និងជំនួយបច្ចេកទេស និងក្នុងការគ្រប់គ្រង។ នៅតែមានគម្លាតដ៏ធំរវាងកម្រិតជំនាញ និងបច្ចេកវិទ្យាដែលត្រូវយកមកប្រើប្រាស់ និងត្រូវការចាំបាច់សម្រាប់ការផលិតស្ថិតិ ប្រកបដោយនិរន្តរភាព និងសម្រាប់វិទ្យាស្ថានជាតិស្ថិតិក្នុងការបំពេញនូវតួនាទីរបស់ខ្លួន ដែលជាមណ្ឌលកសាងសមត្ថភាពក្នុងការផលិតស្ថិតិ។ សមត្ថភាពនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការផលិតស្ថិតិផ្លូវការនៅតែមានកម្រិតទាបជាង បើប្រៀបធៀបជាមួយនឹងវិទ្យាស្ថានជាតិស្ថិតិ។ ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន

ទទួលបានជំនួយផ្នែកបច្ចេកទេស និងធនធានគ្រប់គ្រាន់ដើម្បីផលិតស្ថិតិ។ នៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត មានការិយាល័យជាច្រើន កំពុងធ្វើការងាររបស់ខ្លួនជាមួយនឹងការផលិតស្ថិតិដោយគ្មានការសម្របសម្រួលឱ្យបានសមរម្យ ក្នុងក្របខ័ណ្ឌក្រសួង ឬជាមួយវិទ្យាស្ថានជាតិស្ថិតិនៅឡើយ។ ដើម្បីបំពេញគម្លាតទាំងនេះ ត្រូវមានការផ្តល់មូលនិធិឱ្យបានគ្រប់គ្រាន់ និងប្រកបដោយនិរន្តរភាព និងកត្តាមួយត្រូវយកមកដោះស្រាយ គឺថាតើប្រព័ន្ធមជ្ឈការសម្រាប់ការផលិតស្ថិតិផ្លូវការអាចទទួលបានការធ្វើសុខដុមនីយកម្ម និងមានប្រសិទ្ធភាពច្រើនជាងមុន ឬយ៉ាងណា។ ឧទាហរណ៍ បញ្ហាអំពីការធ្វើមជ្ឈការអាចចាប់យកពីរបៀបក្នុងការរៀបចំប្រព័ន្ធស្ថិតិជាតិ និងរបៀបក្នុងការសម្របសម្រួលជាមួយអង្គភាពស្ថិតិដែលបានចាត់តាំងនៅថ្នាក់ជាតិ និង/ឬជាមួយការិយាល័យនៅថ្នាក់ខេត្ត ហើយនិងហេតុផលដើម្បីធ្វើការអង្កេត។

សមាសភាពសំខាន់ៗនៃការកសាងសមត្ថភាពស្ថិតិ គឺការបណ្តុះបណ្តាល និងកម្រិតនៃប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការ។ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធស្ថិតិជាតិ ទោះបីជាបញ្ហាប្រាក់បៀវត្សរ៍ គឺជាបញ្ហាដែលពិបាកសម្រាប់រាជរដ្ឋាភិបាលក្នុងការដោះស្រាយក៏ដោយ តែត្រូវតែមានដំណោះស្រាយ ហើយមន្ត្រីរាជការដែលធ្វើការនៅវិទ្យាស្ថានស្ថិតិជាតិ និងអង្គភាពស្ថិតិផ្សេងទៀតត្រូវតែមានការផ្តល់ជាពិសេសនូវប្រាក់បៀវត្សរ៍/ប្រាក់ឧបត្ថម្ភ ដើម្បីឱ្យពួកគេអាចផ្តោតទៅលើការងាររាជការ ហើយមិនឆ្លៀតធ្វើការងារខាងក្រៅបន្ថែម។ លទ្ធផលនៃការបណ្តុះបណ្តាលត្រូវមានការសម្របសម្រួល ដើម្បីសម្រេចបាននូវគោលបំណងរួម នៃការកសាងសមត្ថភាពប្រកបដោយនិរន្តរភាពរបស់ប្រព័ន្ធស្ថិតិជាតិ។

មានការរីកចម្រើនយ៉ាងខ្លាំង ក្នុងការផ្សព្វផ្សាយស្ថិតិ តាមរយៈការបោះពុម្ពជារបាយការណ៍ និងនៅលើគេហទំព័រ។ នាពេលបច្ចុប្បន្ននេះ គេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិបង្ហាញលទ្ធផលភាគច្រើនបំផុតចេញពីការអង្កេតផ្សេងៗ ហើយអ្នកប្រើប្រាស់ អាចទាញយកទិន្នន័យពីគេហទំព័រដោយផ្ទាល់ ដូចជាជំរឿនប្រជាពលរដ្ឋ និងប្រព័ន្ធទិន្នន័យសូចនាករសេដ្ឋកិច្ចសង្គមសេដ្ឋកិច្ចកម្ពុជាជាដើម។ ទោះយ៉ាងណាក៏ដោយ នៅមានចំណុចកែលម្អជាច្រើន ដែលត្រូវធ្វើនៅក្នុងវិស័យនេះ។តាមបទពិសោធន៍កន្លងមកការផ្សព្វផ្សាយ និងការយល់ដឹងពីស្ថិតិដែលមានការកើនឡើង បង្កើនការប្រើប្រាស់ និងផលប្រយោជន៍ទិន្នន័យ ព្រមទាំងសូចនាករទាំងឡាយ។ ដើម្បីផ្តល់អាទិភាព និងមានលទ្ធភាពផលិតនូវស្ថិតិចាំបាច់ និងប្រើប្រាស់ឱ្យបានច្រើនបំផុត ទាមទារឱ្យមានចំណេះដឹងច្រើនពីផលប្រយោជន៍របស់ទិន្នន័យ និងសូចនាករទាំងឡាយ។

ការពិតនោះគឺថា គ្មានកិច្ចព្រមព្រៀងឱ្យបានទូលំទូលាយ អំពីការចាត់ចំណាត់ថ្នាក់ជាអាទិភាពនៃសកម្មភាពស្ថិតិនៅឡើយ នៅក្នុងផែនការមេស្ថិតិនាពេលបច្ចុប្បន្ននេះ។ នៅតាមក្រសួងពាក់ព័ន្ធនានា អាទិភាពនៃការផលិតស្ថិតិ គឺអាស្រ័យភាគច្រើនទៅលើការធ្វើផែនការរបស់ក្រសួង

ស្ថាប័ននីមួយៗ ដោយឆ្លើយតបនឹង ផ.យ.អ.ជ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និង/ឬគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ទោះបីជាស្ថិតិតម្រូវឱ្យមានភាគច្រើន ដោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការមេស្ថិតិ កិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូល និងផ្តល់របាយការណ៍ស្តីពីសូចនាកររបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ទទួលបានជោគជ័យ ដោយសារតែការបញ្ចូលក្របខ័ណ្ឌការងារត្រួតពិនិត្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ទៅក្នុងការវាយតម្លៃគោលនយោបាយជាតិ ជាពិសេស តាមរយៈការតាមដានត្រួតពិនិត្យរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

យើងសង្កេតឃើញថា មានគុណសម្បត្តិយ៉ាងធំធេងចេញពីជំរឿន និងអង្កេតទ្រង់ទ្រាយធំ។ ចាប់តាំងពីឆ្នាំ ២០០៧ មក ជំរឿនប្រជាពស្ត្រឆ្នាំ ២០០៨ និងជំរឿនសហគ្រាសឆ្នាំ ២០១១ ត្រូវបានរៀបចំធ្វើឡើង ជាពិសេសដោយមានការផ្តល់មូលនិធិពីដៃគូអភិវឌ្ឍន៍។ ជំរឿនកសិកម្មត្រូវបានគ្រោងធ្វើក្នុងឆ្នាំ ២០១៣។ រាជរដ្ឋាភិបាលកម្ពុជាកំពុងបង្កើនមូលនិធិទៅឱ្យការធ្វើជំរឿនទាំងឡាយ។ ប៉ុន្តែការផ្តល់មូលនិធិបន្ថែមពីរាជរដ្ឋាភិបាល ទាមទារឱ្យមានការបង្កើតនូវប្រព័ន្ធស្ថិតិមួយ ប្រកបដោយនិរន្តរភាព។ អាទិភាពខ្ពស់បំផុតសម្រាប់ប្រព័ន្ធស្ថិតិជាតិ គឺការការពារ និងថែរក្សាស្ថិតិសេដ្ឋកិច្ច និងសង្គមប្រជាសាស្ត្រ ដែលមានស្រាប់ និងការកែលម្អគុណភាពព្រមទាំងពេលវេលាដ៏សមរម្យដើម្បីទទួលបានលទ្ធផល។ សកម្មភាពបន្ថែមខ្លះទៀត ត្រូវរួមបញ្ចូលជាអាទិភាពខ្ពស់ ដើម្បីធ្វើការកែលម្អគុណភាព និងបំពេញគម្លាតនៅក្នុងលទ្ធផលអាទិភាពមួយចំនួន។ ស្ថិតិអាទិភាពរួមមានការប្រមូលទិន្នន័យសម្រាប់ចងក្រងគណនេយ្យជាតិ ប្រចាំត្រីមាស និងប្រចាំឆ្នាំ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ សន្ទស្សន៍ថ្លៃទំនិញកសិកម្ម និងអ្នកផលិត សន្ទស្សន៍ផលិតកម្មកសិកម្ម និងឧស្សាហកម្ម និងការលក់រាយ និងស្ថិតិកំលាំងពលកម្ម ព្រមទាំងសន្ទស្សន៍ការចំណាយលើកំលាំងពលកម្ម។ ហើយក៏មានការរួមបញ្ចូលផងដែរនូវស្ថិតិផលិតកម្ម កសិកម្ម និងស្ថិតិដំណាំ បសុសត្វ និងនេសាទ ស្ថិតិសុខាភិបាល ទីផ្សារពលកម្ម និងទេសចរណ៍ និងវិធានការកាត់បន្ថយភាពក្រីក្រនិងប្រជាសាស្ត្រ និងឱកាសប្រើប្រាស់សម្ភារៈផ្សេងៗជាមូលដ្ឋាន។ កំឡុងពេលមានផែនការមេស្ថិតិជំនួយខាងក្រៅអាចសង្កត់ធ្ងន់កាន់តែច្រើន ទៅលើសកម្មភាពអភិវឌ្ឍន៍ សកម្មភាពកែលម្អ និងសកម្មភាពថ្មីៗ ដែលពុំមាននៅក្នុងបញ្ជីអាទិភាពនាពេលបច្ចុប្បន្ន ប៉ុន្តែវាមានតម្លៃដ៏ធំធេងសម្រាប់គុណភាពស្ថិតិ និងការកត់ចូលបញ្ជី (Registers) និងសម្រាប់ឱកាសក្នុងការបំពេញតាមតម្រូវការនាពេលអនាគត។

ការប្រើប្រាស់ស្ថិតិកំពុងមានការកើនឡើង ដោយសារមានការផ្លាស់ប្តូរតម្រូវការរបស់អ្នកប្រើប្រាស់គុណភាពកើនឡើង និងចំណេះដឹងស្ថិតិតាមរយៈការប្រើប្រាស់ និងប្រព័ន្ធមុខងារដ៏ប្រសើរក្នុងការផ្សព្វផ្សាយ។ ការងារបន្ថែមទៀត វាមានសារៈសំខាន់ណាស់ ដើម្បីបន្តបង្កើនចំណេះដឹងនៃផែនការមេស្ថិតិ ក្នុងចំណោមអ្នកប្រើប្រាស់ អ្នកផលិត និងអ្នកពាក់ព័ន្ធ ព្រមទាំង

សាធារណជន។ វាអាចកើតមានឡើងតាមរយៈការអនុវត្តយុទ្ធសាស្ត្រសម្រាប់ការផ្សាភ្ជាប់ផលិតកម្មស្ថិតិផ្លូវការ និងការផ្សព្វផ្សាយ។ វាក៏មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីបង្កើតប្រព័ន្ធទាំងឡាយ សម្រាប់ធ្វើការទំនាក់ទំនងរវាងរាជរដ្ឋាភិបាល វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងស្ថាប័នពាក់ព័ន្ធនានា ដែលជាអ្នកប្រើប្រាស់ និងអ្នកផលិត និងអ្នកប្រើប្រាស់ផ្សេងៗទៀត។ ប្រព័ន្ធមួយអាចរួមមានកិច្ចប្រជុំ និងសិក្ខាសាលាទាំងឡាយធ្វើរួមជាមួយអ្នកប្រើប្រាស់ ដើម្បីកំណត់ពីតម្រូវការស្ថិតិ និងសេចក្តីណែនាំអំពីរបៀបណា ដែលប្រព័ន្ធនេះត្រូវបានផ្តល់អាទិភាព និងផ្តល់ហិរញ្ញវត្ថុ និងប្រព័ន្ធមួយផ្សេងទៀត គឺទាក់ទងនឹងរាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការពិភាក្សាពីការផ្តល់អាទិភាព និងផ្តល់ហិរញ្ញវត្ថុដល់តម្រូវការដែលមានការកំណត់នៃស្ថិតិផ្លូវការ។ មធ្យោបាយមួយនៃការពង្រឹងការផ្តល់មូលនិធិ គឺការធ្វើឱ្យប្រសើរនិងសម្របសម្រួលឱ្យមានការផ្តល់មូលនិធិពីអ្នកពាក់ព័ន្ធផ្សេងៗគ្នា ឧទាហរណ៍ តាមរយៈវិធីសាស្ត្រដោយផ្អែកលើកម្មវិធីមួយ ឬការផ្តល់មូលនិធិជាកញ្ចប់។

ដើម្បីទទួលបានតម្លៃប៉ាន់ប្រមាណបច្ចុប្បន្នច្រើនជាងនេះ អំពីធនធានហិរញ្ញវត្ថុដែលត្រូវការសម្រាប់ស្ថិតិផ្លូវការនៅក្នុងប្រទេសកម្ពុជា គំរូមួយបានត្រូវរៀបចំឡើងសម្រាប់ឯកសារនេះ។ គំរូនេះ អាស្រ័យលើទិន្នន័យដែលមាន អំពីតម្លៃចំណាយដែលមានការរាយការណ៍បានមកពីវិទ្យាស្ថានជាតិស្ថិតិ ក្រសួងពាក់ព័ន្ធ និងការិយាល័យដែលបានចាត់តាំងដែលត្រូវបានតែងតាំងតាមអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង និងស្ថាប័នរាជរដ្ឋាភិបាលផ្សេងៗទៀត ដែលមានការផលិតស្ថិតិ។ គំរូនេះប្រើប្រាស់ទិន្នន័យតាមការរាយការណ៍ពីតម្លៃចំណាយ និងចំនួនមន្ត្រីនៅក្នុងការផលិតស្ថិតិ ដើម្បីគណនាទិន្នន័យលើប្រាក់បៀវត្ស។ នៅពេលមានការបាត់បង់ទិន្នន័យ ទិន្នន័យបានមកពីផែនការមេស្ថិតិត្រូវបានយកមកប្រើប្រាស់។ ការប៉ាន់ស្មានចំណាយឆ្នាំ ២០១១ សម្រាប់ប្រព័ន្ធស្ថិតិជាតិ គឺប្រហែល ៨.៥ លានដុល្លារសហរដ្ឋអាមេរិក។ ការផ្តល់មូលនិធិសម្រាប់ទីប្រឹក្សាអន្តរជាតិ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃប៉ាន់ប្រមាណសម្រាប់ ឆ្នាំ ២០១១ ហើយផ្នែកនោះនឹងថយចុះប្រហែល ៥០ ភាគរយ នៅពេលដែលការផ្តល់មូលនិធិរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានកាត់ផ្តាច់។

លទ្ធផលខ្លះៗ នៅក្នុងចំណោមលទ្ធផលដែលបានរកឃើញ នៅក្នុងរបាយការណ៍នេះ នឹងត្រូវគេប្រើប្រាស់ ក្នុងការរៀបចំផែនការមេឆ្នាំ ២០១៦ បន្ទាប់ និងនៅដំណាក់កាលបន្តបន្ទាប់ផ្សេងទៀត។ មានការផ្តល់អនុសាសន៍ថា ការធ្វើផែនការត្រូវចាប់ផ្តើមកំឡុងឆ្នាំ ២០១៣ ឬយ៉ាងហោចណាស់នៅដើមឆ្នាំ២០១៤។

# ផ្នែកទី១. ស្ថានភាព និងការវាយតម្លៃនាពេលបច្ចុប្បន្ន

## ១. ប្រវត្តិសង្ខេប និងដំណើរការ

### ១.១ ផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា

យុទ្ធសាស្ត្រចតុកោណដើម្បីជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព ត្រូវបានប្រកាសកាលពីឆ្នាំ ២០០៤ និងចង្អុលទិសពីការអនុវត្តរបៀបវារៈគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា។ អភិបាលកិច្ចល្អ គឺជាស្នូលនៅក្នុងយុទ្ធសាស្ត្រចតុកោណ ហើយព័ត៌មានស្ថិតិប្រកបដោយគុណភាព នឹងផ្តល់នូវលទ្ធភាពឱ្យមានការតាមដានត្រួតពិនិត្យរាល់សកម្មភាពដែលគ្រប់គ្រងដោយរាជរដ្ឋាភិបាល ដែលនឹងមានសារៈសំខាន់ ក្នុងការធ្វើឱ្យប្រសើរនូវបទដ្ឋានអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា។ ផ្នែកផ្សេងៗទៀតនៃយុទ្ធសាស្ត្រចតុកោណនេះ គឺការលើកស្ទួយកំណើនសេដ្ឋកិច្ចតាមរយៈការអភិវឌ្ឍវិស័យកសិកម្ម ការស្តារនីតិសម្បទា និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍវិស័យឯកជន និងការកសាងសមត្ថភាព ព្រមទាំងការអភិវឌ្ឍធនធានមនុស្ស។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ត្រូវបានប្រកាសជាការឆ្លើយតបចាប់តាំងពីមានវិបត្តិហិរញ្ញវត្ថុ និងការធ្លាក់ចុះសេដ្ឋកិច្ចសាកល ដើម្បីកម្ពុជាធ្វើការត្រៀមខ្លួនក្នុងការប្រឈមនឹងបញ្ហាទាំងអស់នេះ។

ផ.យ.អ.ជ ត្រូវបានរៀបចំឡើងជាឯកសារផែនការមួយ សម្រាប់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តទស្សនវិស័យ ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ បន្ទាប់ពីយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ត្រូវបានប្រកាសឡើង ការធ្វើបច្ចុប្បន្នភាពនៃ ផ.យ.អ.ជ ក៏ត្រូវបានរៀបចំឡើងផងដែរ។ ផ.យ.អ.ជ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ផ្តោតសំខាន់ទៅលើភាពស៊ីសង្វាក់គ្នានូវរយៈវេលារវាង ផ.យ.អ.ជ បច្ចុប្បន្នកម្ម និងអាណត្តិទី៤ របស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីធានានូវការអនុវត្តរាល់សកម្មភាព កម្មវិធី និងគម្រោងនានា ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។ ផ.យ.អ.ជ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ផ្តោតការយកចិត្តទុកដាក់ទៅលើផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចសាកលមកលើសេដ្ឋកិច្ចកម្ពុជា។

សូចនាករនៅក្នុង ផ.យ.អ.ជ គឺជាកត្តាកំណត់ព័ត៌មានដ៏សំខាន់ ដើម្បីពិពណ៌នាពីស្ថានភាពបច្ចុប្បន្ន និងមធ្យោបាយក្នុងការអភិវឌ្ឍសង្គមកម្ពុជា ស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ បច្ចុប្បន្ននេះ សូចនាករថ្មីសម្រាប់តាមដានត្រួតពិនិត្យវឌ្ឍនភាព ត្រូវបានពង្រីកបន្ថែម បន្ទាប់ពីរបាយការណ៍ពាក់កណ្តាលអាណត្តិស្តីពីការអនុវត្ត ផ.យ.អ.ជ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបានរៀបចំឡើង។

ស្ថិតិដែលមានការសម្របសម្រួល និងសូចនាករដែលមានគុណភាពខ្ពស់ គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់អ្នកធ្វើនយោបាយ នៅពេលឈានដល់ការដឹកនាំឱ្យមានកំណើនប្រកបដោយនិរន្តរភាព និងសុខមាលភាពសម្រាប់សង្គមកម្ពុជា។ ផែនការមេស្ថិតិ គឺលទ្ធផលរកឃើញដ៏មានសារៈសំខាន់ នៅពេលមានការពិពណ៌នាពីព័ត៌មានចាំបាច់ និងចង្អុលបង្ហាញថាតើឧបករណ៍អង្កេត និងជំរឿនណាខ្លះដែលត្រូវយកមកប្រើប្រាស់។ ផែនការមេស្ថិតិនេះ ក៏ចង្អុលបង្ហាញផងដែរពីកំហិត ក្នុង ការបំពេញស្ថិតិតាមផែនការដាក់ចុះ យោងទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ ពីព្រោះមាននូវគម្លាតផ្នែកហិរញ្ញប្បទានដ៏ធំ ក្នុងការផ្ដល់មូលនិធិរបស់រាជរដ្ឋាភិបាល។

តួអង្គដ៏សំខាន់នៅក្នុងប្រព័ន្ធស្ថិតិជាតិ គឺវិទ្យាស្ថានជាតិស្ថិតិ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងធានាគារជាតិនៃកម្ពុជា។ ស្ថាប័នទាំងអស់នេះ ដោយអនុលោមតាមអនុក្រឹត្យស្ដីពីស្ថិតិផ្លូវការដែលបានចាត់តាំង គឺជាអ្នកផលិតស្ថិតិផ្លូវការដែលបានចាត់តាំង។ ក្រសួងខ្លះរៀបចំផែនការរយៈពេល ៥ ឆ្នាំ សម្រាប់ការងាររបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ ផែនការនេះឆ្លុះបញ្ចាំងពីមហិច្ឆតាខ្ពស់ជាងអ្វីដែលធនធានកំណត់ ទាំងមន្ត្រី និងហិរញ្ញវត្ថុអាចដោះស្រាយបាន។ មានការសម្របសម្រួលដែលមានការកំណត់មួយរវាងផែនការរយៈពេលវែង និងរយៈពេលខ្លីរបស់ក្រសួងពាក់ព័ន្ធរៀងៗខ្លួន។ បញ្ហាទាំងនេះត្រូវមានការកែលម្អ ដើម្បីផលិតបាននូវស្ថិតិដោយការប្រើប្រាស់ធនធានដែលមានប្រសិទ្ធភាពជាងមុន។

ក្រសួងផែនការទទួលខុសត្រូវនូវ ផ.យ.អ.ជ និងដោយឡែកវិទ្យាស្ថានជាតិស្ថិតិ ទទួលខុសត្រូវសម្រាប់ស្ថិតិក្នុងការតាមដានប្រចាំឆ្នាំ។ របាយការណ៍តាមដានត្រូវគ្រោងបោះពុម្ពនៅខែកក្កដា ឆ្នាំ ២០១២ នេះ។ របាយការណ៍នេះ នឹងក្លាយជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ទាំងឡាយសម្រាប់ធ្វើផែនការនូវធនធានបន្តដើម្បីផលិតស្ថិតិផ្លូវការ។

## ១.២ សកម្មភាពអភិវឌ្ឍន៍ស្ថិតិ

កិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូល ការប៉ាន់ស្មាន និងរាយការណ៍ពីសូចនាករគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទទួលបានជោគជ័យ ដោយសារមានការដាក់បញ្ចូលនូវក្របខ័ណ្ឌការងារតាមដានត្រួតពិនិត្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ចូលទៅក្នុងការតាមដានវាយតម្លៃគោលនយោបាយជាតិ ជាពិសេសតាមរយៈការតាមដានត្រួតពិនិត្យយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ នៅថ្នាក់ជាតិសូចនាករគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ច្រើនជាង ២/៣ មានចំណុចទិន្នន័យយ៉ាងហោចណាស់ចំនួនពីរ ចន្លោះឆ្នាំ ១៩៩៩ និង ២០១១។ នៅថ្នាក់អន្តរជាតិទោះជាយ៉ាងណាក៏ដោយកម្រិតដែលមាននេះគឺទាបជាង។បន្ទាប់ពីការអង្កេតចន្លោះជំរឿនប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៤ ត្រូវបានចេញផ្សាយមក វិទ្យាស្ថានជាតិស្ថិតិបានធ្វើជំរឿនប្រជារាស្ត្រឆ្នាំ ២០០៨ ដែលយកមកប្រើ

ប្រាស់យ៉ាងទូលំទូលាយ ក្នុងការតាមដានត្រួតពិនិត្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ បន្ថែមជាងនេះទៀត អង្កេតសុខភាព និងប្រជាសាស្ត្រកម្ពុជាក្នុងឆ្នាំ ២០០០ ២០០៥ និង ២០១០ ផ្តល់នូវឱកាសដ៏ល្អសម្រាប់អ្នកបង្កើតគោលនយោបាយ ដើម្បីត្រួតពិនិត្យមើលពីការរីកចម្រើនយោងទៅតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាត្រូវបានធ្វើឡើងកាលពីឆ្នាំ ២០០៤ និងចាប់តាំងពីឆ្នាំ ២០០៧ មក ត្រូវបានធ្វើឡើងប្រចាំឆ្នាំ។ ផ.យ.អ.ជ ប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា សម្រាប់ការតាមដានត្រួតពិនិត្យប្រចាំឆ្នាំ ហើយទិន្នន័យរបស់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា នឹងត្រូវគេប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់ការគណនាពីបន្ទាត់ភាពក្រីក្រ។ ជាលទ្ធផល វិធានការទំនើបច្រើនជាងមុននៃសូចនាករ ផ.យ.អ.ជ អាច រកបានសម្រាប់អ្នកប្រើប្រាស់ទិន្នន័យនាពេលបច្ចុប្បន្ននេះ។

ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៧ ហើយវាមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការគាំទ្រដំណើរការអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ និងជំនួយក្នុងការសម្របសម្រួលបច្ចេកទេសនៃស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចាប់តាំងពីបានបង្កើតឡើង ក្រុមប្រឹក្សាស្ថិតិបានប្រជុំចំនួន៣លើក និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ បានប្រជុំចំនួន១១លើក ។

## ១.៣ ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍

វិទ្យាស្ថានជាតិស្ថិតិបានធ្វើការពិនិត្យឡើងវិញជាបន្តបន្ទាប់ ដើម្បីដោះស្រាយបញ្ហាស្ថាប័ន និងការរៀបចំនានា សម្រាប់ផែនការមេស្ថិតិ ដែលបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០០៧។ ផែនការនានា និងសូចនាករមួយចំនួនត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពចាប់តាំងពីផែនការមេស្ថិតិនេះត្រូវបានរៀបចំឡើង។ ការពិនិត្យឡើងវិញនេះ ត្រូវបានធ្វើឡើងដោយផ្អែកភាគច្រើនទៅលើផែនការ និងឯកសារសំខាន់ៗមួយចំនួនរួមមាន៖

- បញ្ជីសូចនាករតាមដានត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣
- ផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ
- កិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ស្តីពីការកៀរគរធនធានសម្រាប់ការធ្វើជំរឿនកសិកម្ម

## ១.៤ បទពិសោធន៍ស្វែងយល់

មានសកម្មភាពរីកចម្រើនមួយចំនួន សម្រាប់កិច្ចសម្របសម្រួលប្រសើរជាងមុននៃខ្លឹមសារ និងការកំណត់ពេលនៃសកម្មភាពអង្កេត។ ទោះជាយ៉ាងណាក៏ដោយ មានតម្រូវការដើម្បីអភិវឌ្ឍន៍បន្ថែមក្នុងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងការធ្វើផែនការ ការផ្តល់ហិរញ្ញវត្ថុអំពី

បញ្ហាវិធីសាស្ត្រ សំណួរប្រកបដោយបទដ្ឋាន វិធីសាស្ត្រទូទៅក្នុងការវិភាគ និងការប្រើប្រាស់សមត្ថភាពការងាររបស់វិទ្យាស្ថានជាតិស្ថិតិ។ ច្បាប់ស្ថិតិធ្វើការសម្របសម្រួលរវាងវិទ្យាស្ថានជាតិស្ថិតិ ធនាគារជាតិនៃកម្ពុជា ក្រសួងពាក់ព័ន្ធនានា ដែលផ្តល់ឱ្យប្រព័ន្ធនេះ នូវមូលដ្ឋានដ៏រឹងមាំសម្រាប់ធ្វើការសម្រសម្រួលនូវប្រព័ន្ធទាំងមូល។

មានគុណសម្បត្តិដ៏ធំចេញមកពីអង្កេត និងជំរឿនទ្រង់ទ្រាយធំ។ ដើម្បីថែរក្សាគុណភាពនាពេលបច្ចុប្បន្នក្នុងស្ថិតិ និងសូចនាករដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍកំណើនសង្គមកិច្ចកម្ពុជា ប្រកបដោយនិរន្តរភាព ត្រូវមានការធ្វើផែនការទាំងរយៈពេលខ្លី និងរយៈពេលវែង នៅក្នុងរបៀបថែរក្សាលទ្ធផលដែលអាចទាញយកបាន និងថវិកាស្ទួលដែលមានការធានា។ ចាប់តាំងពីឆ្នាំ ២០០៧ មក ជំរឿនប្រជារាស្ត្រឆ្នាំ២០០៨ និងជំរឿនសហគ្រាសឆ្នាំ២០១១ ត្រូវបានធ្វើឡើងរួមជាមួយការផ្តល់មូលនិធិពីដៃគូអភិវឌ្ឍន៍។ រាជរដ្ឋាភិបាលកម្ពុជាកំពុងបង្កើនការផ្តល់មូលនិធិដល់ការធ្វើជំរឿនទាំងឡាយ។ ប៉ុន្តែការផ្តល់មូលនិធិឱ្យបានកើនឡើងពីរាជរដ្ឋាភិបាលកម្ពុជាទាមទារឱ្យបង្កើតប្រព័ន្ធស្ថិតិប្រកបដោយនិរន្តរភាព។

ជំនាញក្នុងស្ថិតិ និងសមត្ថភាពនៅវិទ្យាស្ថានជាតិស្ថិតិ មានការរីកចម្រើនចាប់តាំងពីឆ្នាំ២០០៧មក។ ការកែលម្អទាំងឡាយនៅមិនទាន់មាននៅឡើយទេ ទាំងការធ្វើការអង្កេត និងជំរឿននៅវិទ្យាស្ថានជាតិស្ថិតិ និងថាតើនៅពេលណាវិទ្យាស្ថានជាតិស្ថិតិនឹងបណ្តុះបណ្តាលផ្នែកផ្សេងទៀត នៅក្នុងប្រព័ន្ធស្ថិតិជាតិដើម្បីធ្វើការកែលម្អជំនាញមន្ត្រីផ្នែកស្ថិតិ។ ថវិកាស្ទួលសម្រាប់ការងារនេះ គឺជាតម្រូវការមួយផងដែរ។

## ១.៥ ការរៀបចំរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃផែនការមេស្ថិតិ

ផែនការមេស្ថិតិនាពេលបច្ចុប្បន្ននេះ គ្របដណ្តប់រយៈពេលពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៥ និងដល់ពេលដែលត្រូវពិនិត្យឡើងវិញ ដើម្បីធ្វើការវាយតម្លៃថាតើផែនការមេស្ថិតិនេះ ត្រូវការឱ្យមានការកែតម្រូវឬទេ ជាពិសេសទាក់ទងនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ គំនិតពិចារណាមួយផ្សេងទៀត គឺក្របខ័ណ្ឌការងារអាស៊ានដែលនឹងមានឥទ្ធិពលធំជាងមុន ទៅលើប្រព័ន្ធស្ថិតិជាតិក្នុងពេលអនាគតដ៏ខ្លីខាងមុខ។

ផែនការមេស្ថិតិ គឺជាផែនការរយៈពេលវែង និងមានមហិច្ឆតាខ្ពស់ដើម្បីគ្របដណ្តប់លើតម្រូវការរបស់អ្នកប្រើប្រាស់ដែលមានការទទួលស្គាល់នៃស្ថិតិក្នុងសង្គមកម្ពុជា។ វាគឺជាផែនការដែលមានការរៀបចំយ៉ាងល្អ និងបានកំណត់នូវកម្មវិធីហេដ្ឋារចនាសម្ព័ន្ធស្ថិតិ កម្មវិធីការងារស្ថិតិ សំណើថវិកា និងផែនការហិរញ្ញវត្ថុ និងផែនការអនុវត្តសម្រាប់ប្រព័ន្ធស្ថិតិជាតិទាំងមូល។ វាក៏ផ្តល់ផងដែរនូវព័ត៌មានស្ដីអំពីការប្តេជ្ញាចិត្តរបស់ដៃគូអភិវឌ្ឍន៍ និងបញ្ជីសូចនាករ។ ទោះយ៉ាង

ណាក៏ដោយ ក៏នៅមានកង្វះខាតហិរញ្ញវត្ថុដ៏ច្រើន គឺប្រហែលជាត្រូវការ ៧៥ ភាគរយនៃថវិកាសរុប។ នៅពេលសព្វថ្ងៃនេះ ថវិកាស្ថិតិភាគច្រើនត្រូវបានផ្តល់ដោយអង្គការជាដៃគូអភិវឌ្ឍន៍ផ្សេងៗគ្នា។ នៅក្នុងផែនការមេស្ថិតិនាពេលបច្ចុប្បន្ន មានការស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាតម្លើងចំណែកបដិភាគរបស់ខ្លួន ១០ ភាគរយជារៀងរាល់ឆ្នាំ រហូតដល់មានការផ្តល់ហិរញ្ញវត្ថុពេញលេញដល់ប្រព័ន្ធស្ថិតិជាតិ។ យោបល់ស្នើសុំនេះ គឺអាស្រ័យលើស្ថានភាពកាលពីឆ្នាំ ២០០៧។ ដូចដែលបានដឹងកន្លងមកការផ្តល់ហិរញ្ញវត្ថុភាគច្រើន ឬទាំងអស់របស់ដៃគូអភិវឌ្ឍន៍នឹងបញ្ចប់នៅឆ្នាំ២០១៥។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលត្រូវតែបង្កើនមូលនិធិយ៉ាងតិចប្រហែលពី ២០ ទៅ ២៥ ភាគរយជារៀងរាល់ឆ្នាំរហូតដល់ឆ្នាំ ២០១៥។

គណៈប្រតិភូ PARIS21 តាមរយៈវិទ្យាស្ថានជាតិស្ថិតិ បានមកបំពេញបេសកកម្មកាលពីខែមិថុនា ឆ្នាំ ២០១១ ដើម្បីជួបជាមួយមន្ត្រីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សំខាន់ៗមួយចំនួននៃប្រព័ន្ធស្ថិតិកម្ពុជា ក្នុងការលើកទឹកចិត្តឱ្យមានការចូលរួមពិនិត្យឡើងវិញផែនការមេស្ថិតិនេះ។ បន្ទាប់ពីជំនួប និងកិច្ចពិភាក្សាជាមួយវិទ្យាស្ថានជាតិស្ថិតិ មន្ត្រីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គណៈប្រតិភូបានផ្តល់អនុសាសន៍មួយចំនួន ក្នុងការប្រកាសរៀបចំការពិនិត្យឡើងវិញ នូវផែនការមេស្ថិតិនេះ។ ក្នុងរបាយការណ៍បេសកកម្ម Sida ដែលមានចំណងជើងថា "ជំនួយក្នុងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិនៅក្នុងប្រទេសកម្ពុជា" ពីឆ្នាំ២០០៩ ក៏មានអនុសាសន៍មួយផងដែរក្នុងការគោរពតាមសេចក្តីអនុម័តរបស់ផែនការមេស្ថិតិ ចូលទៅក្នុងភាពជាក់ស្តែងសម្រាប់ការកែលម្អ និងការពិនិត្យឡើងវិញនាពេលអនាគត។

ឯកសារពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិផែនការមេស្ថិតិនេះ ឥឡូវត្រូវបានធ្វើឡើងជាផ្នែកមួយនៃគម្រោងកសាងសមត្ថភាពស្ថាប័នដែលមានការជួយឧបត្ថម្ភពីអង្គការ Sida នៅវិទ្យាស្ថានជាតិស្ថិតិ។ គោលបំណងរួម គឺការពិនិត្យឡើងវិញ និងការវាយតម្លៃផែនការមេស្ថិតិ និងសកម្មភាពដែលស្ថិតនៅក្រោមផែនការមេស្ថិតិនេះ រួមជាមួយការវាយតម្លៃនៃសកម្មភាពអនុវត្ត និងពីរបៀបដែលសកម្មភាពទាំងអស់នេះ កំពុងរួមចំណែកដល់ការអនុវត្តផែនការមេស្ថិតិ។ ការងារពាក់ព័ន្ធនឹងអ្នកផលិត អ្នកប្រើប្រាស់ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។

# ២. ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធស្ថិតិជាតិ

## ២.១ សមាសធាតុនៃប្រព័ន្ធស្ថិតិជាតិ

ប្រព័ន្ធស្ថិតិជាតិកម្ពុជា ជាប្រព័ន្ធស្ថិតិបែបវិមជ្ឈការយ៉ាងទូលំទូលាយ ហើយត្រូវបានកំណត់ដោយច្បាប់ស្ថិតិ និងអនុក្រឹត្យពាក់ព័ន្ធមួយចំនួន។ ច្បាប់ស្ថិតិចូលជាធរមាននៅឆ្នាំ ២០០៥ និងអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ក៏ចូលជាធរមានយ៉ាងពេញលេញកាលពីឆ្នាំ ២០០៧។ នៅឆ្នាំ ២០១០ អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងត្រូវបានអនុម័ត។ ក្របខ័ណ្ឌការងារផ្លូវច្បាប់ រួមមានច្បាប់ស្ថិតិ និងអនុក្រឹត្យទាំងឡាយផ្តល់នូវមូលដ្ឋានរួមក្នុងការធ្វើឱ្យការងារប្រព័ន្ធស្ថិតិជាតិមានដំណើរការល្អ និងគាំទ្រដល់ដំណើរការការងារ។

ច្បាប់ស្ថិតិ និងអនុក្រឹត្យពាក់ព័ន្ធនានា បានកំណត់យ៉ាងច្បាស់នូវការទទួលខុសត្រូវ និងទំនាក់ទំនងរវាងវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង។ ច្បាប់ស្ថិតិផ្តល់នូវតួនាទីពេញលេញដល់ក្រុមប្រឹក្សាស្ថិតិ ជាអ្នកផ្តល់ប្រឹក្សាក្នុងការសម្របសម្រួលនូវការអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ ហើយគណៈកម្មាធិការសម្របសម្រួលស្ថិតិ មានតួនាទីជួយវិទ្យាស្ថានជាតិស្ថិតិក្នុងការសម្របសម្រួលបច្ចេកទេសនៃស្ថិតិផ្លូវការ។

យោងតាមអនុក្រឹត្យនៃស្ថិតិផ្លូវការដែលបានចាត់តាំង វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងពាក់ព័ន្ធចំនួន ២២ ក្រុមប្រឹក្សាចំនួន ២ រដ្ឋលេខាធិការដ្ឋានចំនួន ២ និងធនាគារជាតិនៃកម្ពុជា មានភារកិច្ចក្នុងការប្រមូល កែឆ្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ ទៅតាមតម្រូវការទិន្នន័យរបស់អ្នកប្រើប្រាស់។ ជំរឿន និងអង្កេតទាំងអស់ត្រូវធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងការអង្កេតតាមវិស័យ ត្រូវធ្វើឡើងដោយអង្គភាពស្ថិតិដែលបានចាត់តាំង ឬត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ។ បញ្ជីស្ថិតិផ្លូវការដែលផលិតដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបានកត់ត្រានៅក្នុងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង។

ច្បាប់ស្ថិតិ និងអនុក្រឹត្យបានបង្កើតនូវក្របខ័ណ្ឌការងារ និងលើកទឹកចិត្តដល់ការធ្វើសមាហរណកម្មនូវសកម្មភាពស្ថិតិនានា ទៅក្នុងប្រព័ន្ធស្ថិតិជាតិ។ ដូច្នេះ វាគឺជាឧបករណ៍ដែលមានការរៀបចំបានយ៉ាងល្អ និងបានកំណត់យ៉ាងច្បាស់ពីទំនួលខុសត្រូវក្នុងការប្រមូល និងរៀបចំស្ថិតិផ្លូវការនៅក្នុងប្រព័ន្ធស្ថិតិជាតិ ប៉ុន្តែតាមការអនុវត្តជាក់ស្តែង វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងស្ថាប័នពាក់ព័ន្ធ នៅតែជួបការលំបាកក្នុងការបំពេញមុខងារឱ្យបានពេញលេញ ពីព្រោះការទទួលខុសត្រូវរបស់ផ្នែកផ្សេងៗនៅក្នុងប្រព័ន្ធ គឺពិបាកក្នុងការបំពេញដោយសារគ្មានការផ្តល់មូលនិធិពីរាជរដ្ឋាភិបាលប្រកបដោយនិរន្តរភាព។ ស្ថិតិមួយចំនួន ក្នុងចំណោមស្ថិតិផ្លូវការដែល

បានចាត់តាំង អាចជាស្ថិតិតាមផ្នែកច្រើនជាងមុន ដែលត្រូវបានគេប្រើប្រាស់ផ្ទៃក្នុងនៅក្នុងក្រសួង អាស្រ័យហេតុនេះវាមិនត្រូវចាត់ទុកថាជាស្ថិតិផ្លូវការនោះឡើយ។

ការផ្តល់មូលនិធិពីរាជរដ្ឋាភិបាលដ៏រឹងមាំ សម្រាប់ស្ថិតិផ្លូវការដែលបានចាត់តាំង នឹងធានាឱ្យប្រព័ន្ធស្ថិតិជាតិមានដំណើការប្រកបដោយនិរន្តរភាព។ ដរាបណាការផ្តល់ហិរញ្ញវត្ថុភាគច្រើននៃប្រព័ន្ធស្ថិតិជាតិធ្វើឡើងដោយដៃគូអភិវឌ្ឍន៍ ជំរឿន និងអង្កេតត្រូវធ្វើឡើងក្នុងគោលដៅពិសេសតែប៉ុណ្ណោះ។

នៅឆ្នាំ ២០១១ មានមន្ត្រីសរុបចំនួន ៩៩៦ នាក់ បានចូលរួមក្នុងការងារផលិតកម្មស្ថិតិផ្លូវការ។ វិទ្យាស្ថានជាតិស្ថិតិមានមន្ត្រីប្រហែល ៣១៤ នាក់ នៅថ្នាក់ការិយាល័យកណ្តាលនៃក្រសួងផែនការ និងមន្ត្រីចំនួន ៣១៥ នាក់ នៅការិយាល័យខេត្ត និងស្រុក។ មានមន្ត្រីប្រហែល ៣៦៧ នាក់ ដែលចូលរួមក្នុងសកម្មភាពស្ថិតិនៅតាមក្រសួងនានា និងធនាគារជាតិនៃកម្ពុជា។

## ២.២ ទំនាក់ទំនងរវាងសមាសធាតុនៃប្រព័ន្ធស្ថិតិជាតិ

ក្នុងដំណើរការនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ ផ.យ.អ.ជ កិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបានរៀបចំឡើង ដោយមានការសហការរវាងអគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ ស្តីពីការត្រួតពិនិត្យឡើងវិញ និងកែសម្រួលសូចនាករសម្រាប់តាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តផ.យ.អ.ជនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ក៏មានកិច្ចប្រជុំពិគ្រោះយោបល់មួយចំនួនផងដែរ អំពីការរៀបចំរបាយការណ៍បច្ចុប្បន្នកម្មគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

- ក្រុមការងារថ្នាក់ជាតិវាស់វែងភាពក្រីក្រ (NWG PM) បានរៀបចំកិច្ចប្រជុំចំនួន ៥ លើក ដើម្បីធ្វើការពិភាក្សាអំពីវិធីសាស្ត្រថ្មីសម្រាប់វាស់វែងភាពក្រីក្រ
- អនុក្រុមការងារបច្ចេកទេសផែនការ និងកាត់បន្ថយភាពក្រីក្រ ផ្នែកស្ថិតិ (TWG-PPR Sub-group for Statistics) នៃវិទ្យាស្ថានជាតិស្ថិតិ បានរៀបចំកិច្ចប្រជុំចំនួន ២ លើក ដើម្បីពិភាក្សាពីការវាយតម្លៃពាក់កណ្តាលអាណត្តិផែនការមេស្ថិតិ
- កិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានរៀបចំឡើង ជាច្រើនលើក ហើយប្រធានបទមួយចំនួន ត្រូវបានលើកមកពិភាក្សាកំឡុងកិច្ចប្រជុំទាំងនោះ ដូចជាការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ ការកសាងសមត្ថភាពសម្រាប់ប្រព័ន្ធស្ថិតិជាតិ និងការប្រមូលម៉េតាដាតា (Metadata) សម្រាប់ប្រព័ន្ធស្ថិតិ
- កិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ដើម្បីកៀរគរធនធានសម្រាប់ធ្វើជំរឿនកសិកម្ម និងសម្រាប់ការធ្វើអង្កេតផ្សេងៗទៀត ដូចជាការអង្កេតកម្លាំងពលកម្ម

ការរៀបចំសិក្ខាសាលាដើម្បីពិភាក្សាពីតម្រូវការស្ថិតិ ការកសាងសមត្ថភាព និងតម្រូវការធនធាននានា គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្កើតនូវប្រព័ន្ធមួយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការស្ថិតិសម្រាប់អ្នកប្រើប្រាស់ក្នុងសង្គមកម្ពុជាទូទៅ។ ក្រៅពីនេះ ក្រុមការងារបច្ចេកទេសផែនការ និងកាត់បន្ថយភាពក្រីក្រផ្នែក ផ.យ.អ.ជ និងដៃគូអភិវឌ្ឍន៍មួយចំនួនទៀត មិនបានចូលរួមក្នុងដំណើរការនៃការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ផែនការមេស្ថិតិនេះទេ។

កំឡុងនៃការពិនិត្យឡើងវិញនូវផែនការមេស្ថិតិ មានកិច្ចប្រជុំជាច្រើន ធ្វើឡើងជាមួយដៃគូអភិវឌ្ឍន៍ និងក្រសួង ស្ថាប័ននានា។ កិច្ចប្រជុំ និងកិច្ចពិភាក្សាទាំងនេះ បានបង្ហាញពីតម្រូវការជាប្រព័ន្ធមួយនៃកិច្ចប្រជុំ និងសិក្ខាសាលាជាទៀងទាត់ដើម្បីពង្រឹងពីប្រព័ន្ធស្ថិតិជាតិ។ វាមានសារៈសំខាន់យ៉ាងខ្លាំងផងដែរ ក្នុងការកំណត់ប្រព័ន្ធនានាសម្រាប់ការទំនាក់ទំនងជាទៀងទាត់រវាងវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដែលជាអ្នកប្រើប្រាស់ និងជាអ្នកផលិតទិន្នន័យ និងអ្នកប្រើប្រាស់ដទៃទៀត។ ដោយហេតុនេះ ប្រព័ន្ធមួយដែលរួមបញ្ចូលកិច្ចប្រជុំ និងសិក្ខាសាលាជាមួយអ្នកប្រើប្រាស់ក្នុងការកំណត់តម្រូវការស្ថិតិ និងមតិយោបល់អំពីរបៀបដែលគួរត្រូវបានផ្តល់អាទិភាព និងផ្តល់ហិរញ្ញវត្ថុ និងប្រព័ន្ធមួយផ្សេងទៀត គឺជាប់ទាក់ទងនឹងរាជរដ្ឋាភិបាល ដើម្បីពិភាក្សាអំពីតម្រូវការដែលមានការកំណត់នៃស្ថិតិផ្លូវការ និងពីរបៀបថាតើវាត្រូវបានផ្តល់ហិរញ្ញវត្ថុ និងអាទិភាពយ៉ាងដូចម្តេច។

# ៣. ការវាយតម្លៃចំណុចខ្លាំង និងចំណុចខ្សោយ នៃប្រព័ន្ធនាពេលបច្ចុប្បន្ន

## ៣.១ ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធស្ថិតិជាតិ

របាយការណ៍ពាក់កណ្តាលអាណត្តិផែនការមេស្ថិតិ បង្ហាញថាចំណុចខ្សោយចំបងៗមួយចំនួនដែលត្រូវបានដោះស្រាយជាដំបូងគឺនៅតែចាំបាច់។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័នដែលបានផ្តល់ដោយច្បាប់ស្ថិតិ ផ្នែកខ្លះមានលក្ខណៈគ្រប់គ្រាន់ និងផ្នែកខ្លះទៀត គឺនៅមិនទាន់គ្រប់គ្រាន់នៅឡើយ។ ឧទាហរណ៍រួមមានកង្វះឯករាជ្យភាព ឯករាជ្យភាពផ្នែក មូលនិធិនិងថវិការបស់វិទ្យាស្ថានជាតិស្ថិតិ និងស្ថិតិផ្លូវការ។ ប្រព័ន្ធនានាសម្រាប់ការធ្វើទំនាក់ទំនង (សូមមើលផ្នែក ២.២) និងសម្រាប់ការធ្វើផែនការ និងតាមដាន និងការសម្របសម្រួល និងការពិគ្រោះយោបល់ ត្រូវតែពង្រឹងសម្រាប់ប្រព័ន្ធស្ថិតិជាតិ ដើម្បីធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាពជាមួយនឹងប្រព័ន្ធវិមជ្ឈការ។

ក្របខ័ណ្ឌច្បាប់គ្របដណ្តប់ភាគច្រើនក្នុងការធ្វើឱ្យការងារប្រព័ន្ធស្ថិតិជាតិ ដំណើរការបានយ៉ាងល្អ និងផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំផងដែរ សម្រាប់ការងារស្ថិតិ និងសម្របសម្រួល។ ទោះបីជាយ៉ាងណាក៏ដោយ មានផ្នែកច្បាប់មួយចំនួនដែលអាចកែលម្អបាន។ មានភាពខុសគ្នាក្នុងការកំណត់នៅក្នុងច្បាប់ស្ថិតិ និងអនុក្រឹត្យ និងបញ្ហាមួយចំនួនអាចមានលក្ខណៈច្បាស់លាស់ជាងដើម្បីធ្វើឱ្យច្បាប់ និងឯកសារងាយស្រួលអាន និងយល់។ ផ្នែកខ្លះនៃច្បាប់មានភាពលំអិតពេកដោយមានភាពប្រថុយប្រថានក្នុងការទាមទារឯកសាររំលឹកសារឡើងវិញច្រើនជាង ប្រសិនបើផ្នែកទាំងអស់នេះមិនសូវមានភាពលំអិត។ ការធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិទាំងឡាយជារឿយៗមានដំណើរការយឺត។ ដោយសារស្ថិតិជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធនៃសង្គម ផលិតកម្មស្ថិតិនាពេលបច្ចុប្បន្ន ត្រូវគាំទ្រឱ្យមានស្ថិតិប្រភេទអ្វីដែលត្រូវផលិត ហើយផលិតដោយនរណា និងសម្រាប់នរណា។ ក្របខ័ណ្ឌការងារផ្នែកផ្លូវច្បាប់ត្រូវគាំទ្រដំណើរការការងារ និងត្រូវឱ្យច្បាស់លាស់អំពីទំនួលខុសត្រូវ។

មានការផ្តល់អនុសាសន៍ឱ្យធ្វើការកែសម្រួល អនុក្រឹត្យទាំងឡាយដើម្បីពង្រឹងក្របខ័ណ្ឌការងារឱ្យកាន់តែប្រសើរ។ ការពិនិត្យឡើងវិញត្រូវក្រឡេកមើលភាពច្បាស់លាស់ និងឱ្យកាន់តែយល់ច្បាស់ ត្រូវក្រឡេកមើលលើការធ្វើសុខដុមនីយកម្មនៃផ្នែកបីៈ អាស្រ័យលើការទទួលខុសត្រូវការផ្តល់នូវទស្សន និងនិយមន័យ តាមកម្រិតនៃព័ត៌មានលំអិត និងប្រសិនបើមានកង្វះខាតនូវចំណុចសំខាន់ៗ ឧទាហរណ៍ គុណភាព និងភាពសាមញ្ញសម្រាប់អ្នកឆ្លើយតប។ ក្នុងឆ្នាំទៅមុខៗទៀតជាការប្រសើរ គួរតែធ្វើវិសោធនកម្មច្បាប់ស្ថិតិ។

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានកិច្ចខិតខំប្រឹងប្រែងជាច្រើន ក្នុងការពង្រឹងការផលិតស្ថិតិតាមរយៈការបណ្តុះបណ្តាល ជំនួយបច្ចេកទេស និងការគាំទ្រផ្នែកគ្រប់គ្រង។ នៅមានគម្លាតដ៏ធំរវាងកម្រិតជំនាញ និងបច្ចេកវិទ្យាដែលត្រូវយកមកប្រើប្រាស់សម្រាប់ផលិតកម្មស្ថិតិ ប្រកបដោយនិរន្តរភាព និងសម្រាប់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីបំពេញតួនាទីរបស់ខ្លួនជាមជ្ឈមណ្ឌលសមត្ថភាពមួយក្នុងផលិតកម្មស្ថិតិ។

## ៣.២ លទ្ធផលស្ថិតិ និងគុណភាពទិន្នន័យ

បន្ទាប់ពីផែនការមេស្ថិតិត្រូវបានចេញផ្សាយ ជំនួយគាំទ្រដល់វិទ្យាស្ថានជាតិស្ថិតិបានបន្តតាមរយៈដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា JICA, Sida, UNFPA និង UNICEF។ មន្ត្រីដែលមានការបណ្តុះបណ្តាល និងស្ថិតិដែលមានចំនួនច្រើន និងមានការផ្សព្វផ្សាយ គឺជាលទ្ធផលនៃជំនួយរបស់ដៃគូអភិវឌ្ឍន៍នៅប៉ុន្មានឆ្នាំចុងក្រោយនេះ។

ផ្នែកគណនេយ្យជាតិបានទទួលការបណ្តុះបណ្តាលតាមរយៈទីប្រឹក្សារយៈពេលខ្លី និងទិន្នន័យរដ្ឋបាលច្រើនជាងមុន ត្រូវបានប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់មុខងារគណនាទាំងឡាយ។ ទិន្នន័យអំពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានរៀបចំប្រើប្រាស់សម្រាប់គណនេយ្យជាតិប្រចាំឆ្នាំ និងប្រចាំត្រីមាស។ ការផ្សព្វផ្សាយគណនេយ្យជាតិប្រចាំត្រីមាស នឹងចាប់ផ្តើមក្នុងឆ្នាំ ២០១២។

ជំរឿនកសិកម្មនៅមិនទាន់ធ្វើនៅឡើយ ដោយសារតែកង្វះខាតមូលនិធិ។ វិទ្យាស្ថានជាតិស្ថិតិបានខិតខំដើម្បីស្វែងរកដៃគូអភិវឌ្ឍន៍ឱ្យបានគ្រប់គ្រាន់ និងជំនួយគាំទ្រពីរាជរដ្ឋាភិបាលក្នុងការរៀបចំជំរឿនកសិកម្មក្នុងឆ្នាំ២០១៣។ អង្គការ JICA បានជួយគាំទ្រវិទ្យាស្ថានជាតិស្ថិតិក្នុងការអនុវត្តជំរឿនសហគ្រាសក្នុង ឆ្នាំ២០១១ និងរៀបចំផែនការដើម្បីដំណើរការរៀបចំអង្កេតសហគ្រាសដ៏ធំមួយក្នុងឆ្នាំ២០១៤។ ជំរឿន និងអង្កេតទាំងនេះ នឹងជួយកែលម្អព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ឱ្យកាន់តែប្រសើរឡើង។

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែសម្រាប់ទីក្រុងភ្នំពេញ ត្រូវបានផ្សព្វផ្សាយដោយវិទ្យា-ស្ថានជាតិស្ថិតិជាទៀងទាត់។ ក្នុងឆ្នាំ២០១១ ការរៀបចំឆ្នាំគោលសម្រាប់សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ត្រូវបានធ្វើឡើង។ ចាប់ពីឆ្នាំ២០១២ វិទ្យាស្ថានជាតិស្ថិតិ នឹងមានគម្រោងចងក្រងសន្ទស្សន៍ថ្លៃទំនិញ ដោយគ្របដណ្តប់ខេត្តចំនួន៥ បន្ថែមទៀត ។

ការប្រមូលទិន្នន័យតាមវិស័យមួយចំនួន ដែលធ្វើឡើងដោយក្រសួងពាក់ព័ន្ធមានលក្ខណៈប្រសើរ ហើយវិទ្យាស្ថានជាតិស្ថិតិអាចទាញយកទិន្នន័យបានកាន់តែច្រើនជាងមុន។ បច្ចុប្បន្ន

ទិន្នន័យនាំចេញ និងនាំចូលត្រូវបានគេធ្វើជាទៀងទាត់ មកកាន់វិទ្យាស្ថានជាតិស្ថិតិដើម្បីយកទៅប្រើប្រាស់នៅក្នុងគណនេយ្យជាតិ។ ទិន្នន័យហិរញ្ញវត្ថុ និងទេសចរណ៍ក៏ត្រូវបានធ្វើឱ្យប្រសើរផងដែរ។ ផ្នែកផ្សេងៗទៀត ការរីកចម្រើននៅមានភាពយឺតយ៉ាវ ដូចជាទិន្នន័យផ្នែកគមនាគមន៍ និងការដឹកជញ្ជូនជាដើម។

ចំពោះវិស័យសង្គមកិច្ច ការផ្តល់សេវាផ្នែកស្ថិតិកាន់តែមានភាពប្រសើរ ហើយនៅតែមានសុពលភាព។ជំរឿននិងអង្កេតមួយចំនួនត្រូវបានគេធ្វើឡើងជាទៀងទាត់ដូចជាជំរឿនប្រជារាស្ត្រ អង្កេតប្រជាសាស្ត្រ និងសុខភាព និងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាជាដើម។ នៅក្នុងវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡាមានប្រព័ន្ធទិន្នន័យដ៏ធំជាមួយនឹងទិន្នន័យរដ្ឋបាល (ប្រព័ន្ធគ្រប់គ្រងព័ត៌មានការអប់រំ) ប៉ុន្តែសម្រាប់វិស័យឯកជន និងការអប់រំក្រៅប្រព័ន្ធ ស្ថានភាពគឺស្រដៀងនឹងឆ្នាំ ២០០៧។

ការវិភាគអំពីភាពក្រីក្រក្នុងឆ្នាំ ២០១១ ធនាគារពិភពលោកបានបន្តគាំទ្រដោយមានការផ្តល់នូវវគ្គបណ្តុះបណ្តាលស្តីពីការវិភាគភាពក្រីក្រ និងបានបណ្តុះបណ្តាលមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិអំពីរបៀបគណនាការប៉ាន់ប្រមាណនៃភាពក្រីក្រ។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រុមការងារថ្នាក់ជាតិវាស់វែងភាពក្រីក្រ ដែលមានរដ្ឋលេខាធិការនៃក្រសួងផែនការជាប្រធាន និងអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិជាអនុប្រធាន។ នាពេលបច្ចុប្បន្ននេះ ក្រុមការងារនេះកំពុងពិភាក្សាអំពីវិធីសាស្ត្រដែលអាចយកទៅប្រើប្រាស់ដើម្បីតាមដានភាពរីកចម្រើន នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលពាក់ព័ន្ធផ្នែកភាពក្រីក្រ ដែលជួយគាំទ្រដោយទីប្រឹក្សារបស់អគ្គនាយកដ្ឋានផែនការ។ រៀងរាល់ ៥ ឆ្នាំ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាទ្រង់ទ្រាយធំ តែងតែត្រូវបានរៀបចំធ្វើឡើង ដែលការអង្កេតនេះផ្តល់ឱ្យប្រទេសកម្ពុជានូវឱកាសដ៏ល្អឥតខ្ចោះក្នុងការធ្វើវិភាគលើភាពក្រីក្រស៊ីជម្រៅ។ វិធីសាស្ត្រថ្មីចុងក្រោយសម្រាប់វាស់វែងបន្ទាត់នៃភាពក្រីក្រផ្លូវការនឹងត្រូវអនុវត្តក្នុងឆ្នាំ ២០១២។

ការផ្សព្វផ្សាយស្ថិតិ ត្រូវបានកែលម្អ ដោយសារគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនាពេលបច្ចុប្បន្ននេះ បានផ្សព្វផ្សាយនូវលទ្ធផលបានមកពីការអង្កេតផ្សេងៗជាច្រើន ហើយអ្នកប្រើប្រាស់អាចចូលទៅយកទិន្នន័យដោយផ្ទាល់បាន ដូចជាជំរឿនប្រជារាស្ត្រ និងកាំអ៊ីនហ្វូ។ សៀវភៅកម្រងទិន្នន័យស្ថិតិប្រចាំឆ្នាំបោះពុម្ពថ្មី ត្រូវបានចេញផ្សាយនៅខែមិថុនា ឆ្នាំ២០១២។ កូនសៀវភៅស្តីពីយែនឌ័រ បោះពុម្ពពីរលើកដែលមានចំណងជើងថា "ស្ត្រី និង បុរសក្នុងប្រទេសកម្ពុជា" ក៏ត្រូវបានចេញផ្សាយផងដែរ។

គម្រោងគាំទ្រដោយអង្គភាពស្ថិតិរបស់អង្គការសហប្រជាជាតិ (UNSD) ស្តីពីការផ្សព្វផ្សាយសូចនាករអភិវឌ្ឍន៍ជាតិ ក្នុងនោះផ្តោតជាពិសេសសូចនាករស្នូលផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ត្រូវបានអនុវត្តដោយជោគជ័យនាពេលបច្ចុប្បន្ន ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យសូចនាករសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CAMInfo) និងប្រើប្រាស់ប្រព័ន្ធបំលាស់ប្តូរម៉េតាជាតា (SDMX) ជាឧបករណ៍ក្នុងការបញ្ជូនសូចនាករ និងមេតាជាតារបស់សូចនាករទាំងនេះ ទៅកាន់ប្រព័ន្ធទិន្នន័យមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ហើយអ្នកប្រើប្រាស់ទូទៅក៏អាចចូលទៅទាញយកទិន្នន័យទាំងនេះបានផងដែរ ពីគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។

## ៣.៣ កម្រិតជំនាញ និងការបណ្តុះបណ្តាល

ការធ្វើឱ្យកាន់ប្រសើរនូវសមត្ថភាពរបស់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ បានបន្តទៅមុខចាប់តាំងពីផែនការមេស្ថិតិត្រូវបានរៀបចំឡើង។ មន្ត្រីដែលមានកម្រិតសិក្សាយ៉ាងតិចត្រឹមថ្នាក់អនុបណ្ឌិតមានចំនួន ៣៤ នាក់ក្នុងឆ្នាំ ២០១១។ កំណើននេះ ភាគច្រើនដោយសារមន្ត្រីវ័យក្មេងនៅវិទ្យាស្ថានជាតិស្ថិតិ ដែលមានកំរិតអប់រំខ្ពស់ទាំងនោះ បានបញ្ចប់ពីសាកលវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា គឺមិនមែនតាមរយៈការបណ្តុះបណ្តាលនៅក្រៅប្រទេស ដូចជាប្រទេសហ្វីលីពីនកាលក្នុងកំឡុងឆ្នាំ ២០០៦ នោះឡើយ។

អង្គភាពបណ្តុះបណ្តាលមិនបានបន្តដំណើរការទៀតឡើយ ដោយសារកង្វះខាតធនធាន។ ផ្ទុយទៅវិញ គម្រោងដៃគូអភិវឌ្ឍន៍ជាច្រើន បានរៀបចំវគ្គបណ្តុះបណ្តាលផ្ទាល់ដោយឡែកនៅកន្លែងធ្វើការ ឬប្រើប្រាស់ក្រុមហ៊ុនក្នុងស្រុកដើម្បីកសាងសមត្ថភាព។ គម្រោងជំនួយរយៈពេលវែងនៅវិទ្យាស្ថានជាតិស្ថិតិចន្លោះឆ្នាំ២០០៧ និង ឆ្នាំ២០១២ ត្រូវបានរៀបចំដោយអង្គការ JICA, UNFPA, UNICEF និង Sida។ ដៃគូអភិវឌ្ឍន៍ទាំងអស់បានរៀបចំវគ្គបណ្តុះបណ្តាលដើម្បីធ្វើឱ្យប្រសើរនូវសមត្ថភាព និងប្រាកដថាវិទ្យាស្ថានជាតិស្ថិតិមានសមត្ថភាពក្នុងការអនុវត្តការងារជំរឿន និងអង្កេតផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ មានតម្រូវការពីការសម្របសម្រួលវគ្គបណ្តុះបណ្តាល ដើម្បីធ្វើឱ្យការកសាងសមត្ថភាពមាននិរន្តរភាព និងដើម្បីប្រើប្រាស់ធនធានឱ្យកាន់តែមានប្រសិទ្ធភាព។

វិទ្យាស្ថានជាតិស្ថិតិ បានអនុវត្តការវាយតម្លៃសន្និធិសមត្ថភាព ក្នុងចំណោមអ្នកផលិតស្ថិតិផ្លូវការទាំងអស់ ក្នុងឆ្នាំ២០១០/២០១១ (វិទ្យាស្ថានជាតិស្ថិតិមិនរាប់បញ្ចូលទេ) ។ ក្នុងចំណោមអ្នកឆ្លើយទាំងអស់ មានត្រឹមតែ ១/៣ នៃមន្ត្រី ហាក់បីដូចជាមានជំនាញគ្រប់គ្រាន់ក្នុងការអនុវត្តការងារក្នុងស្ថាប័នស្ថិតិ និងចំនួនមន្ត្រីដែលមានជំនាញស្ថិតិខ្ពស់ នៅមិនទាន់គ្រប់គ្រាន់ក្នុងការផលិតស្ថិតិ

នៅឡើយ។ មានគម្លាតសមត្ថភាពយ៉ាងធំខាងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង និងភាសាអង់គ្លេស។ សមត្ថភាពនៅតាមក្រសួងនានា ក្នុងការផលិតស្ថិតិផ្លូវការមានកម្រិតទាបជាងច្រើន បើប្រៀបធៀបទៅនឹងវិទ្យាស្ថានជាតិស្ថិតិ។ ក្រសួងមួយចំនួនមានជំនួយផ្នែកបច្ចេកទេស និងធនធានគ្រប់គ្រាន់ក្នុងការផលិតស្ថិតិ ប៉ុន្តែត្រូវការការបណ្ដុះបណ្ដាលច្រើនបន្ថែមទៀត និងការផ្ដល់មូលនិធិពីរាជរដ្ឋាភិបាលច្រើនផងដែរ សម្រាប់សកម្មភាពរបស់ខ្លួន។

## ៣.៤ កត្តាប្រឈម

កត្តាប្រឈមចម្បងជាច្រើនសម្រាប់ការងារនៅវិទ្យាស្ថានជាតិស្ថិតិ និងសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំងមួយចំនួនមានដូចជាថវិកានៅមានកម្រិត ប្រាក់បៀវត្ស/ប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីនៅមានកម្រិត ហើយកម្រិតជំនាញរបស់មន្ត្រីក៏នៅទាប និងតម្រូវការកែលម្អផ្នែកសម្របសម្រួលជាដើម។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័នមានលក្ខណៈប្រសើរច្រើនហើយ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ទាំងស្រុងតាមគ្រប់មធ្យោបាយនៅឡើយ។ ឧទាហរណ៍ ដូចជាការផ្ដល់មូលនិធិពីរាជរដ្ឋាភិបាលនៅមានចំនួនតិច ការធ្វើឱ្យកាន់តែប្រសើរនូវការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍អំពីការផ្ដល់អាទិភាព និងការសម្របសម្រួល និងការបង្ហាញអំពីសារៈសំខាន់នៃតម្រូវការចំណាយសម្រាប់ការផលិតទិន្នន័យស្ថិតិនៅក្នុងប្រព័ន្ធវិមជ្ឈការជាដើម។

ដើម្បីសម្រេចគោលដៅរបស់ប្រព័ន្ធស្ថិតិជាតិ ដោយអនុលោមតាមច្បាប់ និងអនុក្រឹត្យនានា ផែនការមេស្ថិតិ និងផែនការផ្សេងៗទៀត ត្រូវតែមានការផ្ដល់មូលនិធិដ៏សមស្រប ការអនុវត្តវិធីសាស្ត្រ និងបច្ចេកទេសប្រកបដោយប្រសិទ្ធភាព ហើយមន្ត្រីមានជំនាញ និងមានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការផលិតស្ថិតិផ្លូវការ ត្រូវតែមានការលើកទឹកចិត្ត។ ប្រព័ន្ធមុខងារដ៏ប្រសើរមួយសម្រាប់ការផលិតស្ថិតិមានគុណភាពខ្ពស់នៅក្នុងប្រព័ន្ធស្ថិតិជាតិ និងជាពិសេសនៅវិទ្យាស្ថានជាតិស្ថិតិ ត្រូវតែមានការផ្ដល់ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពនូវមូលនិធិរបស់រាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ ការផលិតស្ថិតិផ្លូវការមិនអាចពឹងផ្អែកទៅលើការផ្ដល់មូលនិធិពីដៃគូអភិវឌ្ឍន៍ក្នុងរយៈពេលយូរអង្វែងតាមលក្ខណៈពិសេសណាមួយបាននោះទេ ក៏ប៉ុន្តែត្រូវតែមានការផ្ដល់មូលនិធិដោយរាជរដ្ឋាភិបាលកម្ពុជាឱ្យបានគ្រប់គ្រាន់ និងមាននិរន្តរភាព។

ដើម្បីបង្កើនប្រសិទ្ធភាពនៅក្នុងប្រព័ន្ធស្ថិតិជាតិ ត្រូវតែមានដំណោះស្រាយនូវបញ្ហាប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភ។ មន្ត្រីរាជការធ្វើការនៅវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិផ្សេងៗទៀត ត្រូវតែផ្ដល់បន្ថែមនូវប្រាក់បៀវត្ស/ប្រាក់ឧបត្ថម្ភ ដើម្បីពួកគេអាចផ្ដោតទៅលើការងាររាជរដ្ឋាភិបាល និងមិនស្វែងរកការងារធ្វើនៅខាងក្រៅបន្ថែមដើម្បីចិញ្ចឹមជីវិតរស់នៅរបស់ពួកគេ។ ក្រុមបេសកកម្មកន្សោមអាទិភាពត្រូវបានបញ្ចប់នៅឆ្នាំ ២០១០ ហើយមិនមានគម្រោងថ្មីណា

ផ្សេងទៀតត្រូវអនុវត្តក្រៅពីការចំណាយប្រតិបត្តិការអាទិភាព ដែលមានការជួយគាំទ្រតែពីដៃគូអភិវឌ្ឍន៍នោះទេ។ គម្រោងចំណាយប្រតិបត្តិការអាទិភាពនេះ នឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១២។ ដោយហេតុនេះ គម្រោងរយៈពេលវែងថ្មីគួរប្រកាសឱ្យអនុវត្តជាបន្ទាន់។ មានការស្នើឡើងនូវកំណែទម្រង់រដ្ឋបាលសាធារណៈ ប៉ុន្តែមិនទាន់បានអនុវត្តនៅឡើយទេ។

ផែនការមេស្ថិតិ និងប្រព័ន្ធស្ថិតិជាតិនឹងកាន់តែមាននិរន្តរភាព លុះត្រាតែកត្តាប្រឈមធំទាំងពីរ ដូចបានរៀបរាប់នៅក្នុងផែនការមេស្ថិតិនាពេលបច្ចុប្បន្ន ហើយដែលបានសង្កត់ធ្ងន់នៅទីនេះ ត្រូវបានដោះស្រាយដោយរាជរដ្ឋាភិបាលកម្ពុជា។

## ៣.៥ ការវាយតម្លៃតាមរយៈការសម្ភាសន៍ជាមួយអ្នកប្រើប្រាស់ អ្នកផលិតទិន្នន័យ និងដៃគូអភិវឌ្ឍន៍

### ៣.៥.១ ការសម្ភាសន៍ជាមួយអ្នកប្រើប្រាស់ និងអ្នកផលិតទិន្នន័យ

ការត្រួតពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃផែនការមេស្ថិតិនេះ មួយផ្នែក គឺត្រូវបានរៀបចំឡើងតាមរយៈការជួបពិគ្រោះយោបល់ជាមួយអង្គភាពស្ថិតិដែលបានចាត់តាំងទាំងអស់ ដែលជាផ្នែកមួយនៃប្រព័ន្ធស្ថិតិជាតិ។ ការជួបពិគ្រោះយោបល់ទាំងនេះ ត្រូវបានធ្វើឡើងជាមួយក្រសួងពាក់ព័ន្ធនានាចំនួន១៧។ អ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យ ត្រូវបានធ្វើការពិភាក្សាដោយផ្ដោតពិសេសទាក់ទងទៅនឹងសមត្ថភាព និងបទពិសោធន៍នាពេលបច្ចុប្បន្ន ក្នុងការផលិតទិន្នន័យស្ថិតិ ភាពទាន់ពេលវេលា និងភាពគួរឱ្យទុកចិត្តផ្នែកទិន្នន័យ សម្រាប់រៀបចំគោលនយោបាយ និងការធ្វើផែនការ ដូចដែលបានកំណត់នៅក្នុងផែនការមេស្ថិតិ។ លទ្ធផលសំខាន់ៗ ដែលបានមកតាមរយៈការពិគ្រោះយោបល់នេះបង្ហាញថា ផែនការមេស្ថិតិបានដើរតួនាទីជាប្លង់យុទ្ធសាស្ត្រសម្រាប់សកម្មភាពស្ថិតិផ្លូវការ និងការបង្កើនសមត្ថភាពពាក់ព័ន្ធសម្រាប់ឆ្នាំ ២០០៨ និងឆ្នាំ ២០១៥។ វាគ្របដណ្ដប់រាល់សកម្មភាពស្ថិតិ និងគម្រោងអភិវឌ្ឍន៍របស់ក្រសួង និងស្ថាប័ន ទាំងអស់ ក្នុងក្របខ័ណ្ឌប្រព័ន្ធស្ថិតិជាតិ។ ទោះបីជាផែនការមេស្ថិតិត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ សន្និសិទ និងតាមរយៈគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួងនានាចំនួន ១៧ បានបង្ហាញថា ក្រសួងចំនួន ៦ ក្នុងចំណោម ១៧ មានការយល់ដឹងច្រើនពីផែនការមេស្ថិតិ។ ហេតុផលជាមូលដ្ឋាន ដែលផ្ដល់ ដោយមន្ត្រីដែលបានចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទាំងនេះ ភាគច្រើនដោយសារតែការពិតថាពួកគេថ្មីចំពោះមុខតំណែង ឬមានការផ្លាស់ប្ដូរផ្នែកការដឹកនាំរបស់ស្ថាប័នផលិតស្ថិតិរបស់ពួកគេ។

ទិន្នន័យស្ថិតិត្រូវបានផ្សារភ្ជាប់ទៅនឹងបញ្ជីនៃអញ្ញត្តិ និងសូចនាកររបស់ ជ.យ.អ.ជ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងអាស៊ាន។ ការផលិតទិន្នន័យស្ថិតិជាប់ពាក់ព័ន្ធក្នុង

កាលៈទេសៈថ្មីនៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។ ការសម្រេចចិត្តក្នុងការផលិតស្ថិតិផ្លូវការ ឬសូចនាករទាំងឡាយពឹងផ្អែកជាសំខាន់ទៅលើ ផ.យ.អ.ជ ឬក្របខ័ណ្ឌការងាររបស់ក្រសួងនីមួយៗ។ តាមការរាយការណ៍ ផ.យ.អ.ជ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ត្រូវបានរៀបចំស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ អាស្រ័យហេតុនេះ ស្ថិតិផ្លូវការ និងសូចនាករ ដែលផលិតដោយក្រសួង ស្ថាប័ននីមួយៗ ត្រូវបានរាយការណ៍ថាមានប្រយោជន៍ ក្នុងការវាស់វែងភាពរីកចម្រើន និងសមិទ្ធផលរបស់ ផ.យ.អ.ជ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (សូមមើលឧបសម្ព័ន្ធ២: បញ្ជីសូចនាករតាមដានត្រួតពិនិត្យ ផ.យ.អ.ជ)។ ទិន្នន័យស្ថិតិផ្លូវការដែលផលិតដោយប្រព័ន្ធរដ្ឋបាល និងការរាយការណ៍ទិន្នន័យ ត្រូវបានផ្ញើទៅកាន់វិទ្យាស្ថានជាតិស្ថិតិ និងអគ្គនាយកផែនការ នៃក្រសួងផែនការ តាមការស្នើសុំជារៀងរាល់ឆ្នាំ។

សមត្ថភាពរបស់អង្គភាពស្ថិតិ នៃក្រសួងនានាមានភាពខុសគ្នាយ៉ាងខ្លាំង។ ទោះបីតម្រូវការស្ថិតិសម្រាប់ ផ.យ.អ.ជ ដែលភាគច្រើនចាំបាច់ឱ្យមានការផលិតឡើងទាន់ពេលវេលា គឺមានតែក្រសួងចំនួន ៨ ក្នុងចំណោមក្រសួងចំនួន ១៧ ដែលបានជួបពិគ្រោះយោបល់ បង្ហាញពីប្រព័ន្ធរាយការណ៍ និងកត់ត្រាទិន្នន័យរដ្ឋបាលកម្រិតខ្ពស់ ឬល្អ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រសួងភាគច្រើនក្នុងចំណោមក្រសួងចំនួន ៨ ទាំងនោះ ដែលមានអង្គភាពស្ថិតិរឹងមាំ នៅតែប្រឈមដដែលៗ ទៅនឹងបញ្ហាប្រឈមនៅក្នុងការកែលម្អកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលផ្ទៃក្នុងរបស់នាយកដ្ឋានបច្ចេកទេសនីមួយៗ ដែលស្ថិតនៅក្រោមក្រសួងដូចគ្នា។ បញ្ហាប្រឈមរបៀបនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់ យ៉ាងតិចតាមរយៈក្រសួងចំនួន៥។ កិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួល គឺកាន់តែមានបញ្ហាសម្រាប់ក្រសួងផ្សេងៗទៀត ដែលត្រូវបានចាត់ទុកជាការធ្វើឱ្យរីកចម្រើនមួយ និងសមត្ថភាពរបស់អ្នកផលិត និងអ្នកប្រើប្រាស់នៅមានកម្រិតក្នុងការបែងចែកព័ត៌មានទិន្នន័យឱ្យទាន់ពេលវេលា។

តាមរយៈការវាយតម្លៃ បានបង្ហាញថាមានគម្លាតដ៏ធំ រវាងជំនួយផ្នែកហិរញ្ញវត្ថុ និងតម្រូវការក្នុងការផលិតស្ថិតិប្រកបដោយគុណភាព និងគួរឱ្យទុកចិត្ត។ មន្ត្រីទាំងអស់បង្ហាញពីកង្វល់ថា មានការយកចិត្តទុកដាក់កម្រិតទាប ចំពោះសារៈសំខាន់ខាងស្ថិតិ ដោយគណៈគ្រប់គ្រងជាន់ខ្ពស់ តាមរយៈសកម្មភាពអភិវឌ្ឍន៍ជាអាទិភាព។ ដើម្បីលើកស្ទួយគុណភាពទិន្នន័យ ដែលត្រូវផលិតដោយប្រព័ន្ធរបាយការណ៍ និងកត់ត្រាទិន្នន័យរដ្ឋបាលដែលមានស្រាប់ តម្រូវការខាងធនធានហិរញ្ញវត្ថុមិនត្រឹមតែយកទៅប្រើប្រាស់សម្រាប់សកម្មភាពប្រមូល កត់ត្រា និងរាយការណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ជំនួយផ្នែកសកម្មភាពត្រួតពិនិត្យ ការគ្រប់គ្រង និងការបណ្តុះបណ្តាលផងដែរ។

ការកែលម្អកិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួលផ្ទៃក្នុង និងតាមរយៈក្រសួង ពីព្រោះអ្នកផលិត និងអ្នកប្រើប្រាស់ត្រូវការសម្រាប់ការផលិត និងធ្វើឱ្យប្រសើរ នូវគុណភាពស្ថិតិផ្លូវការក្នុងកាលៈទេសៈមានតម្រូវការ តាមរយៈការបង្កើតបន្ថែមនូវប្រព័ន្ធរដ្ឋបាលដែលមានស្រាប់ នៃការរាយការណ៍ និងការកត់ត្រាទិន្នន័យ។

ការកសាងសមត្ថភាព និងការផ្ទេរចំណេះដឹងពីទីប្រឹក្សាបច្ចេកទេសទៅកាន់មន្ត្រីក្នុងស្រុក គឺមានសារៈសំខាន់ណាស់។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងមួយចំនួន ដូចជាក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្ហាញពីភាពជោគជ័យ ក្នុងការផ្ទេរសមត្ថភាពពីទីប្រឹក្សាបច្ចេកទេសទៅកាន់មន្ត្រីក្នុងស្រុក ក្នុងការធ្វើឱ្យប្រសើរនូវសមត្ថភាពផលិតកម្មស្ថិតិ។ ក្រសួងផ្សេងៗទៀត ដែលបានជួបពិភាក្សា មិនទាន់មានមន្ត្រីមានជំនាញគ្រប់គ្រាន់នៅឡើយទេ ឬថាជំនាញទាំងនោះមិនបានផ្ទេរទៅឱ្យមន្ត្រីក្នុងស្រុកប្រកបដោយប្រសិទ្ធភាពនោះទេ។ នេះដោយសារតែទីប្រឹក្សាបច្ចេកទេសសម្រាប់រយៈពេលខ្លី ត្រូវតែបញ្ចប់ការងាររបស់ពួកគេ នៅក្នុងក្របខ័ណ្ឌពេលវេលានោះ ពួកគេទៅមកដោយបន្សល់ទុកនូវគម្រោងមិនអាចប្រើប្រាស់បាននៃប្រព័ន្ធគ្រប់គ្រងទិន្នន័យ ឬថាជំនួយបច្ចេកទេសមិនអាចរកបានបន្ទាប់ពីការបណ្ដុះបណ្ដាល។

ទិន្នន័យផ្លូវការបច្ចុប្បន្ន ដែលផលិតដោយប្រព័ន្ធរដ្ឋបាលដែលមានស្រាប់ត្រូវរាយការណ៍ថាមានលក្ខណៈល្អគួរសម។ ទោះបីជាយ៉ាងណាក៏ដោយ ការយល់ដឹងនូវមានកម្រិតរបស់មន្ត្រី និងអំពីសារៈសំខាន់នៃស្ថិតិបច្ចុប្បន្ន ជារឿយៗកំពុងជះឥទ្ធិពលដល់គុណភាពទិន្នន័យដែលបានផលិតឡើង។ ទាំងនេះត្រូវបានលើកឡើងថាជាកង្វល់យ៉ាងខ្លាំង ពីសំណាក់ក្រសួងដែលបានជួបពិភាក្សា។

ស្ថិតិ និងសូចនាករថ្មី ដែលមានក្នុង ផ.យ.អ.ជ បច្ចុប្បន្នកម្ម នាពេលបច្ចុប្បន្ន តម្រូវឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវតែធ្វើបច្ចុប្បន្នភាពផងដែរ នូវតម្រូវការទិន្នន័យរបស់សូចនាករទាំងនេះ និងរៀបចំឱ្យស្របគ្នាដែរជាមួយនឹងផែនការមេស្ថិតិ និងកំណត់ថាតើនរណាគួរមានទំនួលខុសត្រូវក្នុងការផលិតស្ថិតិទាំងនេះ។

អ្នកប្រើប្រាស់បាននិយាយថា កិច្ចសម្របសម្រួល និងកិច្ចសហប្រតិបត្តិការដែលមានប្រសិទ្ធភាពត្រូវតែមានការកែលម្អ ដើម្បីចែករំលែកព័ត៌មានបច្ចុប្បន្នភាពឱ្យទាន់ពេលវេលា សម្រាប់ទាំងការធ្វើគោលនយោបាយ និងការផលិតជារបាយការណ៍ និងតាមមធ្យោបាយទំនាក់ទំនងផ្សេងៗទៀត។ មានការលើកឡើងផងដែរ ពីភាពច្របូកច្របល់នៃទិន្នន័យដូចគ្នា ដែលបានផលិតដោយក្រសួងផ្សេងៗគ្នា ឧទាហរណ៍ ការកំណត់និយមន័យរបស់ពលកម្មកុមារជាដើម។ អ្នកប្រើប្រាស់

ទិន្នន័យបានលើកឡើងផងដែរ ពីតម្រូវការខាងការកសាងសមត្ថភាពស្ថិតិ និងការបណ្ដុះបណ្ដាលក្នុងការប្រមូលទិន្នន័យ ការត្រួតពិនិត្យ ការវិភាគ និងការបកស្រាយទិន្នន័យ។

អនុសាសន៍ទាំងឡាយដើម្បីធ្វើឱ្យប្រសើរនូវគុណភាពស្ថិតិ និងប្រព័ន្ធស្ថិតិជាតិ ការរៀបចំឱ្យស្របនឹងច្បាប់ស្ថិតិ ផែនការមេស្ថិតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងការអភិវឌ្ឍយុទ្ធសាស្ត្រតាមវិស័យ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ គួរមានការឆ្លុះបញ្ចាំងក្នុងការត្រួតពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិផែនការមេស្ថិតិ ។

ការកើនឡើងនូវតួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិ ក្នុងការផ្ដល់នូវការកសាងសមត្ថភាពស្ថិតិ ការត្រួតពិនិត្យនិងការគ្រប់គ្រងនឹងជួយលើកស្ទួយគុណភាពផលិតកម្មស្ថិតិរបស់ក្រសួងនីមួយៗ។ បញ្ហាប្រឈមរបស់សូចនាករតាមបទដ្ឋាន និងតម្រូវការកើនឡើងសម្រាប់ស្ថិតិផ្លូវការ ត្រូវបានផ្ដល់អនុសាសន៍ឱ្យធ្វើការដោះស្រាយ ឬដាក់ជាប្រធានបទសម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ ឬនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិ។ យុទ្ធសាស្ត្រក្នុងការទទួលបានមូលនិធិសម្រាប់កសាងសមត្ថភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងការងារស្ថិតិចាំបាច់ត្រូវមានការដោះស្រាយ។ ជាចុងក្រោយ វាមានសារៈសំខាន់ដើម្បីធ្វើការកែលម្អការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ រវាងអ្នកផលិតស្ថិតិ និងអ្នកប្រើប្រាស់ ដែលស្ថិតនៅក្រោមជំនួយបច្ចេកទេសខ្លាំងជាងមុន និងការគ្រប់គ្រងពីវិទ្យាស្ថានជាតិស្ថិតិ។

### ៣.៥.២ ការសម្ភាសន៍ជាមួយដៃគូអភិវឌ្ឍន៍

ផ្នែកមួយទៀត នៃដំណើរការវាយតម្លៃពាក់កណ្ដាលអាណត្តិផែនការមេស្ថិតិ គឺការជួបពិគ្រោះយោបល់ជាមួយអង្គការដៃគូអភិវឌ្ឍន៍ ដែលជួយគាំទ្រប្រព័ន្ធស្ថិតិជាតិ ក្នុងនាមជាដៃគូអភិវឌ្ឍន៍ ឬដោយមានជំនួយបច្ចេកទេស។ លទ្ធផលមួយចំនួន ពីការពិគ្រោះយោបល់ទាំងនោះ និងពីកិច្ចប្រជុំអនុក្រុមការងារបច្ចេកទេសស្ថិតិ ដែលដឹកនាំវិទ្យាស្ថានជាតិស្ថិតិ ផែនការមេស្ថិតិត្រូវបានគេមើលឃើញថាជាផ័ត្រសម្រាប់ប្រព័ន្ធស្ថិតិជាតិ និងត្រូវបានប្រើប្រាស់តាមមធ្យោបាយផ្សេងៗ។ តាមរយៈដៃគូអភិវឌ្ឍន៍ដែលបានផ្ដល់កិច្ចសម្ភាសន៍ ខ្លះថាបានប្រើប្រាស់វាជាឯកសារមូលដ្ឋាន ហើយខ្លះទៀតមិនបានដឹងពីខ្លឹមសារផែនការនេះទេ។ ការកសាងសមត្ថភាព និងការសម្រេចបាននូវការទទួលបានហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព សម្រាប់ប្រព័ន្ធស្ថិតិជាតិ គឺជាផ្នែកដ៏មានសារៈសំខាន់សម្រាប់ម្ចាស់ជំនួយ។ នៅពេលបច្ចុប្បន្ននេះ ផែនការមេស្ថិតិត្រូវបានគេមើលឃើញថាជាផែនការទ្រឹស្ដីសម្រាប់ប្រព័ន្ធស្ថិតិ ហើយក៏ត្រូវបានគេមើលឃើញផងដែរថា វាហាក់មិនបានធ្វើតាមដូចក្នុងការអនុវត្តឡើយ (យោងទៅតាមកាលៈទេសៈធនធានហិរញ្ញវត្ថុ និងធនធាន

មនុស្ស)។ អ្នកប្រើប្រាស់មិនប្រាកដថាតើត្រូវធ្វើអង្កេត និងជំរឿនមួយណាទាំងអស់ ឬនៅពេលខាងមុខ ឬនៅពេលដែលមានការបោះពុម្ព និងមានផែនការបោះពុម្ពនូវតួលេខទាំងឡាយ។

ត្រូវមានការពង្រឹងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីផ្ដល់ដល់ប្រព័ន្ធស្ថិតិជាតិនូវបច្ចេកទេសដ៏ល្អប្រសើរ។ មានតម្រូវការសម្រាប់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីគាំទ្រក្រសួងនានាក្នុងការងាររបស់ពួកគេ ដោយមានការផលិតស្ថិតិ ជាពិសេសទៅលើការគាំទ្រផ្នែកវិធីសាស្ត្រ និងបច្ចេកទេស។ វាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការគ្រប់គ្រង ដើម្បីឱ្យមើលឃើញថាជាផ្នែកដ៏គួរឱ្យទុកចិត្ត និងការដែលថាអង្គការជាដៃគូអភិវឌ្ឍន៍មានជំនឿទុកចិត្តយ៉ាងខ្លាំងចំពោះបញ្ហានេះ។ នេះគឺនិយាយអំពីតម្លាភាព និងប្រព័ន្ធដែលមានមុខងារដ៏ប្រសើរសម្រាប់ការធ្វើផែនការ និងការតាមដានសម្រាប់រយៈពេលខ្លី និងរយៈពេលវែង ។

ដៃគូអភិវឌ្ឍន៍ភាគច្រើន ពេញចិត្តនឹងលទ្ធផលនៃការចូលរួមដោយអង្គការរបស់ពួកគេ ដោយសារការពិតដែលថាលទ្ធផលបានបំពេញតាមតម្រូវការរបស់អ្នកប្រើប្រាស់។ មានគម្លាតជាច្រើនអំពីតម្រូវការព័ត៌មាន និងអំពីការអង្កេត/ជំរឿនណាខ្លះដែលត្រូវផ្ដល់ទិន្នន័យសម្រាប់សូចនាករដែលកំណត់។ ការគាំទ្រពីដៃគូអភិវឌ្ឍន៍ មានការចែកជាផ្នែក។ មានដៃគូអភិវឌ្ឍន៍ជាច្រើនគាំទ្រក្នុងផ្នែកនេះ ហើយពួកគេស្ទើរតែទាំងអស់មានគំនិតផ្ទាល់ខ្លួនអំពីវិសាលភាពនៃការងារ និងអំពីផ្នែកណាមួយនៃប្រព័ន្ធស្ថិតិ ឬស្ថាប័ន ដែលត្រូវការឱ្យមានការពង្រឹងនោះ។ ពុំមានកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិការរវាងដៃគូអភិវឌ្ឍន៍ផ្សេងៗគ្នា ក្នុងការធ្វើឱ្យមានការអនុវត្តការងារប្រកបដោយប្រសិទ្ធនោះទេ។ សម្រាប់ពេលបច្ចុប្បន្ននេះ វាមានសារៈសំខាន់ណាស់ ដែលបណ្ដាញក្រុមការងារបច្ចេកទេសដើរតួនាទីជា "អ្នកកាច់ចង្កូត" ។

ផែនការមេស្ថិតិ ពិតជាពិពណ៌នាពីតម្រូវការអ្នកប្រើប្រាស់បានយ៉ាងប្រសើរ នៅកម្រិតជាតិ ប៉ុន្តែនៅមានចន្លោះសម្រាប់ការធ្វើការកែលម្អ ដែលមានការសង្កត់ធ្ងន់កាន់តែច្រើននៅកម្រិតក្រោមជាតិ និងកាន់តែច្រើនទៅលើការវិភាគ និងគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) រយៈពេលវែង។

# ផ្នែកទី២. ផែនការមេស្ថិតិ

## ៤. ផែនការមេស្ថិតិ

### ៤.១. គម្រោងផែនការមេស្ថិតិ

ផែនការមេស្ថិតិ គឺជាឯកសារយុទ្ធសាស្ត្រ ដែលកំណត់នូវទស្សនវិស័យ និងគោលដៅសម្រាប់ប្រព័ន្ធស្ថិតិជាតិ។ វាគឺជាផែនទីបង្ហាញអំពីថាតើប្រព័ន្ធស្ថិតិគួរទៅកន្លែងណា និងទៅដល់ទីនោះដោយរបៀបណា។ វាគឺជាក្របខ័ណ្ឌការងារស្ថិតនៅក្នុងចំណុចអាទិភាពតម្រូវការ និងធនធានដែលត្រូវយកមកពិចារណា ប្រៀបធៀបទៅនឹងគោលដៅ និងទស្សនវិស័យ។ ដោយប្រើប្រាស់ផែនការមេស្ថិតិជាឧបករណ៍គ្រប់គ្រង ស្ថិតិនឹងត្រូវបានផលិតដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិភាពដែលបានដាក់ចេញ។ ផែនការមេស្ថិតិគឺជាឯកសាររស់ ដែលមានភាពបត់បែន មានការតាមដានត្រួតពិនិត្យឡើងវិញ និងកែតម្រូវនៅក្នុងពេលកំណត់ណាមួយជាទៀងទាត់។

ទស្សនវិស័យកំណត់ក្នុងផែនការយុទ្ធសាស្ត្រ ២០០២-២០០៦ ឈរលើមូលដ្ឋាននៃគោលការណ៍ ៥ ចំណុចៈ ភាពសំខាន់ ភាពសុចរិត ភាពអាចប្រើប្រាស់បាន វិជ្ជាជីវៈនិយម និងជំនឿទុកចិត្ត។ តាមរយៈនេះ គឺមាននូវ បេសកកម្មដូចខាងក្រោមៈ

*បេសកកម្មរបស់វិទ្យាស្ថានជាតិស្ថិតិ គឺការសម្របសម្រួល ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយគុណភាពខ្ពស់ និងស្ថិតិផ្លូវការ ដើម្បីជួយដល់ការធ្វើការសម្រេចចិត្តដែលមានការផ្ដល់ព័ត៌មាន ការជជែកវែកញែក និងការពិភាក្សាស្ថិតនៅក្នុងរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ខេត្ត និងឃុំ ផ្នែកឯកជន និងប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ។*

កម្មវត្ថុមាន ៧ ៖

១. សម្របសម្រួល និងធ្វើឱ្យប្រសើរប្រព័ន្ធស្ថិតិជាតិនៃព្រះរាជាណាចក្រកម្ពុជា
២. វិទ្យាស្ថានជាតិស្ថិតិផ្ដល់សេវាកម្មស្ថិតិ ទាន់ពេលវេលា មានការពាក់ព័ន្ធ មានការឆ្លើយ តប និងគោរពគោលការណ៍សុចរិតភាព និងគុណភាព
៣. ផ្ដល់ព័ត៌មាន និងបង្កើនការប្រើប្រាស់ស្ថិតិផ្លូវការ
៤. ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពស្ថិតិអន្តរជាតិ ទាំងនេះមានសារៈសំខាន់សម្រាប់ព្រះរាជាណាចក្រកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍
៥. ស្ថាប័នដែលលើកទឹកចិត្តដល់ការសិក្សាស្វែងយល់ ការច្នៃប្រឌិត និងការអនុវត្តកម្រិតខ្ពស់នៅក្នុងសកម្មភាព និងការអភិវឌ្ឍស្ថិតិ
៦. មានជំនឿទុកចិត្ត និងកិច្ចសហប្រតិបត្តិការ ក្នុងការផ្ដល់ទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ

៧. មានការទទួលស្គាល់កម្រិតខ្ពស់ និងគាំទ្រចំពោះវិទ្យាស្ថានជាតិស្ថិតិ ពីសំណាក់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងសហគមន៍

ចំណុចសំខាន់ៗនៃផែនការដែលមានក្នុងឯកសារនេះ បានចង្អុលបង្ហាញនូវកត្តាប្រឈមមួយចំនួន។ កត្តាប្រឈមទាំងនោះ គឺដោយសារធនធាននៅមានកម្រិត និងសមត្ថភាពមិនទាន់គ្រប់គ្រាន់នៅក្នុងវិទ្យាស្ថានជាតិស្ថិតិ និងនៅតាមស្ថាប័នដទៃទៀត។ ប៉ុន្តែវាមានសារៈសំខាន់ពីព្រោះវាបង្ហាញនូវទស្សនៈប្រមូលផ្តុំមួយ នៅពេលអនាគតនៃប្រព័ន្ធស្ថិតិជាតិ។ ដើម្បីសម្រេចបំណងប្រាថ្នាទាំងនេះ ប្រកបដោយនិរន្តរភាព ប្រព័ន្ធស្ថិតិជាតិត្រូវតែមានលក្ខណៈគ្រប់គ្រាន់ដោយខ្លួនឯង និងមិនត្រូវពឹងផ្អែកទៅលើការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ទាំងស្រុងនោះឡើយ។

## ៤.២ ប្រតិបត្តិការ នៃផែនការមេស្ថិតិ

ផែនការមេស្ថិតិគឺជាឯកសារយុទ្ធសាស្ត្រកំណត់នូវទស្សនវិស័យ និងគោលដៅសម្រាប់ប្រព័ន្ធស្ថិតិជាតិ។ វាគឺជាឯកសារគ្រឹះ ពីព្រោះវាក៏បង្ហាញផងដែរថាតើស្ថិតិប្រភេទណាគួរត្រូវផលិតឡើង ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អ្នកប្រើប្រាស់នៅក្នុងសង្គមកម្ពុជា ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។ វានឹងបង្ហាញថាតើប្រព័ន្ធស្ថិតិគួរសំដៅទៅកន្លែងណា ប៉ុន្តែវាមិនច្បាស់អំពីថាតើនឹងទៅដល់ទីនោះដោយរបៀបណា។ ផែនការមេស្ថិតិគឺជាក្របខ័ណ្ឌការងារសកម្មភាពអាទិភាព តម្រូវការនានា និងធនធានដែលអាចយកមកគិតពិចារណាទាក់ទងនឹងទស្សនវិស័យ និងគោលដៅ។ កង្វះខាត និងការពុំមានមូលនិធិទ្រទ្រង់រយៈពេលវែងសមស្រប វានឹងបង្កើតនូវផលវិបាកសម្រាប់ផែនការមេស្ថិតិ ដើម្បីបំពេញតួនាទីពិតប្រាកដ ដែលថាវាជាឧបករណ៍គ្រប់គ្រងនោះ។

វាមានសារៈសំខាន់ដែលថាផែនការនេះ ធ្វើការរួមបញ្ចូលនូវក្របខ័ណ្ឌការងាររបស់អាស៊ាន និងក្របខ័ណ្ឌការងារស្ថិតិសំខាន់ៗដទៃៗទៀត។ ការងារប្រកបដោយគុណភាព គឺជាការងារដែលត្រូវបន្តធ្វើ ហើយក្រមសីលធម៌ គឺជាផ្នែកមួយដ៏មានសារៈសំខាន់។ គោលបំណងស្ថិតិផ្លូវការរបស់ប្រទេសកម្ពុជា គឺការផលិតប្រកបដោយនិរន្តរភាព ជាមួយនឹងភាពសំខាន់ ភាពសុចរិត ភាពអាចប្រើប្រាស់បាន ភាពមានវិជ្ជាជីវៈ និងភាពគួរឱ្យជឿទុកចិត្ត។

ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័ន ដែលត្រូវបានធ្វើឡើងមួយចំនួន មានលក្ខណៈគ្រប់គ្រាន់ ប៉ុន្តែខ្លះទៀតនៅមិនទាន់គ្រប់គ្រាន់នៅឡើយ។ ការផ្តល់មូលនិធិ និងប្រាក់បៀវត្ស/ប្រាក់ឧបត្ថម្ភ ព្រមទាំងប្រព័ន្ធសម្រាប់ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ អ្នកប្រើប្រាស់ និងអ្នកផលិតស្ថិតិសម្រាប់ការធ្វើផែនការ និងតាមដានបន្ត ក៏ដូចជាការរៀបចំការងារសម្របសម្រួល និង

ពិគ្រោះយោបល់ត្រូវមានការពង្រឹង ដើម្បីឱ្យប្រព័ន្ធស្ថិតិជាតិក្លាយជាប្រព័ន្ធវិមជ្ឈការប្រកបដោយប្រសិទ្ធភាព។ វាមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីអនុវត្តនូវប្រព័ន្ធមួយក្នុងការប៉ាន់ស្មានការចំណាយសម្រាប់ការផលិតស្ថិតិ ដែលស្ថិតនៅក្នុងប្រព័ន្ធវិមជ្ឈការ ដើម្បីឱ្យមានមូលដ្ឋានគ្រឹះដ៏ល្អមួយសម្រាប់ការផ្ដល់អាទិភាព និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។

# ៥. កម្មវិធីហេដ្ឋារចនាសម្ព័ន្ធស្ថិតិ

## ៥.១ ក្របខ័ណ្ឌច្បាប់

ក្របខ័ណ្ឌច្បាប់គ្របដណ្តប់នូវផ្នែកសំខាន់ៗ ក្នុងគោលបំណងធ្វើឱ្យប្រព័ន្ធស្ថិតិជាតិមានដំណើរល្អ និងផ្តល់នូវមូលដ្ឋានគ្រឹះដ៏ល្អផងដែរ សម្រាប់ការរៀបចំការងារស្ថិតិ។ កម្មវិធីហេដ្ឋារចនាសម្ព័ន្ធស្ថិតិចង្អុលបង្ហាញយ៉ាងច្បាស់ថាតើអ្វីត្រូវធ្វើ និងតាមរបៀបណា និងនរណាត្រូវធ្វើ។ វាបានបញ្ជាក់យ៉ាងច្បាស់ និងអំពីមហិច្ឆតាខ្ពស់សម្រាប់ប្រព័ន្ធនេះ។ របាយការណ៍ពិនិត្យឡើងវិញនេះ ផ្តល់ព័ត៌មានដោយផ្ទាល់អំពីកម្មវិធីហេដ្ឋារចនាសម្ព័ន្ធស្ថិតិ គឺវាមានលក្ខណៈសុទិដ្ឋិនិយមខ្លាំងពេក ដោយផ្តោតទៅលើចំនួនមន្ត្រីដែលមានជំនាញនៅវិទ្យាស្ថានជាតិស្ថិតិ និងនៅតាមក្រសួង/ស្ថាប័នផ្សេងៗទៀតនៅក្នុងប្រព័ន្ធស្ថិតិជាតិ ហើយក្រៅពីនេះ គឺដោយសារកង្វះប្រភពធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងមាននិរន្តរភាព។ កង្វះខាតធនធានមនុស្ស និងហិរញ្ញវត្ថុនៅវិទ្យាស្ថានជាតិស្ថិតិ និងតាមក្រសួង ស្ថាប័ននានា ជាកត្តានាំឱ្យវិទ្យាស្ថានជាតិស្ថិតិ មិនអាចមានលទ្ធភាពបង្កើតនូវការិយាល័យត្រួតពិនិត្យស្ថិតិ (Statistical Clearing House) បានឡើយ។ អាស្រ័យហេតុនេះ មហិច្ឆតានេះគួរត្រូវចាត់ទុកថាជាគោលដៅរយៈពេលវែង និងគួរមានលក្ខណៈជាក់លាក់ជាងនេះបន្ថែមទៀត ឧទាហរណ៍ ទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម តែមួយមុខដូចមាននៅក្នុងករណីនៃប្រទេសអូស្ត្រាលី។

មានភាពខុសគ្នាក្នុងការប្រើប្រាស់និយមន័យមួយចំនួន នៅក្នុងច្បាប់ស្ថិតិ និងក្នុងអនុក្រឹត្យដែលពាក់ព័ន្ធ។ ក្របខ័ណ្ឌច្បាប់ត្រូវតែគាំទ្រដល់ដំណើរការការងារ និងត្រូវតែមានភាពច្បាស់លាស់អំពីការទទួលខុសត្រូវ។ មានការផ្តល់អនុសាសន៍ឱ្យមានការពិនិត្យកែសម្រួលឡើងវិញ នូវច្បាប់ស្ថិតិ និងអនុក្រឹត្យផងដែរ ដើម្បីធ្វើការពង្រឹងក្របខ័ណ្ឌការងារនេះឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។ ការពិនិត្យឡើងវិញនេះត្រូវពិនិត្យឱ្យច្បាស់លាស់ និងឱ្យមានការឯកភាពទូលំទូលាយដូច្នេះ នៅពេលដែលធ្វើសុខដុមនីយកម្មច្បាប់ស្ថិតិ និងអនុក្រឹត្យពាក់ព័ន្ធ នឹងធានាបានការគោរពតាមការទទួលខុសត្រូវ ការប្រើប្រាស់ពាក្យ និងនិយមន័យ កម្រិតនៃភាពលម្អិត និងជៀសវាងការបាត់បង់នូវចំណុចសំខាន់ៗនានា ឧទាហរណ៍ដូចជា អំពីគុណភាព និងភាពងាយស្រួលសម្រាប់អ្នកឆ្លើយតបជាដើម។ ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំបន្តបន្ទាប់មកទៀត ក៏អាចធ្វើវិសោធនកម្មច្បាប់ស្ថិតិបានផងដែរ។

## ៥.២ ការអភិវឌ្ឍធនធានមនុស្ស

មានភាពរីកចម្រើនគួរឱ្យកត់សំគាល់នៅក្នុងវិស័យនេះ ហើយរាល់ចំណុចទាំងអស់ដែលត្រូវបានលើកឡើងនៅក្នុងផែនការមេស្ថិតិនេះ គឺនៅតែមានការអនុវត្តនៅឡើយ។ យោងទៅតាម

ផែនការមេស្ថិតិ សមត្ថភាពនៅក្នុងប្រព័ន្ធស្ថិតិជាតិ កំពុងចាប់ផ្តើមពីមូលដ្ឋានកម្រិតទាបមួយ។ ទោះបីសមត្ថភាពនៅវិទ្យាស្ថានជាតិស្ថិតិ និងនៅតាមក្រសួងធំៗមួយចំនួន មានភាពប្រសើររួចហើយក៏ដោយក្តី ក៏ប៉ុន្តែក្រសួង/ស្ថាប័នជាច្រើនទៀតនៃប្រព័ន្ធស្ថិតិជាតិ នៅតែមានកម្រិតទាបនៅឡើយ។ មានតម្រូវការដ៏ធំ សម្រាប់វគ្គបណ្តុះបណ្តាលស្ថិតិមូលដ្ឋាន។ ក្នុងឆ្នាំ ២០១២ វគ្គបណ្តុះបណ្តាលស្ថិតិមូលដ្ឋាន ត្រូវបានធ្វើឡើងសម្រាប់មន្ត្រីស្ថិតិរបស់វិទ្យាស្ថានជាតិស្ថិតិ។ វគ្គបណ្តុះបណ្តាលដូចគ្នានេះ នឹងផ្តល់ទៅឱ្យក្រសួង/ស្ថាប័ននានា ដើម្បីបង្កើនជំនាញស្ថិតិសម្រាប់មន្ត្រីដែលផលិតស្ថិតិផ្លូវការ។ វគ្គបណ្តុះបណ្តាលនេះ បង្រៀនដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិជាភាសាខ្មែរ ហើយក៏ជាឱកាសមួយផ្តល់ឱ្យវិទ្យាស្ថានជាតិស្ថិតិ ក្នុងការផ្តល់ការបណ្តុះបណ្តាលទៅឱ្យក្រសួងនានា ដែលជាផ្នែកមួយនៃការទទួលខុសត្រូវរបស់ វិទ្យាស្ថានជាតិស្ថិតិ ទាក់ទងទៅនឹងការងារសម្របសម្រួលផងដែរ។ វាគឺជាជំហានដំបូងសម្រាប់ឱ្យប្រទេសកម្ពុជាមានលក្ខណៈម្ចាស់ការដោយខ្លួនឯង ដោយមិនពឹងផ្អែកលើទីប្រឹក្សាអន្តរជាតិ នៅពេលដែលមានការរៀបចំវគ្គបណ្តុះបណ្តាលស្ថិតិដូចនេះតទៅទៀត។ សម្រាប់ឆ្នាំខាងមុខ វគ្គបណ្តុះបណ្តាលស្ថិតិកម្រិតខ្ពស់ វិទ្យាស្ថានជាតិស្ថិតិ នឹងនៅតែត្រូវការជំនួយបច្ចេកទេសពីអ្នកជំនាញអន្តរជាតិ ដោយមានការសហការជាមួយមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ។ ក៏ប៉ុន្តែមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ គឺជាអ្នកទទួលខុសត្រូវក្នុងវគ្គបណ្តុះបណ្តាលនេះភាគច្រើន ដោយខ្លួនឯង ច្រើនជាងការទទួលខុសត្រូវដោយអ្នកជំនាញអន្តរជាតិ។

អង្គការ JICA បានបណ្តុះបណ្តាលមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ ក្នុងកំឡុងការអនុវត្តជំរឿនប្រជារាស្ត្រឆ្នាំ ២០០៨ និងជំរឿនសហគ្រាសឆ្នាំ ២០១១។ វគ្គបណ្តុះបណ្តាលនេះ គឺជាវគ្គមួយមានរយៈពេលខ្លី និងធ្វើឡើងតាមរយៈការងារផ្ទាល់ដោយទីប្រឹក្សាអន្តរជាតិ។ អង្គការ JICA ក៏មានផែនការបណ្តុះបណ្តាលមន្ត្រីថ្នាក់ខេត្ត នៅឆ្នាំ ២០១២ ក្នុងការប្រើប្រាស់ស្ថិតិតំបន់។

រៀងរាល់ឆ្នាំមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ ត្រូវបានបញ្ជូនឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន សម្រាប់រយៈពេលពី ៣ ទៅ ៤ ខែ។ ការបណ្តុះបណ្តាលក្រៅប្រទេសរយៈពេលខ្លីផ្សេងទៀត ផ្តល់ដោយដៃគូអភិវឌ្ឍន៍មួយចំនួន។ មន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិប្រហែល ១០០ នាក់ ទទួលបានវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនៅប៉ុន្មានឆ្នាំចុងក្រោយនេះ និងចូលរួមក្នុងសិក្ខាសាលាបច្ចេកទេស និងកិច្ចប្រជុំនានា។

អង្គការ UNFPA បានបណ្តុះបណ្តាលមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ តាមរយៈដំណើរការការងារនៃជំរឿនប្រជារាស្ត្រ ឧទាហរណ៍ ការជ្រើសរើសសំណាកគំរូ ការកែឆ្នៃទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង និងបន្តវគ្គបណ្តុះបណ្តាលដើម្បីរៀបចំអង្កេតចន្លោះជំរឿនក្នុងឆ្នាំ ២០១៣។ វិទ្យាស្ថានជាតិស្ថិតិ និងការិយាល័យស្ថិតិនៅក្រសួងសុខាភិបាល ក៏បានទទួលវគ្គ

បណ្តុះបណ្តាល ក្នុងកំឡុងអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០១០ និងឆ្នាំ ២០១២។ អង្គការ UNICEF ជួយគាំទ្រវិទ្យាស្ថានជាតិស្ថិតិក្នុងការរៀបចំប្រព័ន្ធទិន្នន័យសូចនាករសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ដោយមានការបណ្តុះបណ្តាលមន្ត្រីរបស់ប្រព័ន្ធស្ថិតិជាតិជាទៀងទាត់ខាងផ្នែក CAMInfo និង ICT ដើម្បីជួយឱ្យកាន់តែប្រសើរឡើងនូវជំនាញកុំព្យូទ័រ។

អង្គការ Sida ជួយគាំទ្រវិទ្យាស្ថានជាតិស្ថិតិ ដើម្បីបង្កើនសមត្ថភាពប្រកបដោយនិរន្តរភាពនៅវិទ្យាស្ថានជាតិស្ថិតិ។ គម្រោងដំណាក់កាលទី២ ការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង និងផ្នែកគ្រប់គ្រង ត្រូវបានរៀបចំឡើង។ គោលបំណងមួយក្នុងចំណោមគោលបំណងចម្បងៗ នៃគម្រោងកសាងសមត្ថភាពស្ថាប័ន នៅដំណាក់កាលទី៣ គឺការបង្កើនសមត្ថភាពរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីបន្តផលិតស្ថិតិនៃការអង្កេតគ្រួសារ។ គម្រោងនេះពឹងផ្អែកទៅលើជំនួយបច្ចេកទេសរយៈពេលវែង និងរយៈពេលខ្លី ដែលវគ្គរយៈពេលខ្លី ក្នុងជំនាញអង្កេតដូចជាការវិភាគស្ថិតិ និង ICT ត្រូវបានធ្វើឡើងរួមជាមួយវគ្គបណ្តុះបណ្តាលនៅកន្លែងធ្វើការ។ ក្រៅពីជំនួយផ្នែកបច្ចេកទេស Sida បានផ្តល់ឱ្យមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិច្រើនជាង ៥០ នាក់ នូវឱកាសបង្កើនជំនាញភាសាអង់គ្លេស តាមរយៈវគ្គបណ្តុះបណ្តាលភាសាអង់គ្លេស។ ទាំងអគ្គនាយក និងអគ្គនាយករងមួយចំនួន បានចូលរួមជាទៀងទាត់ នូវវគ្គបណ្តុះបណ្តាលគ្រប់គ្រងដែលដឹកនាំដោយទីប្រឹក្សាអន្តរជាតិ។ ជំនាញដឹកនាំ និងគ្រប់គ្រងមានកម្រិតខ្ពស់ខ្លាំងនៅពេលសព្វថ្ងៃបើប្រៀបធៀបនឹងឆ្នាំ២០០៩។

ទាំងសមត្ថភាពចាត់ចែង និងគ្រប់គ្រង គឺពឹងផ្អែកលើសមត្ថភាពមន្ត្រី។ វាមានសារៈសំខាន់ណាស់ មន្ត្រីនឹងទទួលបានការបណ្តុះបណ្តាលតាមរយៈវគ្គផ្សេងៗ និងបណ្តុះបណ្តាលនៅកន្លែងធ្វើការ។ បន្ថែមជាងនេះទៀត ដើម្បីកសាងសមត្ថភាពប្រកបដោយនិរន្តរភាព មន្ត្រីស្ថិតិត្រូវតែអនុវត្តការងារតាមនាយកដ្ឋាន ដែលពួកគេទទួលបានការបណ្តុះបណ្តាល។ នៅពេលបច្ចុប្បន្ន មន្ត្រីមានការផ្លាស់ប្តូររវាងគម្រោងផ្សេងៗគ្នា ដើម្បីទទួលបានប្រាក់បៀវត្សច្រើន ដែលជារឿយៗទទួលការងារដែលមិនស្ថិតនៅក្រោមទំនួលខុសត្រូវរបស់ពួកគេ ដូចជាការដាក់លេខកូដ និងបញ្ចូលទិន្នន័យជាដើម។ អាស្រ័យហេតុនេះ មន្ត្រីដែលធ្វើការងារបិតថេរនឹងការងារអង្កេតជាទៀងទាត់ និងការវិភាគស្ថិតិនៅតាមនាយកដ្ឋាននីមួយៗ នឹងមានការធានាថាទទួលបានការកសាងសមត្ថភាពប្រកបដោយនិរន្តរភាពច្រើនជាងមុន។ គំនិតមាននៅក្នុងផែនការមេស្ថិតិនាពេលបច្ចុប្បន្ន ស្តីពីការជ្រើសរើស និងតម្លើងឋានៈមន្ត្រី គឺនៅតែត្រូវលើកមកធ្វើការពិភាក្សា។ ការពិនិត្យឱ្យបានប្រសើរជាងមុន នៅក្នុងដំណើរការជ្រើសរើសមន្ត្រី និងការតម្លើងឋានៈ ដោយផ្អែកលើគុណសម្បត្តិ នឹងធានាថា នឹងទទួលបានមន្ត្រីប្រកបដោយគុណសម្បត្តិ ដែលមានមុខតំណែងសមរម្យសម្រាប់ជំនាញរបស់ពួកគេ។

ជាទូទៅជំនួយផ្នែកបច្ចេកទេស ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ផ្សេងៗ បានរួមចំណែកគួរឱ្យកត់សំគាល់ក្នុងការកសាងសមត្ថភាពនៅវិទ្យាស្ថានជាតិស្ថិតិ នាប៉ុន្មានឆ្នាំថ្មីៗនេះ។ ទោះជាយ៉ាងណាក៏ដោយ ការកសាងសមត្ថភាព ត្រូវតែបន្តនៅឆ្នាំខាងមុខទៀត។ បន្ថែមជាងនេះទៀត សកម្មភាពបណ្តុះបណ្តាល គួររៀបចំផែនការឱ្យបានកៀកក្នុងកិច្ចសហប្រតិបត្តិជាមួយវិទ្យាស្ថានជាតិស្ថិតិ និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត។ តាមរយៈកិច្ចសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ក្នុងការធ្វើផែនការ និងការអនុវត្តនូវការបណ្តុះបណ្តាល ស្ថិតនៅក្នុងប្រព័ន្ធការកសាងសមត្ថភាពនឹងមានប្រសិទ្ធភាពច្រើនជាងមុន។

## ៥.៣ ការបង្កើន/ការអភិវឌ្ឍប្រតិបត្តិការស្ថិតិ

តាមផ្នែកមួយចំនួន មានភាពរីកចម្រើនដូចមានក្នុងផែនការ និងអនុសាសន៍នៅក្នុងសិក្ខាសាលាកសាងសមត្ថភាពស្ថិតិ និងយោងតាមផែនការដែលបានកំណត់នៅលើគេហទំព័រប្រព័ន្ធផ្សព្វផ្សាយទិន្នន័យទូទៅ ប៉ុន្តែនៅមានការងារច្រើនត្រូវធ្វើបន្ថែមទៀត។ ហេតុផលមួយដែលនៅពុំទាន់បានបង្កើនឡើង គឺធនធានហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលនៅមានកម្រិត និងការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍នៅមានភាពជាផ្នែកៗនៅឡើយ។ មានដៃគូអភិវឌ្ឍន៍ជាច្រើនគាំទ្រតែមួយផ្នែក ហើយពួកគេភាគច្រើនមានទស្សនៈរៀងៗខ្លួនផ្តោតទៅលើតែវិសាលភាពការងារ ឬផ្នែកណាមួយនៃប្រព័ន្ធ/ស្ថាប័ន ដែលត្រូវធ្វើការពង្រឹងតែប៉ុណ្ណោះ។ បញ្ហាទាំងនេះទាមទារឱ្យមានការជជែកវែកញែក និងកិច្ចសហប្រតិបត្តិការរវាងអ្នកអនុវត្តផ្សេងៗគ្នា ដើម្បីធ្វើឱ្យការងារកាន់តែមានប្រសិទ្ធភាពខ្ពស់។ ការងារផ្សេងៗទៀតដែលត្រូវធ្វើនោះ គឺការជួយគាំទ្រខាងផ្នែក បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) វិធីសាស្ត្រ (បច្ចុប្បន្នកំពុងអភិវឌ្ឍន៍នូវវិធីសាស្ត្រសម្រាប់វាស់វែងភាពក្រីក្រ) និងជំរឿនកសិកម្ម ឆ្នាំ ២០១៣។

# ៦. កម្មវិធីការងារស្ថិតិ

## ៦.១ ទស្សនវិស័យសម្រាប់អនាគត

ផ្នែកទី៤ ទស្សនវិស័យ បេសកកម្ម និងគោលបំណងសម្រាប់រយៈពេលរហូតដល់ឆ្នាំ ២០១៥ ត្រូវបានកំណត់ ហើយគឺជាទស្សនវិស័យដ៏វែងឆ្ងាយមួយ។ ដើម្បីថែរក្សា និងកសាងប្រព័ន្ធស្ថិតិជាតិឱ្យបានរឹងមាំជាងនេះសម្រាប់នាពេលអនាគត មានសកម្មភាពជាច្រើនកំពុងបន្ត និងសកម្មភាពផ្សេងទៀត នឹងចាប់ផ្តើម សកម្មភាពខ្លះជាការស្រមើស្រមៃ និងខ្លះទៀតមានលក្ខណៈប្រាកដនិយមខ្លាំង។ ចំណុចខ្លះ គឺការរួមបញ្ចូលនូវក្របខ័ណ្ឌការងារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងអាស៊ាន និងការងារផ្សេងទៀត ដើម្បីពង្រឹងគុណភាពស្ថិតិតាមរយៈការអនុវត្តនូវក្រមសីលធម៌។ រហូតដល់សព្វថ្ងៃនេះ សូចនាករភាគច្រើននៅក្នុង ជ.យ.អ.ជ ត្រូវបានផលិតឡើង ដែលផ្តល់នូវមូលដ្ឋានគ្រឹះដ៏ប្រសើរសម្រាប់ការងារបន្ត និងដើម្បីរៀបចំសម្រាប់តម្រូវការដែលមានការកើនឡើងដោយអាចមើលឃើញទុកជាមុន សម្រាប់ស្ថិតិផ្លូវការក្នុងក្របខ័ណ្ឌការងារដ៏សំខាន់បំផុតដូចជាអាស៊ាន។ សម្រាប់ពេលអនាគត ត្រូវមានការបញ្ជ្រាបសម្រាប់ការប្រើប្រាស់រាល់បញ្ជីរដ្ឋបាលដែលបានប្រមូល និងទិន្នន័យអង្កេត និងការប្រើប្រាស់នូវបទដ្ឋានចាត់ចំណាត់ថ្នាក់និងនីតិវិធីការងារបទដ្ឋាន។ សម្រាប់ការប្រើប្រាស់នូវវិធីសាស្ត្រល្អបំផុត នាពេលបច្ចុប្បន្ន គឺការរៀបចំវិធីសាស្ត្រ និងការផលិតស្ថិតិ ព្រមទាំងការផ្សព្វផ្សាយ ដោយមានការសហប្រតិបត្តិការជាមួយប្រព័ន្ធស្ថិតិជាតិ និងដើម្បីពង្រឹងវិទ្យាស្ថានជាតិស្ថិតិ និងការធ្វើការងាររួមគ្នា និងជាមួយបណ្តាអង្គភាពស្ថិតិនៃក្រសួងសំខាន់ៗផ្សេងៗទៀត។

គោលដៅផ្សេងៗទៀត សម្រាប់ពេលអនាគត គឺការបង្កើនគុណភាពស្ថិតិតាមរយៈការសម្របសម្រួល ការបណ្តុះបណ្តាល ការប្រើប្រាស់សូចនាករ និងដំណើរការបទដ្ឋាន និងប្រព័ន្ធគ្រប់គ្រងទិន្នន័យព្រមទាំងការប្រើប្រាស់ ICT ឱ្យបានកាន់តែច្រើនឡើង។ សំណួរសម្រាប់ពេលអនាគតមួយដែលអាចលើកឡើង គឺអំពីការរៀបចំប្រព័ន្ធស្ថិតិជាតិ ដែលមានប្រសិទ្ធភាពបំផុតនោះ គឺថាតើគួរឱ្យមានប្រព័ន្ធបែបមជ្ឈការ ឬក៏វិមជ្ឈការ ហើយតើអង្គភាពណាមួយត្រូវបញ្ចូលនៅក្នុងប្រព័ន្ធស្ថិតិជាតិ? ចុះយ៉ាងដូចម្តេចដែរ ចំពោះស្ថាប័ននានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការសម្របសម្រួល ឬការទទួលខុសត្រូវក្នុងការអនុវត្តការអង្កេត និងក្នុងចំណោមសកម្មភាពផ្សេងៗទៀត។

មានការផ្តល់អនុសាសន៍ផងដែរ ឱ្យបញ្ចូលផែនការមេស្ថិតិ ជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃ និងរបាយការណ៍ប្រចាំឆ្នាំ នៃប្រព័ន្ធស្ថិតិជាតិដើម្បីឱ្យក្លាយជាផ្នែកមួយរបស់ប្រព័ន្ធមួយ សម្រាប់ការធ្វើផែនការ និងការតាមដានបន្ត។ មាន

តម្រូវការសម្រាប់ប្រព័ន្ធដ៏មានប្រសិទ្ធភាពមួយ សម្រាប់ការធ្វើផែនការ និងការតាមដានបន្ត ដើម្បីបង្កើនចំណេះដឹងក្នុងការដោះស្រាយបញ្ហាប្រតិបត្តិការនានា ថាតើការចំណាយផលិតកម្មត្រូវគណនាដោយរបៀបណា និងថាតើធនធានមន្ត្រី និងធនធានផ្សេងៗទៀត ត្រូវប្រើប្រាស់ឱ្យមានប្រសិទ្ធភាពបំផុតតាមរបៀបណា។

## ៦.២ ការរក្សាស្ថិតិសេដ្ឋកិច្ច និងសង្គម-ប្រជាសាស្ត្រសំខាន់ៗ

ទិន្នផលស្ថិតិដែលមានស្រាប់ ឆ្លុះបញ្ចាំងនូវអាទិភាពខ្ពស់បំផុតសម្រាប់អ្នកប្រើប្រាស់ និងលទ្ធភាពអាចរកបាននូវទិន្នន័យដ៏សម្បូរបែប ជាពិសេស សម្រាប់សូចនាករភាគច្រើននៅក្នុង ផ.យ.អ.ជ។

ទិន្នផលស្ថិតិសំខាន់ៗ មានបង្ហាញក្នុងឧបសម្ព័ន្ធ ២ ក្នុងនោះរួមមានការបញ្ជាក់នូវសមាសធាតុសំខាន់ៗ និងប្រភពទិន្នន័យផងដែរ។ អាទិភាពខ្ពស់បំផុតសម្រាប់ប្រព័ន្ធស្ថិតិជាតិ គឺការថែរក្សាទុកទិន្នន័យស្ថិតិឱ្យបានទៀងទាត់គ្រប់ផ្នែកទាំងអស់ និងផ្តោតការយកចិត្តទុកដាក់ខ្ពស់សម្រាប់សេចក្តីត្រូវការនានា ឧទាហរណ៍ សម្រាប់ក្របខ័ណ្ឌការងារអាស៊ានជាដើម។ ការអង្កេតភាគច្រើនផ្តល់នូវអាទិភាព ហើយទិន្នន័យដែលមានភាពសំខាន់នៅទាបនោះ គឺការប្រមូលទិន្នន័យតាម រយៈប្រព័ន្ធរដ្ឋបាល។ រហូតដល់បច្ចុប្បន្ននេះ មានការលំបាកក្នុងការផ្តល់អាទិភាពសម្រាប់ប្រព័ន្ធស្ថិតិជាតិទាំងមូល។ មានការដាក់បញ្ចូលគ្នារវាងការអង្កេតមួយចំនួន ដូចជាការអង្កេតទាក់ទងនឹងការចំណាយរបស់គ្រួសារ ប្រជាសាស្ត្រ ឬសុខភាពដើម្បីកាត់បន្ថយចំណាយ និងបន្ទុកក្នុងការឆ្លើយសំណួរ។

អាទិភាពខ្ពស់ជាងគេបំផុត គឺការធ្វើជំរឿន ដូចបានបញ្ជាក់នៅក្នុងច្បាប់ស្ថិតិ ត្រូវធ្វើយ៉ាងតិចរៀងរាល់ ១០ ឆ្នាំម្តង ដូចជាជំរឿនប្រជារាស្ត្រ ជំរឿនកសិកម្ម និងជំរឿនសហគ្រាស។ អង្កេតចន្លោះជំរឿនត្រូវធ្វើឡើងរវាងជំរឿនទាំងឡាយ ដើម្បីធ្វើការសម្របសម្រួលនូវព័ត៌មានបច្ចុប្បន្នភាពប្រចាំឆ្នាំ។ ការអង្កេតប្រកបដោយអាទិភាពខ្ពស់ ត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ឬប្រចាំត្រីមាសមានដូចជា៖

- ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (អង្កេតគ្រួសារ) ជាទៀងទាត់
- ការអង្កេតកំលាំងពលកម្ម ជាទៀងទាត់
- ថ្លៃទំនិញប្រើប្រាស់
- ផលិតកម្មឧស្សាហកម្ម
- ទំនិញកសិកម្ម និងថ្លៃផលិតកម្ម
- ស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ

- ពាណិជ្ជកម្មអន្តរជាតិ ផ្នែកសេវាកម្ម
- ការអង្កេតវិនិយោគទុនអន្តរជាតិ

និងការអង្កេតមិនសូវញឹកញាប់ (ចន្លោះពី ២ ទៅ ៥ ឆ្នាំ)៖

- ការអង្កេតប្រជាសាស្ត្រ
- ការអង្កេតសុខភាព
- ការអង្កេតអក្ខរភាព
- ការអង្កេតសន្ទស្សន៍ភាពក្រីក្រ
- ការអង្កេតលទ្ធភាពទទួលបានសម្ភារៈមូលដ្ឋានដើម្បីប្រើប្រាស់

### ៦.៣ ជំរឿន និងអង្កេត

ដូចបង្ហាញនៅក្នុងផែនការមេស្ថិតិ នាពេលបច្ចុប្បន្ននេះ ជំរឿនបង្កើតនូវគ្រឹះនៃការងារស្ថិតិ ពីព្រោះវាផ្តល់នូវតម្លៃប៉ាន់ប្រមាណដ៏ត្រឹមត្រូវសម្រាប់ផ្នែកតូចៗ និងការចាត់ចំណាត់ថ្នាក់លម្អិត។ ច្បាប់ស្ថិតិកំណត់ថា ជំរឿនត្រូវធ្វើឡើងរៀងរាល់ ១០ ឆ្នាំម្តង។ ជំរឿនប្រជាពលរដ្ឋបានធ្វើឡើងក្នុងឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៨។ វិទ្យាស្ថានជាតិស្ថិតិនឹងរៀបចំធ្វើអង្កេតចន្លោះជំរឿនប្រជាពលរដ្ឋ ដោយមានជំនួយឧបត្ថម្ភពីអង្គការ UNFPA ដើម្បីធ្វើការត្រួតពិនិត្យនូវកំណើនប្រជាពលរដ្ឋ និងធ្វើបច្ចុប្បន្នភាពអំពីព័ត៌មានចំនួនប្រជាជន (សូមមើលតារាងទី១)។

មានការស្នើសុំឱ្យរៀបចំជំរឿនកសិកម្មនៅឆ្នាំ ២០០៩ ភ្លាមៗបន្ទាប់ពីជំរឿនប្រជាពលរដ្ឋ។ ដោយសារតែកង្វះខាតធនធាន ជំរឿនកសិកម្មត្រូវបានពន្យាពេល។ វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានលទ្ធភាពប្រមូលធនធានបានគ្រប់គ្រាន់ក្នុងឆ្នាំ ២០១២ ហើយរហូតមកដល់បច្ចុប្បន្ននេះ បាននឹងកំពុងរៀបចំធ្វើជំរឿននេះ ក្នុងឆ្នាំ ២០១៣ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល និងអង្គការនានា រួមមាន USAID, AusAID, Sida និង FAO ។

ជំរឿនសហគ្រាស (ជំរឿនសេដ្ឋកិច្ច) ដែលជាជំរឿនមិនធ្លាប់មាន ត្រូវបានធ្វើឡើងជាលើកដំបូងក្នុងឆ្នាំ ២០១១ បន្ទាប់ពីមានការចុះបញ្ជីសហគ្រាសកាលពីឆ្នាំ ២០០៩ និងការអង្កេតសាកល្បងដ៏ធំមួយកាលពីឆ្នាំ២០១០។ ទិន្នន័យបានមកពីជំរឿនសហគ្រាសអាចយកទៅប្រើប្រាស់សម្រាប់គណនេយ្យជាតិ សម្រាប់ប្រើប្រាស់ជាក្របខ័ណ្ឌការងារនៃអាជីវកម្មទាំងឡាយ និងដើម្បីធ្វើការកំណត់នូវការចុះបញ្ជីអាជីវកម្មផងដែរ។ ការរៀបចំគណនេយ្យជាតិ នឹងមានគម្រោងប្រើប្រាស់ព័ត៌មានពីជំរឿននេះ។ កន្លងមក គ្មានដៃគូអភិវឌ្ឍន៍ណាមួយចាប់អារម្មណ៍ក្នុងការរៀបការចុះបញ្ជីអាជីវកម្មនោះទេ។ អង្កេតសហគ្រាសនឹងត្រូវរៀបចំធ្វើនៅឆ្នាំ ២០១៤ ដោយវិទ្យាស្ថានជាតិ ស្ថិតិ ដែលមានការគាំទ្រដោយ អង្គការ JICA។

ការអង្កេតថ្នាក់ជាតិសំខាន់ៗមួយចំនួនទៀត ដែលត្រូវរៀបចំធ្វើរៀងរាល់ ៥ ឆ្នាំម្តង គឺការអង្កេតសុខភាព និងប្រជាសាស្ត្ររបស់ប្រទេសកម្ពុជា។ ការអង្កេតចុងក្រោយត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០១០ និងសម្រាប់ធ្វើការប្រៀបធៀបជាមួយនឹងការអង្កេតឆ្នាំ ២០០០ និងឆ្នាំ ២០០៥។ វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងសុខាភិបាល បានប្រតិបត្តិការរួមគ្នា ក្នុងកំឡុងនៃការអនុវត្តអង្កេតនេះ ដោយមានការជួយឧបត្ថម្ភពីអង្គការ UNFPA និង USAID ។

ការអង្កេតគ្រួសារបន្តបន្ទាប់ ដែលទិន្នន័យបានមកពីប្រធានបទផ្សេងៗគ្នា ត្រូវបានគេចងក្រងទុកនោះ ត្រូវបានរៀបចំធ្វើឡើងចាប់តាំងពីឆ្នាំ ២០០៧។ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាមានការជួយគាំទ្រដោយអង្គការ Sida និងមានការផ្តល់អនុសាសន៍ក្នុងផែនការមេស្ថិតិ ហើយកម្រងសំណួរត្រូវបានពិនិត្យឡើងវិញនៅឆ្នាំ ២០០៧។ ទោះយ៉ាងណាក៏ដោយ ខ្លឹមសារមានលក្ខណៈទូលំទូលាយជាងអ្វីដែលមានការស្នើឡើងដោយផែនការមេស្ថិតិ ដោយសារតែតម្រូវការឱ្យមានទិន្នន័យប្រចាំឆ្នាំ ដើម្បីតាមដានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង ផ.យ.អ.ជ។ ទិន្នន័យកំណត់ត្រាប្រចាំថ្ងៃ ត្រូវបានលុបចោលពីក្នុងកម្រងសំណួរសម្រាប់ឆ្នាំ ២០១២ ហើយការប្រើប្រាស់វិធីសាស្ត្រកត់ត្រាប្រចាំថ្ងៃនឹងត្រូវធ្វើឡើងរាល់ ៥ ឆ្នាំម្តង សម្រាប់ការអង្កេតដែលមានសំណាកគំរូធំតែប៉ុណ្ណោះ។ ការអង្កេតគ្រួសារដែលមានសំណាកគំរូធំបន្ទាប់ នឹងត្រូវធ្វើឡើងក្នុងឆ្នាំ ២០១៤។ ទោះយ៉ាងណាក៏ដោយ គំនិតនៅក្នុងផែនការមេស្ថិតិ នៃការអង្កេតទ្រង់ទ្រាយតូច ដោយមានវិធីសាស្ត្រផ្លាស់ប្តូរគ្នានឹងយកមកគិតពិចារណាក្នុងឆ្នាំ ២០១៥ នៅពេលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រូវបានពិនិត្យឡើងវិញ ហើយវិទ្យាស្ថានជាតិស្ថិតិ នឹងទទួលខុសត្រូវរាល់ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា។ ទិន្នន័យត្រូវបានគេប្រើប្រាស់យ៉ាងហ្មត់ចត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការគណនាពីភាពក្រីក្រនៅពេលដែលការវាស់វែងនេះបានពិនិត្យឡើងវិញ និងត្រូវបង្ហាញក្នុងឆ្នាំ ២០១២។

ការអង្កេតកំលាំងពលកម្មដោយឡែក មិនត្រូវបានរៀបចំធ្វើឡើយ ដោយសារកង្វះខាតធនធាន។ ជំនួសមកវិញ ផ្នែកដែលទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ច ត្រូវបានបញ្ចូលនៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ដែលត្រូវយកទៅប្រើប្រាស់ដោយគណនេយ្យជាតិ។ ក្នុងឆ្នាំ ២០១២ អង្កេតកំលាំងពលកម្ម នឹងត្រូវរៀបចំឡើងដោយមានជំនួយពីអង្គការពលកម្មអន្តរជាតិ។ ការអង្កេតក្នុងឆ្នាំ ២០១២ នេះ នឹងត្រូវយកទៅប្រើប្រាស់ដើម្បីត្រួតពិនិត្យភាពរីកចម្រើនចាប់តាំងពីឆ្នាំ ២០០១ មក នៅពេលអង្កេតកំលាំងពលកម្មដែលធ្វើដាច់ដោយឡែកត្រូវបានធ្វើឡើង។

ទិន្នន័យនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ត្រូវបានប្រមូលចងក្រងសម្រាប់ខេត្តចំនួន ៥ ជាទៀងទាត់ និងចាប់តាំងពីផែនការមេស្ថិតិ ត្រូវបានបង្ហាញវិធីសាស្ត្រថ្មី និងឆ្នាំមូលដ្ឋានថ្មីមួយត្រូវបាន

ប្រើប្រាស់នៅក្នុងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់។ ក្នុងខែមេសា ឆ្នាំ ២០០៩ វិទ្យាស្ថានជាតិស្ថិតិ បានសម្រេចចិត្តបង្ហាញនូវសន្ទស្សន៍នៅទីក្រុងភ្នំពេញ ជំនួសឱ្យប្រទេសទាំងមូល ឬតែ ៥ ខេត្ត។ ក្នុងឆ្នាំ ២០១២ មានគំនិតមួយ គឺការពង្រីកសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ដើម្បីរួមបញ្ចូលទាំង ៥ ខេត្តឡើងវិញ។

**តារាងទី១៖ កាលវិភាគបច្ចុប្បន្នភាពជំរឿន និងអង្កេតគ្រួសារ ឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៥ យោងទៅតាមការវាយតម្លៃពាក់កណ្ដាលអាណត្តិផែនការមេស្ថិតិ ខែ មិថុនា ឆ្នាំ ២០១២**

| | ជំហាននៃគោលនយោបាយសំខាន់ៗ | | | ជំរឿន | អង្កេត | | |
|---|---|---|---|---|---|---|---|
| 2006 | NSDP 2006-2010 ចាប់ផ្ដើម | | ការត្រួតពិនិត្យបន្តសូចនាករសម្រាប់ NSDP | | | | 2006 |
| 2007 | | | | | CSES ប្រចាំឆ្នាំ (3,600 គ្រួសារ 2007, 2008, 2010, 2011)<br>*ផ្នែកសំខាន់ៗ៖*<br>-ចំណូលនិងចំណាយ (ទិន្នន័យប្រចាំថ្ងៃ និងសួរំលឹក)<br>-ការងារ<br>-ផ្ទះសម្បែង<br>-អប់រំ និងអក្ខរកម្ម<br>-សុខាភិបាល<br>-កសិកម្ម<br>-ភាពងាយរងគ្រោះ<br>-អន្តោប្រវេសន៍ | | 2007 |
| 2008 | | | | ជំរឿនប្រជារាស្ត្រ | | | 2008 |
| 2009 | រៀបចំ NSDP បច្ចុប្បន្នកម្ម 2009-2013 | របាយការណ៍ MDGs | | | | CSES 2009 សំណាកគំរូធំ (12,000 គ្រួសារ) | 2009 |
| 2010 | | របាយការណ៍ MDGs | | | | CDHS 2010 | 2010 |
| 2011 | NSDP បច្ចុប្បន្នកម្ម 2009-2013 ចាប់ផ្ដើម | | | ជំរឿនសហគ្រាស | | | 2011 |
| 2012 | របាយការណ៍វឌ្ឍភាពប្រចាំឆ្នាំស្ដីពីសូចនាករ NSDP–CMDG | | | | CSES ប្រចាំឆ្នាំ (សំណាកគំរូតូច, 2012, 2013, 2015)<br>*ផ្នែកសំខាន់ៗ៖*<br>-ចំណូលនិងចំណាយ (ទិន្នន័យសួរំលឹកប៉ុណ្ណោះ)<br>-ការងារ<br>-ផ្ទះសម្បែង<br>-អប់រំ និងអក្ខរកម្ម<br>-សុខាភិបាល<br>-កសិកម្ម<br>-ភាពងាយរងគ្រោះ | | 2012 |
| 2013 | រៀបចំ NSDP 2014-2018 | | | ជំរឿនកសិកម្ម | | CIPS 2013 | 2013 |
| 2014 | NSDP 2014-2018 ចាប់ផ្ដើម | របាយការណ៍ MDGs | | | | CSES2014 សំណាកគំរូធំ (កត់ត្រាប្រចាំថ្ងៃ និងសួរំលឹក) | 2014 |
| 2015 | | | | | | CDHS 2010 | 2015 |
| 2016 | | | | | CSES ទ្រង់ទ្រាយតូចជាមួយនឹងគំរូផ្លាស់ប្ដូរឆ្នាំ 2016 និងឆ្នាំបន្ទាប់ៗទៀត | | 2016 |

## ៦.៤ ការរក្សាបញ្ជីសហគ្រាស

អង្គការ JICA បានជួយគាំទ្រវិទ្យាស្ថានជាតិស្ថិតិ ក្នុងការរៀបចំបញ្ជីសហគ្រាសនៅឆ្នាំ២០០៩ អង្កេតសាកល្បងសហគ្រាស និងជំរឿនសហគ្រាសក្នុងឆ្នាំ២០១១។ ព័ត៌មានដែលបានប្រមូលតាមរយៈការធ្វើបញ្ជីសហគ្រាស និងជំរឿនអាចយកទៅប្រើប្រាស់ក្នុងការរៀបចំបញ្ជីអាជីវកម្ម (Business Register)។ ទោះជាយ៉ាងណាក៏ដោយការងារនេះមិនស្ថិតនៅក្នុងវិសាលភាពនៃគម្រោង JICA នោះទេ ហើយក៏មិនទាន់មានដៃគូអភិវឌ្ឍន៍ណា បានបង្ហាញពីចំណាប់អារម្មណ៍

ក្នុងការបង្កើតបញ្ជីអាជីវកម្មនេះដែរ។ នេះគឺជាការងារដ៏ធំមួយ និងដូចបង្ហាញនៅក្នុងផែនការមេស្ថិតិនាពេលបច្ចុប្បន្ន ការចុះបញ្ជីអាជីវកម្ម ត្រូវតែមានការធ្វើបច្ចុប្បន្នកម្មជានិច្ច។ ទោះជាយ៉ាងណាក៏ដោយច្បាប់ស្ថិតិ តម្រូវឱ្យវិទ្យាស្ថានជាតិស្ថិតិបង្កើតនូវការចុះបញ្ជី ហើយវិទ្យាស្ថានជាតិស្ថិតិគួរព្យាយាមស្វែងរកធនធានពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងឡាយដើម្បីចាប់ផ្តើមការងារនេះ។

## ៦.៥ ប្រភពទិន្នន័យ រដ្ឋបាល

ការប្រមូល និងការប្រើប្រាស់ទិន្នន័យរដ្ឋបាលត្រូវបានធ្វើឡើងដោយក្រសួង ស្ថាប័ននានា។ នៅក្នុងវិស័យមួយចំនួន មានការកង្វល់អំពីគុណភាពទិន្នន័យ ដូចជាកម្រិតបទដ្ឋាន និងជំនាញជាក់លាក់ក្នុងការប្រើប្រាស់ទិន្នន័យជាដើម។ មានភាពរីកចម្រើន និងការកើនឡើងអំពីការប្រើប្រាស់ទិន្នន័យអង្កេត និងទិន្នន័យរដ្ឋបាល ដែលទាំងនេះ គឺបញ្ហាប្រឈមមួយសម្រាប់ការប្រើប្រាស់ទិន្នន័យប្រកបដោយប្រសិទ្ធភាព។ គុណភាពដែលធ្វើឱ្យប្រសើរឡើង ក៏ជាកត្តានាំឱ្យមានការប្រើប្រាស់ទិន្នន័យ និងប្រព័ន្ធផ្សេងៗ ដោយអ្នកបង្កើតគោលនយោបាយ អ្នកស្ថិតិ និងមន្ត្រីនៅគ្រប់កម្រិត។ ការរីកចម្រើនផ្នែកគុណភាពបន្ថែមទៀត អាចខិតជិតមកដល់នៅពេលមានក្រមសីលធម៌នៅនឹងទីកន្លែង និងនីតិវិធីការងារតាមបទដ្ឋានកំពុងត្រូវគេប្រើប្រាស់។ កង្វល់អំពីភាពទាន់ពេលនៃព័ត៌មាន ពីប្រភពទិន្នន័យរដ្ឋបាល អាចមានការកាត់បន្ថយតាមរយៈការពិភាក្សាជាមួយនឹងអ្នកផលិត និងអ្នកប្រើប្រាស់។ ការប្រើប្រាស់ទិន្នន័យរដ្ឋបាល ដែលបំពេញបន្ថែមទិន្នន័យអង្កេត ក្នុងការផលិតស្ថិតិសំខាន់ៗ និងយុទ្ធសាស្ត្រផ្សព្វផ្សាយតាមរយៈភ្នាក់ងារសម្រាប់ស្ថិតិទាំងនោះ គឺមានសារៈសំខាន់ណាស់។

## ៦.៦ ការអភិវឌ្ឍប្រព័ន្ធសូចនាករ

បញ្ជីសូចនាករថ្មីដែលមានចំនួន ១៣៦ សូចនាករ សម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងនោះរួមមានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ត្រូវបានរៀបចំរួចរាល់ និងបានអនុម័តដោយកិច្ចប្រជុំរបស់ក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី នាពេលថ្មីៗនេះ។ ក្នុងចំណោមសូចនាករទាំងអស់ មានសូចនាករចំនួន ៦៣ គឺជាសូចនាករស្នូល និងសូចនាករ ចំនួន ៧៣ ផ្សេងទៀត គឺជាសូចនាករបន្ថែម។

CAMInfo គឺជាប្រព័ន្ធទិន្នន័យសូចនាករ ដែលគ្រប់គ្រងដោយវិទ្យាស្ថានជាតិស្ថិតិ ដោយមានការគាំទ្រពី UNICEF។ វាត្រូវបានធ្វើបច្ចុប្បន្នភាពដោយមានទិន្នន័យសម្រាប់សូចនាករចំនួន ៥៦៥ (រួមមានសូចនាករតាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ) បែងចែក

ជា ៨៩ ផ្នែក និងមានចំនួន ៣២ គោលដៅ ដោយគ្របដណ្តប់នូវរយៈពេលផ្សេងៗគ្នា និងប្រភពខុសៗគ្នា និងត្រូវបានបំបែកជាផ្នែកតាមកម្រិតរហូតដល់ថ្នាក់ឃុំ-សង្កាត់។

## ៦.៧ ការវិភាគ និងការរៀបចំរបាយការណ៍

សមត្ថភាពក្នុងការវិភាគ និងការសរសេររបាយការណ៍ ត្រូវបានបង្កើតឡើងនៅប៉ុន្មានឆ្នាំថ្មីៗនេះតាមរយៈជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ផ្សេងៗ។ ជាពិសេស គម្រោងកសាងសមត្ថភាពស្ថាប័នដែលគាំទ្រដោយ Sida ក្នុងគោលបំណងដើម្បីធ្វើឱ្យប្រសើរនូវជំនាញសរសេររបាយការណ៍របស់វិទ្យាស្ថានជាតិស្ថិតិ។ ទាំងទីប្រឹក្សារយៈពេលខ្លី និងរយៈពេលវែង បានធ្វើការអមជាមួយមន្ត្រីពាក់ព័ន្ធ ដើម្បីបណ្តុះបណ្តាលពួកគេក្នុងការធ្វើវិភាគទិន្នន័យ និងសរសេររបាយការណ៍។ របាយការណ៍ដោយផ្អែកតាមលទ្ធផលរកឃើញសំខាន់ៗត្រូវបានផលិតឡើង និងការប្រើប្រាស់នូវទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គម-កិច្ចកម្ពុជាកំពុងមានការកើនឡើង។ ការបណ្តុះបណ្តាលភាសាអង់គ្លេស តាមរយៈវិទ្យាស្ថានបណ្តុះបណ្តាលក្នុងស្រុក ក៏ត្រូវបានផ្តល់ទៅឱ្យមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ ដែលមានចំនួនគួរឱ្យកត់សម្គាល់។

## ៦.៨ ការផ្សព្វផ្សាយ

នៅវិទ្យាស្ថានជាតិស្ថិតិ មានមជ្ឈមណ្ឌលសេវាកម្មអ្នកប្រើប្រាស់ទិន្នន័យ ដែលផ្តល់ និងគាំទ្រនូវការផ្សព្វផ្សាយទិន្នន័យស្ថិតិ ទៅឱ្យអ្នកប្រើប្រាស់ និងសាធារណជនទូទៅ។ ការបោះពុម្ពដែលបង្កើតឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធទិន្នន័យបានមកពីប្រភពផ្សេងៗ ដូចជាអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ជំរឿនប្រជាពលរដ្ឋ និងជំរឿនសហគ្រាស និងអត្ថបទបោះពុម្ពរបស់ក្រសួង ស្ថាប័ននានា គឺអាចរកបានតាមរយៈមជ្ឈមណ្ឌលនេះ។

គេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ ផ្តល់នូវតួនាទីដ៏សំខាន់ក្នុងការរក្សាឯកសារ និងការផ្សព្វ-ផ្សាយស្ថិតិផ្លូវការនៃប្រទេសកម្ពុជា។ នៅពេលថ្មីៗនេះ បណ្តាញទាក់ទង និងខ្លឹមសាររបស់គេហទំព័រត្រូវបានពិនិត្យឡើងវិញ។ នាពេលបច្ចុប្បន្ន ឯកសារបោះពុម្ព ដូចជាគណនេយ្យជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងរបាយការណ៍ស្ថិតិផ្សេងៗទៀត (ដូចជា អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ជំរឿនប្រជាពលរដ្ឋ និងសមិទ្ធផលស្ថិតិផ្សេងៗទៀត ) អាចរកបានតាមរយៈការទាញយកពីគេហទំព័រនេះ។

តាមរយៈគេហទំព័រ អ្នកប្រើប្រាស់អាចចូលទៅប្រើប្រាស់ ប្រព័ន្ធទិន្នន័យនៃសូចនាករសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ដែលជាការផ្សព្វផ្សាយតាមគេហទំព័រ និងជាឧបករណ៍ប្រត្យក្សមួយ ដែលអាច

ឱ្យអ្នកប្រើប្រាស់បង្កើតជាផែនទី ឬតារាងផ្សេងៗ ចេញពីទិន្នន័យមូលដ្ឋាននេះ។ ដោយមានប្រព័ន្ធតាមគេហទំព័រ (CamInfo Online) ប្រព័ន្ធទិន្នន័យ CAMInfo ផ្តល់ឱ្យអ្នកប្រើប្រាស់ ដូចជា រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ ។ល។ មានឱកាសទាញយកទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាថ្មីៗបំផុត ដែលទិន្នន័យទាំងនោះ បានមកពីប្រភពផ្សេងៗ ដូចជា ជំរឿន អង្កេត និងតាមរយៈប្រព័ន្ធទិន្នន័យរដ្ឋបាល នៃបណ្ដាក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

វិទ្យាស្ថានជាតិស្ថិតិ បានបង្កើតគម្រោងមួយក្នុងឆ្នាំ ២០១១ ដែលឧបត្ថម្ភដោយនាយកដ្ឋានស្ថិតិអង្គការសហប្រជាជាតិ និងដាក់ចំណងជើងគម្រោងនោះថា "ការធ្វើឱ្យប្រសើរនូវការផ្ទៀងផ្ទាត់ភាពអាចរកបាន និងការផ្សព្វផ្សាយនូវសូចនាករអភិវឌ្ឍន៍ជាតិ រួមមានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍"។ គោលបំណងរបស់គម្រោងនេះ គឺការកែលម្អភាពមានឱកាសអាចប្រើប្រាស់បាន នូវសូចនាករអភិវឌ្ឍន៍ជាតិ រវាងកម្រិតប្រទេស និងអន្តរជាតិ តាមរយៈការបង្កើតច្រកតែមួយសម្រាប់សូចនាករអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងនាំយកសូចនាករទាំងនេះទៅកាន់ថ្នាក់អន្តរជាតិ។ គម្រោងនេះ ពឹងផ្អែកទៅលើប្រព័ន្ធទិន្នន័យ CAMInfo ដែលមានស្រាប់ និងក្របខ័ណ្ឌសូចនាករ សម្រាប់ធ្វើការតាមដានត្រួតពិនិត្យភាពរីកចម្រើនរបស់ NSDP/CMDG ។ នៅក្នុងគម្រោងនេះ សូចនាករស្នូលរបស់ NSDP និងមេតាដាតារបស់វាត្រូវបានរៀបចំ និងធ្វើឱ្យប្រសើរដើម្បីឱ្យស្របទៅតាមស្តង់ដារអន្តរជាតិ។

# ៧. គម្រោងថវិកា និងហិរញ្ញវត្ថុ

យោងទៅតាមអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង (មាត្រា១០) ក្រសួងផែនការ ត្រូវធ្វើបញ្ជីទិន្នន័យរដ្ឋបាលដែលមានស្រាប់ទាំងអស់ ជំរឿន និងអង្កេត គម្រោងចំណាយ និងស្ថានភាពនៃការប្រមូលទិន្នន័យទៅឱ្យទីស្តីការគណៈរដ្ឋមន្ត្រី មុនបំណាច់ខែកក្កដា ឆ្នាំ ២០១១ និងបន្ទាប់មកត្រូវបញ្ជូនជារៀងរាល់ឆ្នាំនូវបញ្ជីទិន្នន័យរដ្ឋបាលថ្មីទាំងអស់ ជំរឿន និងអង្កេត ទៅឱ្យទីស្តីការគណៈរដ្ឋមន្ត្រី។ ការងារទាំងអស់នេះត្រូវបានធ្វើឡើង និងរបាយការណ៍ប្រចាំឆ្នាំ សម្រាប់ប្រព័ន្ធស្ថិតិជាតិត្រូវបានបោះពុម្ពក្នុងខែសីហា ឆ្នាំ ២០១១។

នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ សម្រាប់ប្រព័ន្ធស្ថិតិជាតិឆ្នាំ ២០១០ វិទ្យាស្ថានជាតិស្ថិតិ បានត្រួត-ពិនិត្យឡើងវិញនូវស្ថិតិដែលបានផលិតឡើង។ សម្រាប់អ្នកផលិតស្ថិតិផ្លូវការជាច្រើន ព័ត៌មានអំពីការចំណាយសម្រាប់ការផលិតស្ថិតិ និងសកម្មភាពប្រមូលទិន្នន័យ នៅពុំទាន់មានភាពប្រសើរនៅឡើយ។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំសម្រាប់ប្រព័ន្ធស្ថិតិជាតិឆ្នាំ ២០១១ មានចំណុចរីកចម្រើនច្រើន ប៉ុន្តែនៅតែមានភាពខ្វះខាតព័ត៌មាន អំពីការចំណាយសម្រាប់ការផលិតស្ថិតិចេញពីអ្នក ផលិតជាច្រើន។

គោលបំណងមួយ ក្នុងចំណោមគោលបំណងទាំងអស់ ក្នុងការពិនិត្យឡើងវិញនូវផែនការមេស្ថិតិនេះ គឺការវាយតម្លៃបរិមាណចំណាយសរុបសម្រាប់ការផលិតស្ថិតិ ដែលធ្វើឡើងដោយដៃគូអភិវឌ្ឍន៍ផ្សេងៗក្នុងប្រព័ន្ធស្ថិតិផ្សេងពីវិទ្យាស្ថានជាតិស្ថិតិ។ កំឡុងការពិនិត្យសារឡើងវិញនេះ មានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការប្រមូលព័ត៌មាន អំពីបរិមាណចំណាយសម្រាប់ផ្នែកដែលបាត់បង់ក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០១០ និងឆ្នាំ ២០១១។ គឺមានទិន្នន័យតាមក្រសួងមួយចំនួនប៉ុណ្ណោះ ដែលអាចរកបានអំពីការចំណាយសម្រាប់ការផលិតស្ថិតិ។

ខ្លឹមសារនៃតួលេខដែលមាននៅក្នុងរបាយការណ៍ប្រចាំឆ្នាំ គឺមានភាពមិនច្បាស់លាស់។ តួលេខខ្លះរួមបញ្ចូលទាំងប្រាក់បៀវត្ស ខ្លះទៀតមិនគិតបញ្ចូលទេ និងសម្រាប់តួលេខមួយចំនួនទៀត វាគ្រាន់តែបង្ហាញពីប្រាក់បៀវត្ស សម្រាប់អ្នកដែលពាក់ព័ន្ធនឹងការផលិតស្ថិតិប៉ុណ្ណោះ។ ភាពមិនច្បាស់លាស់នេះ គឺស្ថិតនៅក្នុងចំណោមចំណុចផ្សេងៗទៀត ដោយសារតែការពិតថា គ្មានព័ត៌មានជាក់លាក់ដែលអាចរកបានតាមសកម្មភាពផ្សេងៗគ្នា ក្នុងការផលិតស្ថិតិ ឬមធ្យោបាយប្រកបដោយស្តង់ដារនៃការគណនា និងធ្វើរបាយការណ៍ពីបរិមាណចំណាយលើប្រាក់បៀវត្សការប្រមូលទិន្នន័យ និងការប្រើប្រាស់ទិន្នន័យរដ្ឋបាល ការវិភាគ និងការផ្សព្វផ្សាយ ។ល។ អាស្រ័យហេតុនេះ ដោយសារកង្វះខាតព័ត៌មានអំពីការចំណាយដោយផ្ទាល់ និងប្រយោលសម្រាប់អង្កេតស្ថិតិផ្សេងៗគ្នា និងសម្រាប់ការប្រើប្រាស់ទិន្នន័យរដ្ឋបាល វាមិនអាចធ្វើទៅបាន

ក្នុងការផ្ដល់នូវតួលេខឱ្យបានគ្រប់គ្រាន់សម្រាប់សកម្មភាពនានា ដូចមានបង្ហាញនៅក្នុងផែនការមេស្ថិតិនាពេលបច្ចុប្បន្ននេះ។

ដើម្បីទទួលបានឱ្យបានប្រសើរនូវការប៉ាន់ស្មាន អំពីប្រភពធនធានហិរញ្ញវត្ថុដែលត្រូវការសម្រាប់ស្ថិតិផ្លូវការក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវមានការប្រើប្រាស់នូវគំរូមួយ។

គំរូនេះ គឺត្រូវពឹងផ្អែកលើទិន្នន័យដែលអាចរកបាន អំពីការចំណាយដែលមានការរាយការណ៍ពីវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង នៃក្រសួង ស្ថាប័ននានា ដែលបានកំណត់ដោយអនុក្រឹត្យស្ដីពីស្ថិតិផ្លូវការដែលបានចាត់តាំង និងដោយក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលមួយចំនួនដែលផលិតស្ថិតិ។ គំរូនេះ ប្រើប្រាស់នូវទិន្នន័យដែលមានការរាយ-ការណ៍អំពីបរិមាណចំណាយ និងចំនួនមន្ត្រីធ្វើការក្នុងការងារផលិតស្ថិតិ និងអំពីទិន្នន័យគណនាលើប្រាក់បៀវត្ស។ ការប៉ាន់ស្មានទាំងនេះ មានបង្ហាញនៅក្នុងតារាងទី២ ខាងក្រោម។

បង្គោល (Columns) ទី ២ និងទី ៣ បង្ហាញព័ត៌មានអំពីចំនួនមន្ត្រីក្នុងការងារផលិតស្ថិតិ និងអំពីថវិកាប៉ាន់ស្មាន ឬជាក់ស្ដែង ដូចមានក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០១១។ បង្គោលទី ៤ បង្ហាញព័ត៌មានដែលទទួលបានពីក្រសួង និងស្ថាប័ននានា ក្នុងកំឡុងនៃការជួបប្រជុំពិគ្រោះយោបល់ និងបង្គោលទី ៥ គឺបង្ហាញអំពីព័ត៌មានជាក់ស្ដែងក្នុងផែនការមេស្ថិតិ ចំណែកបង្គោលទី ៦ បង្ហាញព័ត៌មានប៉ាន់ស្មានចំណាយទៅលើប្រាក់បៀវត្សមន្ត្រីរាជការ ប្រសិនបើពួកគេធ្វើការក្នុងផ្នែកផលិតកម្មស្ថិតិ ដែលគួរទទួលបានប្រាក់បៀវត្សជាមធ្យមចំនួន ២០០ ដុល្លារ សហរដ្ឋអាមេរិកក្នុងមួយខែ។ ប្រាក់បៀវត្សមធ្យមនេះ ប៉ាន់ស្មានដោយយោងតម្រូវការក្នុងការបង្កើតឱ្យមានឡើងសម្រាប់មន្ត្រីរាជការ ដែលធ្វើការក្នុងផ្នែកផលិតកម្មស្ថិតិ ដើម្បីឱ្យពួកគេរស់នៅពឹងផ្អែកលើប្រាក់បៀវត្សនេះបាន និងមានការយកចិត្តទុកដាក់ខ្ពស់លើការងាររបស់ខ្លួន។ ចុងក្រោយ គឺបង្គោលទី៧ បង្ហាញពីតួលេខខ្ពស់បំផុត អំពីការប៉ាន់ស្មានចំណាយសម្រាប់បៀវត្ស ដែលមិនបានរាយការណ៍ ហើយដែលត្រូវបានគណនាដើម្បីយកមកប្រើប្រាស់ក្នុងផែនការមេស្ថិតិនេះ។

កំណត់សំគាល់ចំណាយ "ខ្ពស់បំផុត" ដែលមានក្នុងបង្គោលទី៧ គឺបង្ហាញពីតម្រូវការហិរញ្ញ-ប្បទានសម្រាប់ការផលិតស្ថិតិ ដោយសារពុំមានមធ្យោបាយជាក់លាក់បន្ថែម ក្នុងការប៉ាន់ស្មានអំពីផ្នែកនេះ។ វាមានសារៈសំខាន់ក្នុងការចងចាំថា បរិមាណចំណាយដែលមានការគណនាអាចមានការកើនឡើងទ្វេដងលើប្រាក់បៀវត្ស។ ដូច្នេះ នៅពេលមានការពិភាក្សាប្រចាំឆ្នាំអំពីហិរញ្ញប្បទានសម្រាប់ការប្រមូលទិន្នន័យ ការប្រើប្រាស់ទិន្នន័យរដ្ឋបាល ធនធានមន្ត្រី ។ល។ មានការណែនាំឱ្យប្រើប្រាស់ព័ត៌មានឱ្យបានគ្រប់គ្រាន់ អំពីបរិមាណចំណាយ ដោយផ្អែកដែលទទួលខុសត្រូវក្នុងការផលិតស្ថិតិ។ តួលេខដែលមានការគណនានៅក្នុងបង្គោលទី៣ មិនបាន

រួមបញ្ចូល ឬទូទាត់រាល់បរិមាណចំណាយលើហេដ្ឋារចនាសម្ព័ន្ធ (ដូចជា អាគារ សម្ភារៈប្រើប្រាស់ កុំព្យូទ័រ ការបណ្តុះបណ្តាល) ចំណាយលើដើមទុន ឬការចំណាយលើការធ្វើដំណើរ ឬមធ្យោបាយធ្វើដំណើរ ដែលត្រូវការសម្រាប់សកម្មភាពទាំងអស់នេះ។ ហើយវាក៏មិនរាប់បញ្ចូលរាល់បរិមាណចំណាយសម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ ឬប្រាក់ចំណាយ ផ្សេងៗទៀតដែរ។ ការផ្តល់មូលនិធិសម្រាប់ទីប្រឹក្សាអន្តរជាតិ ត្រូវបានបូកបញ្ចូលក្នុងតម្លៃប៉ាន់ប្រមាណសម្រាប់ឆ្នាំ២០១១ និងបន្ថយប្រហែល ៥០ ភាគរយ នៅពេលមូលនិធិផ្តល់ពីដៃគូអភិវឌ្ឍន៍ មានការកាត់បន្ថយបន្តិចម្តងៗ។

**តារាងទី២. ប៉ាន់ស្មានចំណាយសម្រាប់ការផលិតស្ថិតិផ្លូវការនៅវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង**

| ក្រសួង/ស្ថាប័ន (១) | ចំនួនបុគ្គលិកក្នុងការងារផលិតកម្មស្ថិតិរបាយការណ៍ប្រចាំឆ្នាំ២០១១ (២) | ថវិកាប៉ាន់ស្មាន ឬជាក់ស្តែងរបាយការណ៍ប្រចាំឆ្នាំ២០១១ គិតជាដុល្លារសហរដ្ឋអាមេរិក (USD) (៣) | តួលេខរាយការណ៍ដំណើរការនៃការជួបប្រជុំពិគ្រោះយោបល់ (៤) | ចំណាយក្នុងផែនការមេស្ថិតិជាក់ស្តែងឆ្នាំ២០១១ (៥) | ចំណាយប្រាក់បៀវត្សសម្រាប់បុគ្គលិកប្រសិនបើជាមធ្យម ២០០USD ក្នុងមួយខែ ឆ្នាំ ២០១១ (៦) | តួលេខអតិបរមារួមមានប្រាក់បៀវត្សសម្រាប់បុគ្គលិកប៉ាន់ស្មាន ២០០ USD ក្នុងមួយខែ (៧) |
|---|---|---|---|---|---|---|
| អង្គភាពស្ថិតិដែលបានចាត់តាំង | | | | | | |
| NIS | 314 | 6 614 500 | 6 614 500 | 3 360 000 | 753 600 | 6 614 500 |
| COM | 6 | 27 373 | គ្មានព័ត៌មាន | 15 000 | 14 400 | 27 171 |
| MOI | 34 | គ្មានព័ត៌មាន | 15 000 | 100 000 | 81 600 | 81 600 |
| MEF | 27 | 5 400 | 100 000 | 100 000 | 64 800 | 100 000 |
| MAFF | 10 | 78 500 | 32 500 | 320 000 | 24 000 | 78 500 |
| MRD | 5 | 37 200 | 25 000 | 15 000 | 12 000 | 37 200 |
| MOC | 31 | 54 480 | no info | 80 000 | 74 400 | 74 400 |
| MIME | 11 | 17 052 | 80 000 | 80 000 | 26 400 | 80 000 |
| MOEYS | 12 | 64 701 | 170 000 | 170 000 | 28 800 | 170 000 |
| MOSVY | 3 | 12 663 | 35 000 | 15 000 | 7 200 | 35 000 |
| MLMUC | 24 | គ្មានព័ត៌មាន | គ្មានព័ត៌មាន | 80 000 | 57 600 | 80 000 |
| MOE | | គ្មានព័ត៌មាន | គ្មានព័ត៌មាន | 100 000 | 0 | 100 000 |
| MWRM | 4 | 400 | 25 000 | 25 000 | 9 600 | 25 500 |
| MOI | 6 | 727 | 15 000 | 15 000 | 14 400 | 15 000 |
| MOJ | 2 | គ្មានព័ត៌មាន | 40 000 | 40 000 | 4 800 | 40 000 |
| MNASRI | 20 | 2 750 | 15 000 | 15 000 | 48 000 | 48 000 |
| MPT | 3 | 2 900 | 15 000 | 15 000 | 7 200 | 15 000 |
| MoH | 9 | 223 117 | 315 424 | 150 000 | 21 600 | 315 424 |
| MPWT | 5 | គ្មានព័ត៌មាន | 100 000 | 100 000 | 12 000 | 100 000 |
| MCFA | 4 | គ្មានព័ត៌មាន | គ្មានព័ត៌មាន | 15 000 | 9 600 | 15 000 |

| ក្រសួង/ស្ថាប័ន (១) | ចំនួនបុគ្គលិកក្នុងការងារផលិតកម្មស្ថិតិរបាយការណ៍ប្រចាំឆ្នាំ២០១១ (២) | ថវិកាប៉ាន់ស្មានឬជាក់ស្តែងរបាយការណ៍ប្រចាំឆ្នាំ២០១១គិតជាដុល្លារសហរដ្ឋអាមេរិក (USD) (៣) | តួលេខរាយការណ៍ដំណើរការនៃការជួបប្រជុំពិគ្រោះយោបល់ (៤) | ចំណាយក្នុងផែនការមេស្ថិតិជាក់ស្តែងឆ្នាំ២០១១ (៥) | ចំណាយប្រាក់បៀវត្សសម្រាប់បុគ្គលិកប្រសិនបើជាមធ្យម ២០០USD ក្នុងមួយខែ ឆ្នាំ ២០១១ (៦) | តួលេខអតិបរមារួមមានប្រាក់បៀវត្សសម្រាប់បុគ្គលិកប៉ាន់ស្មាន ២០០ USD ក្នុងមួយខែ (៧) |
|---|---|---|---|---|---|---|
| MOT | 20 | 84 900 | 100 000 | 100 000 | 48 000 | 100 000 |
| MRC | | គ្មានព័ត៌មាន | 15 000 | 15 000 | 0 | 15 000 |
| MOWA | 5 | 3 460 | 53 000 | 50 000 | 12 000 | 53 000 |
| MLVT | 11 | 39 200 | 150 000 | 150 000 | 26 400 | 150 000 |
| SCA | 4 | គ្មានព័ត៌មាន | 15 000 | 15 000 | 9 600 | 15 000 |
| SPS | 5 | 15 874 | 15 000 | 15 000 | 12 000 | 15 874 |
| NBC | 22 | គ្មានព័ត៌មាន | គ្មានព័ត៌មាន | 190 000 | 52 800 | 190 000 |
| CDC | 2 | 2 400 | 30 000 | 30 000 | 4 800 | 30 000 |
| ស្ថាប័នផលិតកម្មស្ថិតិផ្សេងទៀត | | | | | | |
| ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល | 68 | គ្មានព័ត៌មាន | គ្មានព័ត៌មាន | | 163 200 | |
| MFA | | 14 | គ្មានព័ត៌មាន | គ្មានព័ត៌មាន | 15 000 | 33 600 |
| SNEC | | | គ្មានព័ត៌មាន | 30 000 | 50 000 | គ្មានព័ត៌មាន |
| សរុប | 681 | 7 287 597 | 8 005 424 | 5 440 000 | 1 634 400 | 8 621 169 |

# ៨. ផែនការអនុវត្តន៍

## ៨.១ យន្តការដើម្បីអនុវត្តផែនការ និងការធ្វើបច្ចុប្បន្នភាពផែនការ

ផែនការមេស្ថិតិ ពិពណ៌នាពីសកម្មភាពស្ថិតិក្នុងប្រព័ន្ធស្ថិតិជាតិ និងជាឯកសារគ្រឹះក្នុងការរៀបចំ និងធ្វើផែនការដើម្បីបំពេញតាមតម្រូវការរបស់អ្នកប្រើប្រាស់នៃស្ថិតិផ្លូវការ និងសម្រាប់យកមកពិភាក្សាអំពីការផ្តល់ហិរញ្ញប្បទាន ជាមួយរាជរដ្ឋាភិបាល និងកន្លងមកជាមួយម្ចាស់ជំនួយ។ ផែនការមេស្ថិតិ ត្រូវបានពិនិត្យឡើងវិញ និងមានការធ្វើបច្ចុប្បន្នភាព ដើម្បីវាយតម្លៃពីសមិទ្ធផលទាំងឡាយ ក្នុងការឆ្លើយតបនឹងកាលៈទេសៈដែលមានការផ្លាស់ប្តូរ និងការងារអាទិភាពទាំងឡាយ។

របាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិផែនការមេស្ថិតិនេះ មានការផ្តល់អនុសាសន៍ដោយ PARIS21 និងតាមរយៈគម្រោងកសាងសមត្ថភាពស្ថាប័ន នៅវិទ្យាស្ថានជាតិស្ថិតិ ដែលមានការឧបត្ថម្ភដោយអង្គការ Sida។ គោលបំណងរួម ដែលត្រូវធ្វើការពិនិត្យឡើងវិញ និងវាយតម្លៃផែនការមេស្ថិតិ និងសកម្មភាពទាំងឡាយ ដែលស្ថិតនៅក្រោមផែនការនេះ គឺដើម្បីវាយតម្លៃទៅលើរាល់ដំណើរការនៃការរៀបចំនានា និងអំពីថាតើសកម្មភាពទាំងអស់នេះ កំពុងរួមចំណែកដល់ការអនុវត្តផែនការមេស្ថិតិនេះយ៉ាងដូចម្តេច។ យន្តការនៃការងារនេះ រួមមានអ្នកផលិត អ្នកប្រើប្រាស់ និងដៃគូអភិវឌ្ឍន៍ ដោយរួមទាំងក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិផងដែរ។

## ៨.២ ការត្រួតពិនិត្យ និងវាយតម្លៃ

ការវាយតម្លៃផែនការមេស្ថិតិ គួរធ្វើឡើងរាល់ ៥ ឆ្នាំម្តង ហើយការកំណត់ពេលវេលាវាយតម្លៃគួរត្រូវផ្តល់អនុសាសន៍ឱ្យធ្វើឡើង ស្របជាមួយនឹងការពិនិត្យឡើងវិញ នូវផែនការយុទ្ធសាស្ត្រផ្សេងៗទៀត (ដូចជាការពិនិត្យឡើងវិញ ផ.យ.អ.ជ ឬគម្រោងផែនការចំណាយនានា ដទៃទៀតរបស់រាជរដ្ឋាភិបាល)។

